# ជំនួយសតិ

## ភាគទី ២១




## សិក្សាព្រះសូត្រ ភាគទី ៩

រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

# ជំនួយសតិភាគទី២១
## សិក្សាព្រះសូត្រ ភាគទី ៩





រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**


សម្រាប់ធម្មទាន

# មាតិកា

| ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- |
| ១. ចូឡរាហុលោវាទសូត្រ | ២ |
| ២. មហារាហុលោវាទសូត្រ | ១៥ |
| ៣. ចូឡមាលុង្ក្យោវាទសូត្រ | ២៣ |
| ៤. មហាមាលុង្ក្យោវាទសូត្រ | ៤១ |
| ៥. ភទ្ទាលិសូត្រ | ៥០ |
| ៦. លដុកិកោបមសូត្រ | ៦១ |
| ៧. ចាតុមសូត្រ | ៦៩ |
| ៨. នឡកបានសូត្រ | ៧៨ |
| ៩. គោលិស្សានិសូត្រ | ៨៦ |
| ១០. កីដាគិរិសូត្រ | ៩២ |
| ១១. មង្គល ៣៨ ប្រការ | ១០០ |

# ព្រះសុត្តន្តបិដកខ្មែរលេខ ២៣

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក
## ភិក្ខុវគ្គ
## មាន ១០ ព្រះសូត្រ គឺ


១- ចូឡរាហុលោវាទសូត្រ ២- មហារាហុលោវាទសូត្រ
៣- ចូឡមាលុង្ក្យោវាទសូត្រ ៤- មហាមាលុង្ក្យោវាទសូត្រ
៥- ភទ្ទាលិសូត្រ ៦- លដុកិកោបមសូត្រ
៧- ចាតុមសូត្រ ៨- នឡកបានសូត្រ
៩- គោលិស្សានិសូត្រ ១០- កីដាគិរិសូត្រ

# ១.ចូឡរាហុលោវាទសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាព្រះមហាវិហារវេឡុវ័ន ជិតក្រុងរាជគ្រឹះ ក្នុងវេលាសាយណ្ហសម័យព្រះអង្គទ្រង់ចេញពីផលសមាបត្តិ ស្តេចយាងចូលទៅកាន់អម្ពលដ្ឋិ-កាវ័ន នៅពីខាងក្រោយវត្តវេឡុវ័ននោះឯង ដើម្បីប្រោសព្រះរាហុល ។ បន្លាវមែងស្រួចតាំងពីកើត យ៉ាងណា ព្រះរាហុលក៏យ៉ាងនោះ គង់ចម្រើនទៅដោយវិវេកគឺសេចក្តីស្ងប់ស្ងាត់ក្នុងទីនោះតាំងពីព្រះជន្ម ៧ វស្សា ។

**អាយស្មន្តំ រាហុលំ អាមន្តេសិ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះរាហុល គឺត្រាស់ហៅដើម្បីប្រទានឱវាទ ។ ពិតណាស់ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងព្រះធម៌ទេសនាយ៉ាងច្រើនដល់ព្រះរាហុល ព្រះអង្គទ្រង់ត្រាស់សាមណេរប្បញ្ហា រាហុលសំយុត្តមហារាហុលោវាទសូត្រ ចូឡរាហុលោវាទសូត្រ រួមទាំងអម្ពលដ្ឋិក-រាហុលោវាទសូត្រនេះផង ( ដោយចូឡរាហុលោវាទសូត្រមានពីរសូត្រ មួយនៅក្នុងបិដកលេខ ២៨ ដែលព្រះរាហុលស្តាប់ហើយ

សម្រេចព្រះអរហត្ត ដូច្នេះទើបព្រះសូត្រនេះ ព្រះអដ្ឋកថាហៅថា អម្ពលដ្ឋិករាហុលោវាទសូត្រ ) ។

ព្រះរាហុលមានព្រះជន្ម ៧ វស្សា ព្រះដ៏មានព្រះភាគទ្រង់ប្រគល់ឲ្យព្រះសារីបុត្តបំបួសជាសាមណេរ ក្នុងវស្សានោះឯងដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងនូវព្រះសូត្រនេះ ដោយព្រះដ៏មានព្រះ-ភាគទ្រង់ព្រះតម្រិះថា ព្រះរាហុលនៅកុមារ ជាធម្មតាក្មេងតូចរមែងនិយាយនូវពាក្យដែលគួរនិងមិនគួរ ដូច្នេះយើងនឹងឲ្យឱវាទដល់រាហុល ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងឧបមាដោយផ្ដិលទឹក ៤ លើក ឧបមាដោយដំរី ២ លើក និងឧបមាដោយកញ្ចក់ឆ្លុះមុខ ១ លើក ។ សេចក្ដីនៅក្នុងព្រះសូត្រនេះ គឺមានប្រយោជន៍ដើម្បីកុំឲ្យព្រះរាហុលពោលនូវសម្បជានមុសាវាទ ( ពោលកុហកទាំងដឹងខ្លួនច្បាស់ ) ។

## ឧបមាដោយផ្ដិលទឹក ៤ លើក

១- ព្រះអង្គទ្រង់ទុកទឹកឲ្យសល់បន្តិចក្នុងផ្ដិល ហើយត្រាស់សួរ... ។

២- ព្រះអង្គទ្រង់ចាក់ទឹកដែលសល់បន្តិចនោះចោល ហើយត្រាស់សួរ... ។

៣- ព្រះអង្គទ្រង់ផ្កាប់ផ្តិលទឹកនោះ ហើយត្រាស់សួរ... ។

៤- ព្រះអង្គទ្រង់ផ្ងារផ្តិលទឹកនោះវិញ ហើយត្រាស់សួរ... ។

គឺព្រះអង្គទ្រង់ត្រាស់សួរព្រះរាហុលបញ្ជាក់អំពីផ្តិលទឹកនោះៗ ដោយការប្រៀបធៀបហើយ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុ ដែលមិនមានសេចក្តីអៀនខ្មាសក្នុងសម្បជានមុសាវាទ ដូចជាទឹកដែលមានប្រមាណតិច ដូចជាទឹកដែលតថាគតចាក់ចោល ដូចជាផ្តិលទឹកដែលតថាគតផ្កាប់ និងដូចជាផ្តិលទឹកដែលទទេរលីងធេង ដូច្នេះឯង ។

## ឧបមាដោយដំរី ២ លើក

១- ដំរីកាលបើចូលកាន់សង្គ្រាម រមែងប្រើអវយវៈទាំងពួងធ្វើការសព្វគ្រប់ រក្សាទុកតែប្រមោយប៉ុណ្ណោះ ឈ្មោះថា មិនទាន់ហ៊ានលះបង់ជីវិតនៅឡើយ ។

២- ដំរីកាលបើចូលកាន់សង្គ្រាម រមែងប្រើអវយវៈទាំងអស់

ធ្វើការសព្វគ្រប់ មិនរក្សាទុកសូម្បីតែប្រមោយ ឈ្មោះថា ជាដំរីហ៊ាន លះបង់ជីវិត ។

ម្នាលរាហុល មានឧបមេយ្យដូចភិក្ខុណាមួយ ដែលមិនមានសេចក្តីអៀនខ្មាសក្នុងសម្បជានមុសាវាទ តថាគត មិនពោលថា ភិក្ខុនោះមិនធ្វើបាបកម្មតិចតួចដូច្នេះទេ ។ ម្នាលរាហុល ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគួរសិក្សាថា អាត្មាអញនឹងមិនពោលពាក្យកុហក សូម្បីគ្រាន់តែដើម្បីសើចលេងនោះឡើយ ម្នាលរាហុល អ្នកត្រូវសិក្សា យ៉ាងនេះចុះ ។

បទថា **នាហំ តស្ស កិញ្ចិ បាបំ** គឺបុគ្គលណា ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងការពោលកុហកទាំងដែលដឹងខ្លួនច្បាស់ ថាបុគ្គលនោះឯង មិនធ្វើនូវបាបកម្មអ្វីតិចតួចនោះ មិនមានឡើយ ( បានសេចក្តីថា មិនមាននូវសម្បជានមុសាវាទណា ដែលមិនមែនជាបាបសូម្បីត្រឹមតែបន្តិចបន្តួចនោះទេ គឺថា បើមិនបាបធំក៏បាបតូចដែរ ដូចជាដំរីក្នុងចំណុចទីពីរ ដែលថាមិនធ្វើកម្មដោយអវយវៈណាមួយនោះ មិនមានហ្នឹងឯង ) ។

# ឧបមាអំពីកញ្ចក់

កញ្ចក់មានប្រយោជន៍ដូចម្តេច ? កញ្ចក់មានប្រយោជន៍ក្នុងការឆ្លុះមើលមុខ ។

ម្នាលរាហុល យ៉ាងនោះមែនហើយ អ្នកគប្បីពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយកាយ ពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយវាចា ពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយចិត្ត ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីការពិចារណានូវកម្មទាំងបី ទាំងដែលនឹងធ្វើ កំពុងធ្វើ ទាំងដែលធ្វើរួចហើយ ដោយពិស្តារ ដែលព្រះធម៌ទេសនានេះប្រព្រឹត្តទៅសមគួរដល់វេនេយ្យសត្វ គឺបុគ្គលដែលគួរដល់ការណែនាំ ។

**សូមអនុមោទនា !**

# បទពិចារណា

បើយើងនិយាយដោយមានសតិចេះត្រិះរិះពិចារណា យើងរមែងបាននូវបុណ្យដ៏ធំមួយ គឺការមិនប្រទូសរ៉ាយបៀតបៀនផ្លូវចិត្តនៃអ្នកដទៃ ។ ដូចគ្នាដែរ បើយើងស្តាប់ដោយមានសតិចេះត្រិះរិះពិចារណា យើងរមែងបាននូវសេចក្តីសុខស្ងប់ ត្រង់ដែលមិនបានយកអារម្មណ៍ គឺពាក្យសម្តីនៃអ្នកដទៃនោះៗ មកប្រទូសរ៉ាយបៀត-បៀនដល់ចិត្តសន្តានរបស់យើង ហ្នឹងឯង ។ ត្រូវរលឹកឃើញថា អ្វីៗសុទ្ធតែមានហេតុត្រឹមត្រូវ ជាការពិត គឺត្រូវតែយ៉ាងហ្នឹងឯង... យល់ព្រម សុខចិត្ត ស្ងប់ត្រជាក់ ។

# ទាល់តែចេះល្មម បានមានរបស់គ្រប់

បើមិនបាននូវអ្វីៗដែលជាទីពេញចិត្តទេ ត្រូវល្មមចិត្តជាមួយនឹងអ្វីៗដែលខ្លួនឯងមានប៉ុណ្ណឹងទៅ កុំចេះតែចង់បាននូវអ្វីៗឲ្យលើសល្មមនោះ ព្រោះក្នុងលោកនេះ មិនមានអ្វីឲ្យបានគ្រប់គ្រាន់ សម្រាប់មនុស្សដែលមិនចេះល្មមនោះឡើយ ។

# សុខនិងទុក្ខ

សុខនៅនឹងចិត្តរបស់យើង ចំណែកទុក្ខក៏នៅនឹងចិត្តរបស់យើងដែរ ដូច្នេះត្រូវចេះមើលថែចិត្តរបស់ខ្លួនឲ្យបានល្អ ។

# គ្រប់គ្នាចង់បានសុខ

គ្រប់គ្នាចង់បានសុខ គ្រាន់តែថា តើស្គាល់សុខពិតដែរឬទេ ? ព្រោះសុខមានពីរយ៉ាង គឺសុខពិត ១ សុខក្លែងក្លាយ ១ ។ សុខក្លែងក្លាយ គឺសុខនាំទុក្ខមកប្រគល់ឲ្យ ឯចំណែកសុខពិត គឺសុខកម្ចាត់ទុក្ខឲ្យអស់ពីជីវិត និងឲ្យអស់ពីវដ្តសង្សារ ដូច្នេះដើម្បីឲ្យបានស្គាល់សុខពិតប្រាកដ ត្រូវអប់រំបញ្ញាឲ្យស្គាល់ទុក្ខក្នុងវដ្តៈ ព្រោះទុក្ខមិនមែនមានតែក្នុងអត្តភាពមួយនេះទេ ដរាបណានៅមានតណ្ហាដរាបនោះ ទុក្ខនៅតែមាន លុះត្រាតែកម្ចាត់តណ្ហាបាន ទើបបានសុខពិតប្រាកដ ដែលជាបរមសុខ ។

## រឿងតូចតាច តែសំខាន់គ្រប់សុខចិត្ត

កុំបណ្តោយឲ្យរឿងបន្តិចបន្តួច ទៅជាមានអំណាចមកទម្លាយសេចក្តីសុខរបស់យើងក្នុងបច្ចុប្បន្ន តើយើងរស់នៅដើម្បីអ្វី បើមិនដើម្បីរក្សាសេចក្តីសុខក្នុងជីវិតទេនោះ ។ កុំចេះតែស្រមៃទៅរកអ្វីធំដុំសម្រាប់សេចក្តីសុខសព្វថ្ងៃនេះ គឺឲ្យតែយើងចេះយកចិត្តទុកដាក់ ឲ្យសេចក្តីសំខាន់ក្នុងការថែរក្សាចិត្ត ជាមួយនឹងរឿងតូចតាចផ្សេងៗ ធ្វើទៅ និយាយទៅ គិតទៅ ព្រមដោយសេចក្តីសុខដែលប្រាសចាកទោស រួចហើយនឹកឃើញមានសេចក្តីសុខបន្ថែមទៀត ។

## បុណ្យធ្វើឲ្យចិត្តសុខស្ងប់

បុណ្យកុសល ធ្វើឲ្យចិត្តសុខស្ងប់ ។ នេះជាការពិតដែលត្រូវយល់ដឹងជាក់ស្តែងដោយខ្លួនឯង ដូច្នេះទើបមិនត្រូវបណ្តោយចិត្តឲ្យទៅតាមការស្រឡាញ់ស្អប់គាប់ទាស់នោះឡើយ ត្រូវឃើញការងារថែរក្សាចិត្តសំខាន់ជាទីបំផុត ក្នុងជីវិតរស់នៅ ទាំងត្រូវដឹងថា បាបអកុសលហ្នឹងឯង ដែលធ្វើឲ្យចិត្តក្រវល់ក្រវាយ ក្តៅក្រហាយ

មិនស្ងប់ ។

## ផ្លូវនៃជីវិត

ផ្លូវមិនរាបស្មើ ដំណើររលាក់ យ៉ាងណាមិញ ផ្លូវនៃជីវិតក៏ដូច្នោះដែរ រមែងមានឧបសគ្គជាដំណើររលាក់ ប៉ុន្តែមិនត្រូវចេះតែទៅតាមចំណង់នោះឡើយ ត្រូវយល់ដឹងអំពីការពិតនៃជីវិត ដែលអ្វីៗសុទ្ធតែជាបរមត្ថកើតឡើងយ៉ាងត្រឹមត្រូវទៅតាមបច្ច័យ ។ បើយើងយកការពិតគឺភាពត្រឹមត្រូវនៃអ្វីៗដែលបានកើតឡើងនោះ មកជាអារម្មណ៍នៃការសុខចិត្ត យល់ព្រម ទទួលបាន ដូច្នេះជីវិតរមែងប្រព្រឹត្តទៅក្នុងផ្លូវស្មើ ។

## កើតទុក្ខព្រោះលង្ងៀង

គ្រប់រឿង សុទ្ធតែមានភាពត្រឹមត្រូវដោយបរមត្ថ រៀបរយសព្វគ្រប់ប្រព្រឹត្តទៅតាមបច្ច័យ ជាសច្ចធម៌ មិនមានអ្វីដែលសម្រាប់ឲ្យកើតទុក្ខមិនសុខចិត្ត ប្រកែក តវ៉ា ទាមទារយ៉ាងដទៃនោះឡើយ

ដូច្នេះមនុស្សយើងកើតទុក្ខមិនសុខស្ងប់ក្នុងចិត្ត ព្រោះចិត្តលម្អៀងខ្លួនឯង ។

## អកុសលា ធម្មា

បើមិនមានលោភៈ ទោសៈ មោហៈទេ តើមានអ្នកណាធ្វើអ្វីខុស ដូច្នេះចំណុចដែលត្រូវសង្កេត គឺនៅត្រង់យើងឃើញអកុសលាធម្មា ឬអកុសលា គេ ។ បើយើងឃើញថា អកុសលា គេ យើងនឹងខឹង តែបើឃើញថា គឺជាអកុសលា ធម្មា យើងរង្កៀសចំពោះតែអកុសលធម៌ប៉ុណ្ណោះ មិនស្អប់អ្នកណាឡើយ ។

## ចេះសាងកម្លាំងចិត្តជាមួយនឹងគុណធម៌

នាងបដាចារ មានកម្លាំងចិត្តចេញពីត្រកូលសេដ្ឋី ទៅរស់នៅក្នុងព្រៃ ជាមួយនឹងបុរសអ្នកបម្រើដែលខ្លួនស្រឡាញ់... ។ សេចក្តីនេះ គ្រាន់តែលើកបញ្ជាក់អំពីសេចក្តីស្រឡាញ់ជាតួសាងកម្លាំងចិត្តប៉ុណ្ណោះ ដូច្នេះយើងគួរតែចេះសាងកម្លាំងចិត្តក្នុងការងារជាមួយនឹង

អ្វីដែលយើងស្រឡាញ់ តែសូមឲ្យអ្វីដែលយើងស្រឡាញ់នោះ នាំយើងចេញឲ្យរួចពីទុក្ខពិតប្រាកដ មិនវិលវិញ ដូចជាស្រឡាញ់សីលជាដើម ។

## អនវជ្ជសុខ

ចេះសប្បាយជាមួយនឹងការងារដែលប្រាសចាកទោស គឺជាសេចក្តីសុខ ។ ត្រូវធ្វើការងារឲ្យសមនឹងសមត្ថភាព សមនឹងឋានៈរបស់ខ្លួន ធ្វើដោយពេញចិត្ត អត់ធន់ព្យាយាម... ។ កុំមានការលោភលន់ចង់ឲ្យដូចអ្នកដទៃដែលមានអ្វីច្រើនៗនោះឡើយ កុំឲ្យដូចក្អែកគោកធ្វើត្រាប់តាមក្អែកទឹក ឃើញក្អែកទឹករកចំណីបានស្រួលងាយ ខ្លួនឯងគ្មានជំនាញត្រូវទាក់កនឹងសារាយក្នុងទឹក ស្លាប់បាត់បង់ជីវិតទៅ ។

## កន្លែងសុខនៅនឹងចិត្តរបស់យើង

មិនចាំបាច់ឈរកន្លែងល្អដូចអ្នកដទៃនោះទេ ត្រឹមតែមាន

សេចក្ដីសុខនៅត្រង់កន្លែងដែលយើងឈរហ្នឹងទៅបានហើយ ។

## ខ្លឹមសារនៃជីវិត

ក្រទ្រព្យ មិនមែនបានន័យថាថោកទាប ឯការមានទ្រព្យ ក៏មិនមែនប្រែថាខ្ពង់ខ្ពស់ថ្លៃថ្នូរនោះដែរ គឺវាស្ថិតនៅលើការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ ។ ម្យ៉ាងទៀត ក្រទ្រព្យ មិនមែនបានន័យថាមានទុក្ខ ចំណែកបានទ្រព្យ ក៏មិនមែនប្រែថាបានសុខដែរ ចំពោះសុខទុក្ខនេះ គឺមានទាំងផ្លូវកាយ ទាំងផ្លូវចិត្ត អាចនៅជាមួយបានទាំងអ្នកមាន ទាំងអ្នកក្រ ដូច្នេះមនុស្សយើង គួរយកចិត្តទុកដាក់ចំពោះគុណតម្លៃនៃជីវិត ឲ្យជាការសំខាន់ ទោះមានឬក្រយ៉ាងណាក៏ដោយ ព្រោះជីវិតដែលមានតម្លៃទៅដោយគុណធម៌ នាំឲ្យសម្រេចនូវប្រយោជន៍ទាំងពួង ទាំងប្រយោជន៍ខ្លួនឯង ទាំងប្រយោជន៍អ្នកដទៃ នេះទើបជាខ្លឹមសារនៃជីវិត ។

# ពឹងខ្លួនឯង បានក្សេមក្សាន្តនិព្វាន

បញ្ឈប់ខឹងក្រោធផ្តោតឲ្យអភ័យ បញ្ឈប់អាល័យក្នុងន័យលះបង់
បញ្ឈប់មាយាការងារស្មោះត្រង់ បញ្ឈប់ចំណង់ឃើញត្រង់ការពិត ។
មិនមានវេលាឈ្លោះគ្នាទេណា៎ គ្មានពេលឥស្សាមរណាមកជិត
ទានសីលភាវនានាំគ្នាប្រព្រឹត្ត ស្មោះត្រង់សុចរិតស្ងប់ចិត្តប្រពៃ ។
ផ្ទះល្អព្រោះម្ចាស់ក្រាស់ដោយទឹកចិត្ត អារាមល្អពិតដ្បិតធម៌វិន័យ
មនុស្សល្អព្រោះធម៌បវរខន្តី តែងឲ្យអភ័យមេត្រីសុខសាន្ត ។
ពាលពិតល្ងង់ខ្លៅសត្រូវនឹងខ្លួន បណ្ឌិតមាំមួនជួយខ្លួនឯងបាន
បុណ្យឲ្យស្ងប់ចិត្តស័ក្តិសិទ្ធិកល្យាណ ពឹងខ្លួនឯងបានក្សេមក្សាន្តនិព្វាន ។

ដោយ **ប.ស.វ.**

# ម្លប់នៃព្រះធម៌

អ្នកណាស្រឡាញ់ អ្នកណាស្អប់យើងក៏ដោយចុះ គេសរសើរ ឬនិន្ទាស្រេចតែគេ ចំណែកយើងមានសេចក្តីអត់ធន់ ចម្រើនមេត្តា មានចិត្តស្ងប់ត្រជាក់ រស់នៅក្រោមម្លប់នៃព្រះធម៌ គឺសុខហើយ ។

# ២. មហារាហុលោវាទសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនា ព្រះមហាវិហារជេតពន ស្ដេចយាងបិណ្ឌបាតចូលទៅកាន់ក្រុងសាវត្ថី ដោយព្រះរាហុលនិមន្តតាមក្រោយ ។ សម័យនោះ ព្រះរាហុលមាន ព្រះជន្ម១៨ ព្រះវស្សា នៅជាសាមណេរនិមន្តតាមព្រះដ៏មានព្រះភាគ កើតឆន្ទរាគៈពេញចិត្តនឹងអត្តភាព ស្រឡាញ់រូបកាយក្នុងគំនិតថា អាត្មាអញមានរូបស្អាត ស័ក្តិសមជាបរិនាយកណាស់ ប្រសិនបើ ព្រះបិតាជាស្ដេចចក្រគ្រប់គ្រងក្នុងទ្វីបទាំង ៤ នោះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបចិត្តុប្បាទរបស់ព្រះរាហុល ដូច គេឃើញត្រីនៅក្នុងទឹកថ្លា ឬឃើញស្រមោលមុខដែលឆ្លុះក្នុងកញ្ចក់ ដូច្នោះឯង ។ ព្រះអង្គទ្រង់ជ្រាបថា ព្រះរាហុលស្ទុះចេញទៅក្រៅផ្លូវ ទៅក្នុងទីអគោចរ ទៅកាន់ទិសដែលមិនគួរទៅ ដូចជាមនុស្សវង្វេង ផ្លូវ ទើបទ្រង់បែរព្រះវរកាយមកក្រោយ ត្រាស់ទៅនឹងព្រះរាហុល ដោយលើកយករូបក្ខន្ធមកជាអារម្មណ៍នៃព្រះកម្មដ្ឋាន ។

ដោយការគោរពដ៏ក្រៃលែង ថ្ងៃហ្នឹងព្រះរាហុលមិននិមន្តទៅ

បិណ្ឌបាតឡើយ ហើយក៏មិនឆាន់ចង្ហាន់ទៀត ព្រោះគោរពក្នុងសុគតោវាទ ដែលសុគតោវាទនេះរកបានដោយក្រក្នុងវេលាអសង្ខេយ្យកប្ប ព្រះរាហុលបាននិមន្តត្រឡប់មកគង់នៅក្រោមម្លប់ឈើមួយដើម ដោយការតាំងស្មារតីក្នុងព្រះកម្មដ្ឋានអប់រំចិត្ត ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះថា ថ្ងៃនេះរាហុលចូរបរិភោគនូវអមតភោជនគឺកាយគតាសតិចុះ ។

ព្រះសារីបុត្ត និមន្តមកតាមក្រោយដើម្បីបិណ្ឌបាត ឃើញព្រះរាហុលគង់យ៉ាងសមសួន ក៏ណែនាំដោយអានាបាណស្សតិ-កម្មដ្ឋានដល់ព្រះរាហុល ដោយមិនបាននឹកដល់ថា ព្រះដ៏មាន-ព្រះភាគទ្រង់បានប្រទាននូវរូបកម្មដ្ឋានហើយនោះឡើយ ។

ព្រះរាហុល បានពិចារណាធ្វើទុកក្នុងចិត្តនូវឱវាទព្រះកម្មដ្ឋានរបស់ព្រះសាស្តា ហើយក៏មិនមែនថាមិនអើពើនឹងការណែនាំរបស់ព្រះឧបជ្ឈាយ៍ដែរ នៅពេលថ្ងៃរសៀល ព្រះរាហុលបានចូលទៅថ្វាយបង្គំព្រះបរមសាស្តា ទូលសួរអំពីវិធីចម្រើននូវអានាបា-ណស្សតិកម្មដ្ឋាន ។ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានត្រាស់ឆ្លើយតបភ្លាមៗតាមសំណួរឡើយ ព្រោះព្រះអង្គទ្រង់ជ្រាបអំពីឆន្ទរាគៈកើតឡើងដល់ព្រះរាហុលអាស្រ័យអត្តភាព ។ ក្នុងពេលនិមន្ត

បិណ្ឌបាតទ្រង់បានប្រទានដោយសង្ខេបហើយ លើកនេះ ព្រះអង្គទ្រង់ប្រទានចែកមហាភូតរូប ៤ ដោយអាការ ៤២ ( គឺអាការបឋវី ២០ អាបោ ១២ តេជោ ៤ និងវាយោ ៦ ) ត្រាស់ឧបាទាយរូបដោយការប្រកាសសម្តែងនូវអាកាសធាតុដោយពិស្តារ ។

ជាបន្ត ព្រះអង្គទ្រង់ត្រាស់ឲ្យព្រះរាហុលចម្រើនមេត្តាកម្ចាត់ព្យាបាទ ចម្រើនករុណាកម្ចាត់ការបៀតបៀន ចម្រើនមុទិតាកម្ចាត់អរតិ ( គឺការមិនត្រេកអរព្រោះច្រណែន ម្យ៉ាងទៀត មិនត្រេកអរក្នុងសេនាសនៈស្ងាត់ មិនត្រេកអរក្នុងអធិកុសល ) ចម្រើនឧបេក្ខាកម្ចាត់បដិឃៈគឺការថ្នាំងថ្នាក់អាក់អន់ចិត្ត ។ ចម្រើនអសុភកម្មដ្ឋានកម្ចាត់រាគៈគឺតម្រេកក្នុងកាម ចម្រើនអនិច្ចសញ្ញាកម្ចាត់អស្មិមានៈគឺការប្រកាន់ថារូបអញប្រសើរជាងគេជាដើម ។ ជាចុងក្រោយនៃព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អានាបាណស្សតិដោយពិស្តារ ទៅតាមការទូលសួររបស់ព្រះរាហុល ជាបុគ្គលគួរដល់ការណែនាំ ។

សូមអនុមោទនា !

## ឥស្សរភាពលើកិលេស ទើបធំពិតប្រាកដ

កុំចាំបាច់ពោលដល់ភាពជាឥស្សរៈលើកិលេសផ្សេងៗ គ្រាន់តែឲ្យបានជាអ្នកធំលើទូរស័ព្ទពេលកំពុងស្តាប់ធម៌នោះ មិនទាំងបានផង ត្រូវធ្វើជាអ្នកបម្រើទូរស័ព្ទ សូម្បីពេលបាយ ពេលចូលបង្គន់ក៏មិនទំនេរដែរ ទាំងយប់ទាំងថ្ងៃ ទាំងពេលកំពុងបើកឡាន បើកម៉ូតូ... ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា **សព្វំ ឥស្សរិយំ សុខំ** ឥស្សរភាពទាំងពួង គឺភាពជាធំលើកិលេសទាំងអស់ នាំមកនូវសេចក្តីសុខពោលដល់ទីបំផុតគឺព្រះនិព្វានជាបរមសុខ ។

## ស្គាល់ខ្លួនពិតប្រាកដ

ការស្គាល់ខ្លួនឯងពិតប្រាកដ គឺស្គាល់ធម៌ បានដល់បរមត្ថធម៌ដែលជាសង្ខារធម៌សុទ្ធៗមិនមែនសត្វ ។ ពេលណាដែលបានឃើញធម៌ ឃើញសង្ខារលោក ពេលនោះ ក៏បានឃើញព្រះសម្មាសម្ពុទ្ធថាព្រះអង្គទ្រង់ត្រាស់ដឹងដោយប្រពៃពិតមែន ។

# ឃើញការពិត រលត់តណ្ហា

មកពីយើងល្ងង់ខ្លួនឯងទេ បានជាចង់ឲ្យអ្វីៗត្រូវចិត្ត ដល់មិនបានដូចចិត្តក៏ខឹងក្រោធ កើតទុក្ខកន្ទក់កន្ទេញ ។ តាមពិត អ្វីៗក្នុងលោកមិនបានផ្គាប់ចិត្តយើងមែន ប៉ុន្តែអ្វីៗនោះ អត់មានខុសទេ គឺត្រឹមត្រូវតាមបច្ច័យ ពុទ្ធបរិស័ទ មិនគួរឡេះឡោះតាមចំណង់ ចេះតែចង់យ៉ាងនេះ យ៉ាងនោះទៅនោះឡើយ គួរសិក្សាចូលឲ្យដល់សច្ចធម៌ដោយបញ្ញា ទើបបានសុខចិត្ត ស្ងប់ត្រជាក់ទៅក្នុងគ្រប់រឿងទាំងអស់ ។

# អស់កិលេសទើបអស់បញ្ហា

យើងមានកិលេសក្នុងចិត្ត កិលេសហ្នឹងឯងនាំឲ្យធ្វើខុស នាំឲ្យភ័យ នាំឲ្យកើតទុក្ខ នាំឲ្យមានបដិសន្ធិ...។ ទោះជាមានមាសប្រាក់ច្រើនប៉ុនណា ក៏មាសប្រាក់មិនអាចលះកិលេសបានដែរ ដូច្នេះ ការប្រព្រឹត្តធម៌លះកិលេស ទើបជាទិសដៅនៃអ្នកដែលប្រាថ្នាឲ្យរួចផុតចាកទុក្ខ ។

## កាន់តែដាក់ចុះគឺកាន់តែស្រាល

បើអ្វីៗជារបស់យើង វានៅក្នុងអំណាចយើងហើយ បើអ្វីៗ មិនមែនជារបស់យើងហើយ តើចង់បានអ្វីៗនោះធ្វើអ្វី ។ ជាមួយ នឹងសង្ខារធម៌ កាន់តែដាក់ចុះ កាន់តែលះបង់ គឺរមែងកាន់តែធូរ ស្រាលនូវទុក្ខកង្វល់ ។

## អកុសលមូលជាហេតុនៃអកុសលកម្ម

ទោះជាមនុស្សអាក្រក់ក្នុងទុច្ចរិតយ៉ាងណាក៏ដោយ បើដក លោភៈ ទោសៈ មោហៈ ចេញហើយ មានទុច្ចរិតអ្វីទៀត ដូច្នេះ ទើបមិនគួរស្អប់អ្នកណាៗក្នុងរឿងអ្វីឡើយ ព្រោះទុច្ចរិត អកុសល-កម្ម អាស្រ័យអកុសលមូលជាហេតុទេតើ ។

## អ្នកធ្វើកម្មគ្រាន់តែជាចោរហារ

កុសលកម្មអាស្រ័យកុសលមូលជាហេតុ អកុសលកម្ម

អាស្រ័យអកុសលមូលជាហេតុ កាលបើបញ្ញាបានឃើញច្បាស់នូវសេចក្តីនេះតាមពិតហើយ រមែងមិនមានសេចក្តីប្រកាន់ថា មានអ្នកធ្វើកម្មនោះឡើយ បុគ្គលអ្នកធ្វើកម្ម មានតែរោហារអាស្រ័យនឹងបរមត្ថតែប៉ុណ្ណោះ ។

## តាំងចិត្តឲ្យស្ងប់ដោះស្រាយបញ្ហា

តាមពិត កាលដែលចិត្តតាំងនៅស្ងប់ក្នុងមហាកុសលហើយ បញ្ហាអ្វីៗនោះមិនមានឡើយ គឺត្រូវដោះស្រាយហើយស្រេចដោយមហាកុសល ព្រោះថាបញ្ហាដែលមាននោះ គឺមានចិត្តដែលត្រូវរុំព័ទ្ធទៅដោយកិលេសហ្នឹងឯង ដូច្នេះបញ្ហាគ្រប់យ៉ាងក្នុងលោកនេះ សុទ្ធតែមានផ្លូវចេញទាំងអស់ ឲ្យតែយើងជឿជាក់លើមហាកុសល កុំគាំទ្រកិលេសខ្លួនឯងទៅបានហើយ ។

## មិនប្រឆាំងនឹងការពិត ឲ្យសិទ្ធិក្នុងការកើត

នៅពេលដែលមានរឿងរ៉ាវស្មុគស្មាញ មនុស្សយើងចេះតែ

គិតមិនសុខចិត្តក្នុងរឿងរ៉ាវនោះៗ ដោយមិនយល់អំពីការពិតផង មិនអប់រំចិត្តឲ្យឋិតនៅក្នុងមហាកុសល ដែលហៅថាកុសលភាវនានោះផង ដូច្នេះសូមពុទ្ធបរិស័ទ បដិបត្តិឲ្យបានដល់កម្រិតមួយ គឺព្រមឲ្យសិទ្ធិក្នុងការកើតឡើងនូវអ្វីៗនោះ ទៅតាមបច្ច័យដែលមានទើបចិត្តមានឱកាសបានតាំងនៅស្ងប់ក្នុងមហាកុសល គ្រប់គ្រង ថែរក្សាដោយសតិសម្បជញ្ញៈ ។

## ព្រមពេលណាសុខចិត្តពេលហ្នឹង

អ្វីៗដែលយើងកំពុងមាន កំពុងបាន កំពុងរស់នៅ គឺមិនត្រូវរំលងឡើយ បច្ចុប្បន្នធម៌ហ្នឹងឯងហើយដែលជាការពិត ដឹងហើយសុខចិត្ត ស្ងប់ត្រជាក់ ។ ព្រោះតែមើលរំលងធម៌ក្នុងបច្ចុប្បន្ន ទើបមានការកើតទុក្ខមិនសុខចិត្ត សោកស្តាយក្នុងគំនិតថា ប្រសិនបើយ៉ាងនេះវិញ យ៉ាងនោះវិញ រវើរវាយរកលាភ រកយស រករបស់ឲ្យជាទីពេញចិត្ត ប៉ុន្តែមិនបានរកការពិតឡើយ ។

# ៣-ចូឡមាលុង្ក្យោវាទសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះមា-លុង្ក្យបុត្តដ៏មានអាយុ បានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលសូមឲ្យព្រះអង្គទ្រង់ប្រកាសសម្តែងនូវមិច្ឆាទិដ្ឋិ គំនិតយល់ឃើញខុសផ្សេងៗ ១០ យ៉ាង ដែលពួកមនុស្សក្រៅព្រះពុទ្ធសាសនាកាន់យកទីបំផុតរៀងៗខ្លួន ឈ្លោះប្រកែកគ្នាថាខ្លួនឯងយល់ត្រូវ អ្នកដទៃយល់ខុស ដូច្នេះតើព្រះដ៏មានព្រះភាគទ្រង់ជ្រាបទិដ្ឋិមួយណាក្នុងទិដ្ឋិទាំង ១០ នោះ សូមព្រះអង្គទ្រង់ត្រាស់សម្តែងឲ្យទាន ។

## មិច្ឆាទិដ្ឋិ ១០ យ៉ាង

១- លោកទៀង ( សស្សតោ លោកោ )

២- លោកមិនទៀង ( អស្សស្សតោ លោកោ )

៣- លោកមានទីបំផុត ( អន្តវា លោកោ )

៤- លោកមិនមានទីបំផុត (អនន្តវា លោកោ)

៥- ជីវៈនោះគឺសរីរៈនោះ (តំ ជីវំ តំ សរីរំ)

៦- ជីវៈដទៃ សរីរៈដទៃ (អញ្ញំ ជីវំ អញ្ញំ សរីរំ)

៧- សត្វស្លាប់ហើយកើតទៀត

៨- សត្វស្លាប់ហើយមិនកើតទៀត

៩- សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន

១០- សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ព្រះដ៏មានព្រះភាគ ទ្រង់មិនត្រាស់ព្យាករនូវចំណុចណាមួយក្នុងមិច្ឆាទិដ្ឋិទាំង ១០ នេះឡើយ ព្រះអង្គទ្រង់ត្រាស់ថា កាលបើមានការយល់ឃើញទៅតាមមិច្ឆាទិដ្ឋិទាំង ១០ នេះ ណាមួយ ការអប់រំព្រហ្មចរិយធម៌មិនមានឡើយ ប៉ុន្តែគឺជាការប្រព្រឹត្តទៅនាំឲ្យមានជាតិ ជរា មរណៈ សោកខ្សឹកខ្សួល លំបាកកាយលំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តដោយពិត ព្រះតថាគតទ្រង់បញ្ញត្តការកម្ចាត់បង់នូវកងទុក្ខទាំងអស់នេះ ដែលត្រូវបានឃើញច្បាស់ក្នុងបច្ចុប្បន្ន គឺថាព្រះអរិយសាវ័កទាំងឡាយ នឿយណាយក្នុងជរានិងមរណៈជាដើមហើយ ទើបសម្រេចនូវព្រះនិព្វានក្នុងព្រះសាសនានេះឯង ។

ព្រោះហេតុទិដ្ឋិទាំង ១០ យ៉ាងនេះ មិនប្រកបដោយ

ប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីរួចផុតចាកទុក្ខ ទើបព្រះអង្គទ្រង់មិនព្យាករ ប៉ុន្តែអ្វីដែលព្រះអង្គទ្រង់ត្រាស់ព្យាករសម្តែងគឺអរិយសច្ចធម៌ ព្រោះការព្យាករសម្តែងនូវអរិយសច្ចធម៌ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីជាក់ច្បាស់នូវព្រះនិព្វានជាអសង្ខតធាតុ ។

សូមអនុមោទនា !

## លិចចុះក្នុងទុក្ខ

សូម្បីតែគំនិតយល់ខុស ( គឺយល់ខុសពីការពិត ) ក៏ជាសភាវធម៌កើតពីបច្ច័យដែរ ជារបស់មិនទៀង ជាទុក្ខ ពួកអ្នកយល់ខុសទាំងនោះមានការប្រកាន់ក្នុងទិដ្ឋិរបស់ខ្លួន ឈ្មោះថាលិចចុះក្នុងទុក្ខ ។

# មិនលិចចុះក្នុងទុក្ខ

សភាវធម៌ទាំងអស់ កើតពីបច្ច័យ មានបច្ច័យតាក់តែងឲ្យកើតឡើងហើយ សុទ្ធតែមិនទៀង មានការអស់ទៅ សូន្យទៅ ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាមិនទៀង ជាទុក្ខ មានការប្រែប្រួល វិបស្សនាឃើញថា របស់នោះមិនមែនជារបស់យើង មិនមែនជាយើង មិនមែនជាខ្លួនរបស់យើងទេ ។ ព្រះអរិយ-បុគ្គលទាំងឡាយ មិនប្រកាន់ក្នុងបញ្ចក្ខន្ធ ដឹងពីការរលាស់ចោលនូវបញ្ចក្ខន្ធ រមែងមិនលិចចុះក្នុងទុក្ខឡើយ ។

# ដូចក្មេងមិនចូលសាលារៀន

ពិតមែនតែអ្វីៗនោះមិនគាប់ចិត្តយើង ប៉ុន្តែយើងត្រូវឆាប់មានស្មារតីរលឹកដឹងថា អ្វីៗនោះសុទ្ធតែជាសភាវៈយ៉ាងត្រឹមត្រូវ ក្នុងការកើតឡើង គឺត្រឹមត្រូវតាមបច្ច័យ មិនថាកុសល អកុសល ឬអព្យាក្រឹតឡើយ ។ ការដែលចេះតែចង់ឲ្យអ្វីៗផ្គាប់ចិត្តយើង វាជារឿងក្មេងៗទេ ពោលគឺក្មេងខ្ញីបញ្ញា កាលបើអ្វីៗជាបរមត្ថសុទ្ធតែ

ត្រឹមត្រូវ ម៉េចក៏មិនព្យាយាមសិក្សាចូលទៅដឹងការពិត អប់រំបញ្ញាទទួលយករសនៃសច្ចធម៌ ស្ងប់ចិត្តរលត់តណ្ហា ការដែលចង់ឲ្យអ្វីៗត្រូវតាមចំណង់ គឺចង់ផ្គាប់កិលេសខ្លួនឯងតែប៉ុណ្ណោះ ដូចក្មេងដែលមិនចូលសាលារៀនអ៊ីចឹងឯង ។

## បៀតបៀនចិត្តខ្លួនឯង

ដឹងថាខ្លួនឯងកើតទុក្ខសោកសៅមកពីអ្វីទេ ? មកពីហួងហែងរបស់មិនទៀងថាជារបស់ខ្លួនឯង ។ តាមពិត ការមិនទៀងនៃសង្ខារធម៌ជាអារម្មណ៍នៃវិបស្សនាល្អណាស់ ប៉ុន្តែព្រោះហេតុតែការមិនយល់ ទើបបៀតបៀនចិត្តខ្លួនឯង ។

## មានសេចក្ដីស្ងប់ជាទីពឹង

នៅពេលណា ដែលយើងសម្រេចបាននូវសេចក្ដីសុខស្ងប់ខាងក្នុងខ្លួនយើង នៅពេលនោះ គឺយើងមិនបានឲ្យសេចក្ដីសំខាន់

ចំពោះកាមសុខ ដោយការខំប្រឹងប្រែងស្វែងរកយកមកសេពសោយនោះឡើយ ទាំងសេចក្ដីទុក្ខដែលកើតមកពីការពឹងពាក់អ្នកដទៃរបស់ដទៃ ហើយមិនបានដូចចិត្តនោះ ក៏ថយចុះទៅដែរ នេះចូលក្នុងបទថា មានខ្លួនឯងជាទីពឹង ។

## មានទ្រព្យហើយមិនឲ្យទានព្រោះមោហៈ

មានទ្រព្យសម្បត្តិជាទីពេញចិត្តហើយ មិនឲ្យទាន ព្រោះហេតុមិនដឹងថា សត្វលោកប្រព្រឹត្តទៅតាមកម្ម ។ បានទ្រព្យហើយធ្វើនូវការសន្សំទ្រព្យនោះៗដោយការជាប់ជំពាក់ រឹងរឹតតែប្រាថ្នានូវវត្ថុកាមគុណឡើងទៀត ។ មិនមានអ្នកណាអស់កិលេស ព្រោះមានមាសប្រាក់ច្រើននោះឡើយ ហើយក៏មិនមានអ្នកណាអស់ទុក្ខព្រោះនៅមានកិលេសនោះដែរ ។

# បានជួបព្រះធម៌ហើយ នៅជាថាអត់ពេល

បានជួបព្រះពុទ្ធដីកាហើយ មិនស្តាប់ មិនរៀនឲ្យបានចេះដឹង ត្រូវចំណាយពេលវេលាដើម្បីនេះ ដើម្បីនោះ តើនេះនោះហ្នឹងក្រណាស់ទៅឬក្នុងវដ្តសង្សារ កាលបានមកហើយឲ្យយើងអស់កិលេសដែរទេ សំខាន់ជាងព្រះពុទ្ធដីកាទៅទៀតឬ ?

# គ្រាន់តែមិនសូវកើតទុក្ខ ប៉ុណ្ណឹងល្អហើយ

មនុស្សយើង តែកាលណាខ្លាចទុក្ខទាំងដែលមិនស្គាល់ទុក្ខ ( ទុក្ខេ អញ្ញាណំ ) រមែងប្រាថ្នាសេចក្តីសុខដោយតណ្ហា ពោលគឺខ្លាចទុក្ខ ប្រាថ្នាសុខ ប៉ុន្តែសាងហេតុនៃសេចក្តីទុក្ខឲ្យខ្លួនឯង ព្រោះអវិជ្ជាមិនដឹងក្នុងអរិយសច្ច ។ តាមពិត មនុស្សយើងសព្វថ្ងៃនេះគ្រាន់តែមិនសូវកើតទុក្ខប៉ុណ្ណឹងប្រសើរណាស់ហើយ មិនចាំបាច់បានសុខអ្វីពីរបស់ក្នុងលោកនេះច្រើនពេកទៅនោះទេ ព្រោះថា សូម្បីតែព្រះនិព្វានដែលជាបរមសុខ ក៏ព្រោះទុក្ខមិនកើតឡើងហ្នឹងឯង ។

## ត្រូវចេះពិចារណាកាន់យកប្រយោជន៍

ព្រោះហេតុតែឆ្ងាញ់អាហារនៅក្នុងមាត់ ទើបគិតរកឆ្ងាញ់បរិភោគបន្តទៀត ដោយមិនបានពិចារណាឲ្យនៅត្រឹមជាអាហារ-ប្បច្ច័យប៉ុណ្ណោះ ។ មនុស្សយើង ស្ទុះទៅតាមចំណង់គឺតណ្ហា មិនបានអប់រំបញ្ញាពិចារណារកឲ្យឃើញនូវប្រយោជន៍នៃបច្ច័យ ៤ ដែលខ្លួនឯងមានសម្រាប់រស់នៅឡើយ របៀបដូចរសឆ្ងាញ់នៅក្នុងមាត់វាបោកឲ្យមនុស្សយើងស្ទុះស្ទារត់រករហូតក្នុងជីវិត ដែលវាគ្រាន់តែកន្លងផុតអណ្ដាតប៉ុណ្ណោះ ក៏អស់ឆ្ងាញ់ទៅហើយនោះ ។

## ត្រូវការតិចដូចកែវតូច

ទឹកបន្តិចបន្តួចក៏អាចចាក់ពេញក្នុងកែវបាន ប៉ុន្តែទឹកប្រៃនៃមហាសមុទ្រច្រើនប៉ុនណាក៏ដោយ ក៏មិនអាចញ៉ាំងមហាសមុទ្រឲ្យពេញបានឡើយ យ៉ាងណាមិញ ការកំណត់ដឹងប្រយោជន៍នៃអ្វីៗដែលបរិភោគប្រើប្រាស់ វាធ្វើឲ្យជីវិតដែលប្រកបដោយចិត្តវិញ្ញាណនេះនៅសល់សេចក្ដីត្រូវការតូចដូចកែវទឹក ងាយនឹងចាក់ទឹកឲ្យពេញ

ណាស់ មិនទាំងអស់ទឹកមួយកូនដបផង ។

## សំខាន់នៅត្រង់ចិត្តស្ងប់

វត្ថុប្រើប្រាស់ មិនមែនថាថ្លៃណាស់ហើយ ល្អណាស់ទៅនោះទេ សីលទើបល្អពិតៗ ល្អណាស់ ។

ម្ហូបអាហារ ក៏មិនមែនថាឆ្ងាញ់ណាស់ហើយ មានប្រយោជន៍ណាស់ទៅនោះដែរ ប្រយោជន៍សំខាន់គឺចិត្តស្ងប់ទុក្ខកង្វល់ មិនរវើរវាយ ធ្វើអ្វីៗដែលល្អៗ មានមេត្តា ចេះអត់ធន់ ឲ្យអភ័យ មិនប្រទូសរ៉ាយអ្នកដទៃ និងចេះគិតឲ្យបានសុខ ។

ទ្រព្យសម្បត្តិ ក៏ដូចគ្នា មិនមែនថាមានច្រើនណាស់ហើយបានសេចក្តីសុខណាស់នោះទេ សម្បត្តិបញ្ញាឃើញអ្វីៗតាមសេចក្តីពិត លះបង់នូវតណ្ហាជាហេតុនៃទុក្ខ ទើបបានសុខពិតប្រាកដ ។

ជីវិតនេះ មិនចាំបាច់ទាល់តែមានរបស់ថ្លៃៗ បរិភោគឆ្ងាញ់ៗ និងមានមាសប្រាក់ច្រើនៗ ទើបបានសេចក្តីសុខនោះឡើយ សំខាន់គឺស្ងប់ចិត្ត ជីវិតរមែងបានសុខ ។

# ល្អហើយមានប្រយោជន៍ ទើបនាំសុខពិត

របស់ថ្លៃណាស់មិនច្បាស់ថាល្អ គុណធម៌បវរល្អថ្លៃក្រៃលែង
មានសីលជាគ្រឹះមិនរើសចាស់ក្មេង ល្អដោយខ្លួនឯងមិនមែនសន្មតិ ។
អាហារឆ្ងាញ់ណាស់មិនច្បាស់ប្រយោជន៍ កាមនាំហិនហោចខូចកេរ្តិ៍ប្រាកដ
សមាធិស្ងប់ចិត្តជីវិតហ្មត់ចត់ ប្រយោជន៍ប្រាកដកំណត់អារម្មណ៍។
មានប្រាក់ច្រើនណាស់មិនច្បាស់ថាសុខ ប្រាក់ក្លាយជាគុកការងារបង្ខំ
ប្រាក់នាំប្រព្រឹត្តទុច្ចរិតលាយឡំ ប្រាក់មិនអាចនាំឲ្យចំសុខពិត ។
រកខ្លួនឯងផងទើបឆ្លងផុតកម្ម កំណត់ខន្ធប្រាំប្រចាំជីវិត
ពន្លឺបញ្ញាប្រហារងងឹត អនត្តាពិតថយចិត្តប្រាថ្នា ។
ដូចកែវតូចមួយមិនព្រួយទឹកពេញ ទ្រព្យតិចម្តេចមិញពេញល្មមប្រើការ
ទ្រព្យច្រើនតែខ្វះកន្លះតណ្ហា ប្រៀបដូចជលសាខ្វះការពេញលេញ។
មិនសូវមានទុក្ខជាសុខទៅហើយ ក្នុងចិត្តរហើយស្បើយពីម្នោម្នេញ
ដើរផ្លូវនិព្វានមិនមានវិលវិញ និព្វានសុខពេញចេញចាកទុក្ខា ៕

ដោយ **ប.ស.ឧ.**

# ការងារសំខាន់របស់មនុស្សគឺអប់រំចិត្ត

ពិតមែនតែការដាច់អស់កិលេសពីសន្តាន មិនមែនជាការងាយ ប៉ុន្តែការហ្វឹកហាត់អប់រំចិត្ត ពិតជាអាចប្រព្រឹត្តទៅបាន បើមិនមានការអប់រំចិត្តទេ ក៏មិនមានឈ្មោះថាមនុស្សដែរ ម្យ៉ាងទៀត ការងារសំខាន់របស់មនុស្សដែលកើតមក បើមិននៅត្រង់អប់រំចិត្តទេ តើសំខាន់ជាងសត្វតិរច្ឆានត្រង់ណាទៅ នៅត្រង់ស៊ីឆ្ងាញ់ ដេកស្រួល មានកិត្តិយសហ្នឹងឬ ? ត្រង់នេះ ជាចំណុចនៃការចម្រើនកិលេសរបស់មនុស្សទេតើ បើមិនអប់រំចិត្តទេ មនុស្សនឹងធ្លាក់ចុះទៅក្នុងការធ្វើបាបដ៏ខ្លាំង ដែលមានសភាពនៃចិត្តជាសត្វនរក ឬសត្វតិរច្ឆាន ។

# ការពិតនៅតែជាការពិត

ខ្យល់ដូរទិសដៅ ក្តៅហើយត្រជាក់ ភ្លៀងធ្លាក់ស្មៅដុះ រដូវកាលដូរផ្លាស់ ចិត្តមនុស្សមិនទៀង ... មានតែម្យ៉ាងគត់ដែលមិនធ្លាប់ប្រែប្រួលគឺការពិត ។ ការពិត មិនប្រែប្រួលក្លាយទៅជាមិនពិត

វិញនោះឡើយ ។

## របស់ក្នុងលោកសុទ្ធៗ

ជីវិតមួយ ដៃពីរ កាន់អ្វីច្រើនម្ល៉េះហ្ន៎ ! កើតមកដៃទទេ ទោះជាខំចាប់កាន់អ្វីៗពេញដៃក៏ដោយ ស្លាប់ទៅនៅតែដៃទទេ ចំណែកអ្នកដែលស្រឡាញ់យើងស្មើរលេប ក៏ព្រមយកសាកសព យើងទៅដុតចោលដែរ ។ តាមពិត នៅមិនទាន់ស្លាប់ក៏ដោយ ក៏មិនមានអ្វីជាយើង ជារបស់យើងដែរ អ្វីៗគ្រាន់តែជាអារម្មណ៍របស់ចិត្តប៉ុណ្ណោះ ដែលចិត្តនេះកើតរលត់បន្តគ្នា នេះឯងដែលជាការរស់នៅរាល់ថ្ងៃនោះ ។

## គួរតាំងចិត្តឲ្យអ្នកដទៃបានសុខ

ដឹងថា ពាក្យសម្ដីយើងមុតជាងដាវលំពែងទេ កាលបើយើងនិយាយដោយប្រាសចាកមេត្តាចិត្ត និយាយដោយអត់គិតពិចារណា ។ ជីវិតមានតម្លៃ នៅត្រង់ធ្វើអ្វី និយាយអ្វី ឲ្យអ្នកដទៃបាន

ប្រយោជន៍សុខ ។ បើអ្នកដទៃធ្វើអ្វីខុស យើងមិនអាចឲ្យអភ័យបានទេ យើងក៏មិនមែនជាមនុស្សសំខាន់អ្វីជាងគេក្នុងលោកនេះដែរ ជាមនុស្សកេងយកគ្រាន់បើខ្លួនឯង ចាំតែមានគេខុសនឹងអាលប្រកាសទោសគេនោះក្តែងៗ ខ្វះសមត្ថភាពសាងសេចក្តីល្អខ្លួនឯង ។

## ឱកាសល្អណាស់ ប្រញាប់សន្សំបុណ្យ

កុំរវល់តែគិតថា ខ្ញុំត្រូវបានអ្វី អ្នកនេះ អ្នកនោះ ត្រូវឲ្យអ្វីដល់ខ្ញុំ ម៉េចបានឲ្យតែអ្នកដទៃ ម៉េចបានចោលខ្ញុំ ... ។ ត្រូវចេះគិតថា ខ្ញុំនឹងឲ្យអ្វីដល់អ្នកដទៃ ប្រគេនអ្វីដើម្បីទំនុកបម្រុងព្រះសង្ឃ ខ្ញុំជ្រះថ្លានឹងបុណ្យដែលអ្នកដទៃបានបំពេញហើយ ។ ចិត្តលោភៈ ដូចជាអ្នកក្រ អ្នកសូមទាន ចំណែកចិត្តឲ្យទាន ដូចជាអ្នកមានទ្រព្យច្រើន សម្បូណ៌សប្បាយ ជាចិត្តប្រសើរខ្ពស់ មានភាពជាឥស្សរៈ ។ អ្នកឲ្យទានមានសីលជាដើម ទើបឈ្មោះថា ជាអ្នកស្រឡាញ់ខ្លួនបានត្រឹមត្រូវ ព្រោះបានតម្កល់ខ្លួនគឺចិត្តឲ្យប្រពៃ មិនបណ្តោយឲ្យខ្លួនឯងជាខ្ញុំបម្រើរបស់បាបឡើយ ។

## មានសម្បត្តិ ៣ យ៉ាង

១- មានសម្បត្តិខ្លឹមសារ គឺមានទានសីលភាវនា ត្រូវចេះគិតថា នេះជាសម្បត្តិរបស់ចិត្ត គឺចិត្តសម្បូណ៌សប្បាយ ចិត្តស្អាត និងជាចិត្តដែលមានសុខភាពល្អ ។

២- មានសម្បត្តិជាទីពឹងដ៏ក្រៃលែង គឺមានបញ្ញា ព្រោះបញ្ញាបានចូលដល់សច្ចធម៌ ជាធម៌ពិត មិនប្រែប្រួល មិនក្លាយទៅជាមិនពិតវិញនោះឡើយ នេះហើយឈ្មោះថា បានឃើញធម៌ បានជួបធម៌ទាំងដែលជាទីបញ្ចប់នៃតណ្ហាទៀតផង ។

៣- មានសម្បត្តិដែលជារង្វាន់ គឺនិព្វានសម្បត្តិ ដែលជាលទ្ធផលនៃការប្រឹងប្រែងព្យាយាមត្រូវ ។

## បច្ច័យ ៤ របស់ចិត្ត

១- **ទាន** ជាបិណ្ឌបាតប្បច្ច័យរបស់ចិត្ត ចិត្តបានឆ្អែតមានបីតិ មានចាគានុស្សតិ សុខស្ងប់ ភ្លឺស្វាង ... ។

២- **សីល** ជាចីវរប្បច្ច័យរបស់ចិត្ត ចិត្តបានកក់ក្ដៅ ខ្ពង់ខ្ពស់

ស្អាតល្អ មានសីលានុស្សតិ សុខស្ងប់ ភ្លឺស្វាង ... ។

៣- **សមថៈ** ជាសេនាសនប្បច្ច័យរបស់ចិត្ត ចិត្តបានម្លប់ត្រជាក់ នឹងធឹង ប្រាសចាកកិលេសជាគ្រឿងរួបរឹត សុខស្ងប់ភ្លឺស្វាង ... ។

៤- **វិបស្សនា** ជាគិលានភេសជ្ជប្បច្ច័យរបស់ចិត្ត ចិត្តបានជាសះស្បើយ មានសុខភាពល្អ ប្រាសចាករោគ ប្រាសចាកទោស សុខស្ងប់ ភ្លឺស្វាង ... ។

## សន្តោស ធ្វើឲ្យមានទ្រព្យ ចេះគ្រប់

យើងកើតមកមិនមែនជាអ្នកមានទ្រព្យសម្បត្តិច្រើន ប៉ុន្តែយើងចេះពេញចិត្តនឹងសម្បត្តិដែលយើងមាន នេះជាគុណធម៌គឺសេចក្តីសន្តោស ដែលមានអានុភាពធ្វើសម្បត្តិទ្រព្យដែលខ្លួនមាននោះ ឲ្យជាសម្បត្តិគ្រប់គ្រាន់ នេះអស្ចារ្យណាស់ ព្រោះថា សូម្បីភ្នំមាសពីរ ក៏មិនអាចធ្វើឲ្យបុរសម្នាក់ដែលមិនមានធម៌សន្តោសនោះគ្រប់គ្រាន់ទៅបានឡើយ ។

# ខ្លួនយើងសំខាន់សម្រាប់ខ្លួនឯងណាស់

កុំអន់ចិត្តនឹងខ្លួនឯងព្រោះតែរឿងក្រទ្រព្យ ឬព្រោះតែមិនបានដូចអ្នកដទៃ ... តាមពិត ខ្លួនឯងគឺជាការពិតដ៏សំខាន់ ដែលនាំមកនូវការសិក្សារំលត់កិលេសរបស់ខ្លួន ( សិក្ខេ និព្វានមគ្គនោ ) ដូច្នេះខ្លួនយើងនេះ សំខាន់សម្រាប់ខ្លួនឯងណាស់ កាលណាបើយើងរកការពិតក្នុងខ្លួនឯងឃើញហើយ យើងក៏លែងត្រូវការអ្វីអំពីលោកនេះដែរ ព្រោះមានការរំលត់នូវកិលេស ដែលជាទីពឹងដ៏ឧត្តម ។

# ដោយបរមត្ថ សុទ្ធតែត្រឹមត្រូវ

មនុស្សយើងរមែងញាប់ញ័រ ឬឈឺចាប់នឹងភាពអយុត្តិធម៌ក្នុងរឿងផ្សេងៗ លុះដល់ ពេលណា ដែលបញ្ញារកភាពយុត្តិធម៌ដោយបរមត្ថឃើញ ពេលនោះ យើងក៏អស់បញ្ហា ព្រោះថាដោយបរមត្ថអ្វីៗសុទ្ធតែមានហេតុត្រឹមត្រូវទាំងអស់ ឃើញហើយស្ងប់ចិត្តយល់ព្រមតាមសេចក្ដីពិត ។

# រស់នៅដើម្បីអ្វី

បើយើងរស់នៅឧទ្ទិសជីវិតដើម្បីតែលាភសក្ការៈ យើងនឹងមានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន បើរស់នៅដើម្បីតែការគ្រប់គ្រង ដើម្បីយស ឋានៈបុណ្យស័ក្តិ យើងនឹងមានការហត់-នឿយច្រើន បើរស់នៅដើម្បីតែសេចក្ដីសរសើរ ដើម្បីតែការលើក-តម្កើង យើងនឹងញាប់ញ័រដូចត្រីនៅក្នុងទីដែលមានទឹកតិច បើរស់នៅដើម្បីតែសេចក្ដីស្រឡាញ់ សេពសោយកាមសុខ រីករាយក្នុងបញ្ចកាមគុណ យើងនឹងជួបប្រទះនូវការឈឺចាប់គំនរទុក្ខធំ ប៉ុន្តែបើយើងរស់នៅដើម្បីថែរក្សាសេចក្ដីល្អ កសាងចេតិយនៃជីវិត យើងនឹងបាននូវការសប្បាយចិត្ត ចម្រើនទៅដោយសេចក្ដីសុខ ។

# ចេតិយនៃជីវិត

មានការមិនធ្វើបាបទាំងពួង គឺបុណ្យចាក់គ្រឹះព្រះចេតិយ ។

ដល់ព្រមដោយការបំពេញកុសល គឺបុណ្យសាងតួព្រះចេតិយ ។

កិរិយាសម្អាតចិត្តរបស់ខ្លួនឲ្យផូរផង់ គឺបុណ្យលើកកំពូលព្រះចេតិយ ។

តម្កល់ព្រះនិព្វានធាតុក្នុងព្រះចេតិយ គឺព្រះនិព្វានជាអារម្មណាធិបតីនៃផលសមាបត្តិ ។

## សាលារៀនថ្នាក់បរិញ្ញា

អ្វីៗដែលកើតមានក្នុងជីវិត ជាបរមត្ថ សុទ្ធតែជាមេរៀនថ្នាក់បរិញ្ញាទាំងអស់ ត្រូវសិក្សាកំណត់ដឹង ចាក់ធ្លុះនូវការពិត សម្រេចនូវបរិញ្ញា មានការដឹងនូវនាមរូបអាស្រ័យបច្ច័យកើតឡើងជាដើម ។ ត្រូវយល់ថា ជីវិតនេះជាសាលារៀន មិនមែនជាផ្ទះសម្រាប់យើងប្រកាន់ហួងហែងទេ បើចង់ល្ងង់ ចង់សោយសោក ហួងហែងទៀតទៅ ព្រោះពួកជនរមែងសោកសៅ ដោយសារការហួងហែងរបស់មិនទៀង ថាជារបស់យើងហ្នឹងឯង ។

# ៤-មហាមាលុង្ក្យោវាទសូត្រ

នៅនាវត្តជេតពន សម័យមួយនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរភិក្ខុទាំងឡាយ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយបានចាំនូវឱរម្ភាគិយសំយោជនៈ ( គឺសំយោជនៈជាចំណែកខាងជាន់ទាប មានអំណាចចងសត្វឲ្យកើតនៅក្នុងកាមភព ) ៥ ដែលតថាគតបានសម្ដែងហើយដែរឬ ។

ក្នុងកាលនោះ ព្រះមាលុង្ក្យបុត្ត បានឆ្លើយអំពីសំយោជនៈខាងក្រោម ៥ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស កាមឆន្ទៈ និងព្យាបាទ ក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រះថេរៈពុំបានធ្វើឲ្យត្រូវនឹងព្រះហឫទ័យនៃព្រះដ៏មានព្រះភាគឡើយ ទោះជាបានឆ្លើយនូវឈ្មោះនៃសំយោជនៈខាងក្រោម ៥ នេះ ត្រូវហើយក៏ដោយព្រោះព្រះថេរៈប្រកបដោយកិលេស ប្រកាន់លទ្ធិតាមទិដ្ឋិរបស់ខ្លួនឈ្មោះថាមិនឆ្លាត ទាំងពោលមួលបង្កាច់ព្រះធម៌ទេសនា តាមដែលព្រះដ៏មានព្រះភាគ ទ្រង់ផ្ដើមឡើងដោយព្រះអង្គឯង សម្ដែងដល់ភិក្ខុសង្ឃ ។

សេចក្តីនៃសំយោជនៈខាងក្រោម ៥ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងដល់អនុស័យ ព្រោះហេតុដូច្នេះទើបព្រះអង្គទ្រង់លើកអំពីក្មេងតូចដែលនៅទន់ខ្ចី ទោះបីជាទារកតូចនៅដេកផ្ងារ មិនមានទិដ្ឋិវិចិកិច្ឆា មិនមានសីល មិនមានកាមច្ឆន្ទៈព្យាបាទក៏ដោយ ប៉ុន្តែមានអនុស័យគឺសំយោជនៈដែលនៅមិនទាន់បានលះដោយអរិយមគ្គហ្នឹងឯង ។ បន្ទាប់អំពីព្រះដ៏មានព្រះភាគ ទ្រង់លើកទោសព្រះមាលុង្ក្យបុត្តហើយ ព្រះអានន្ទត្ថេរបានអារាធនាព្រះពុទ្ធអង្គ សូមទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីបុថុជ្ជនដែលមិនបានលះបង់នូវសំយោជនៈនោះៗ ហើយព្រះអង្គទ្រង់ត្រាស់អំពីព្រះអរិយសាវ័ក ដែលជាបុគ្គលបានលះបង់នូវសំយោជនៈព្រមទាំងអនុស័យ ។

ជាបន្ត ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីមគ្គប្បដិបទា ប្រព្រឹត្តទៅដើម្បីលះបង់នូវសំយោជនៈនោះៗ ដូចជាការបកយកសំបកឈើចេញ ចាំងយកស្រាយចេញទៀត រួចហើយបានកាត់យកខ្លឹម ម្យ៉ាងទៀត ប្រៀបដូចអ្នកមានកម្លាំងខ្លាំងហែលកាត់ទន្លេគង្គាដែលមានទឹកពេញ បានដល់ត្រើយនាយដោយសួស្តី ដូច្នោះឯង គឺព្រះអង្គទ្រង់ត្រាស់បដិបទាជាលោកិយ និងលោកុត្តរ ក្នុងការលះនូវសំយោជនៈ ។ ឈានសមាបត្តិដូចការ

បកសំបកឈើចេញ វិបស្សនា ដូចជាការចាំងយកស្រាយឈើចេញទៀត រីឯអរិយមគ្គដូចជាការកាត់យកខ្លឹម ចំណែកការប្រៀបទៅនឹងអ្នកមានកម្លាំងខ្លាំង ហែលទឹកឆ្លងទៅត្រើយនាយនៃទន្លេគង្គា បានដល់ចិត្តដែលស្ទុះទៅ ជ្រះថ្លាមាំទាំ និងរួចផុតដោយសួស្តី ព្រោះអាស្រ័យបានស្តាប់ព្រះធម៌ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងអំពីការរលត់ឧបាទានក្ខន្ធ ៥ ( សក្កាយនិរោធ ) ។

នៅខាងចុងនៃព្រះសូត្រ ព្រះអានន្ទក្រាបទូលសួរព្រះដ៏មាន-ព្រះភាគ អំពីចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ព្រះពុទ្ធអង្គទ្រង់ត្រាស់ឆ្លើយថា ម្នាលអានន្ទ ក្នុងសាសនានេះឯង តថាគតពោលថា ពួកភិក្ខុទាំងនោះ មានឥន្ទ្រិយផ្សេងៗគ្នា ។

សូមអនុមោទនា !

## រស់នៅដើម្បីអ្វី

បើខំប្រឹងរស់ព្រោះតែប្រាក់ ជាប់គុកច្រវាក់ព្រោះប្រាក់ដែរ
ទុក្ខកាយទុក្ខចិត្តឥតមានល្ហែ ក៏ព្រោះប្រាក់ដែរស្រែឬក្រុង ។
បើខំប្រឹងរស់ព្រោះយសស័ក្តិ ព្រោះតែឋានៈប្រាក់បម្រុង

គ្រប់គ្រងហួងហែងចំបែងក្នុង មានដើមមានចុងមានប្រចណ្ឌ ។
បើខំប្រឹងរស់ព្រោះសរសើរ ជណ្ដើរកេរ្តិ៍ឈ្មោះឈ្លោះប្រកាន់
ពូកែខាងខឹងមិនដឹងខន្ធ ឯងអញប្រកាន់កំណាន់ទុក្ខ ។
បើខំប្រឹងរស់ព្រោះស្នេហា សោយសុខកាមាជាប្រមុខ
ប្រព្រឹត្តកាមេគេដាក់គុក មានរឿងកើតទុក្ខឈឺចុកចាប់ ។
បើខំប្រឹងរស់ព្រោះខ្លួនឯង ព្រះធម៌សម្ដែងកោតក្រែងស្ដាប់
បញ្ញានាំផ្លូវត្រូវប្រញាប់ សាងល្អឲ្យឆាប់ក្ដាប់ឱកាស ។
លាភយសសរសើរគ្រាន់បើសុខ លោកធម៌ស្មាញស្មុគប្រែក្រឡាស់
ប្រែប្រួលមិនទៀងតែងព្រាត់ប្រាស ពឹងខ្លួនឯងច្បាស់ក្រាស់បារមី ។
សូមពុទ្ធបរិស័ទប្រព្រឹត្តធម៌ ចរិយាបវរល្អនិស្ស័យ
សិក្សាបដិបត្តិហាត់រាល់ថ្ងៃ បំពេញបារមីនិព្វានហោង ៕

ដោយ **ច.ស.ទ.**

## ប្រយោជន៍របស់ឆត្រ

គេមិនមែនធ្វើឆត្រដើម្បីកុំឲ្យភ្លៀង ឬកុំឲ្យមានថ្ងៃក្ដៅនោះទេ គឺគេធ្វើដើម្បីកាន់បាំងកុំឲ្យភ្លៀងទទឹក ឬកុំឲ្យត្រូវក្ដៅ យ៉ាងណា ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌ ។ យើងមិនអាចហាមឃាត់អារម្មណ៍

( អ្វីណា ដែលចិត្តដឹង អ្វីនោះ ហៅថាអារម្មណ៍ ) ផ្សេងៗ ដូចជា ជរា ព្យាធិ ទុក្ខវេទនា ការព្រាត់ប្រាស អត់លាភ អត់យស ពាក្យ រិះគន់និន្ទា ជាដើមបានមែន ប៉ុន្តែយើងមានការប្រព្រឹត្តធម៌ដើម្បីរក្សា ចិត្ត មិនឲ្យចិត្តកើតទុក្ខ ដូចជាមិនឲ្យរូបកាយទទឹកភ្លៀង ឬមិនឲ្យ ក្តៅព្រោះបានបាំងឆត្រ ដូច្នោះឯង ។

## ជីវិតមានតម្លៃព្រោះបានប្រព្រឹត្តធម៌

ជីវិតមនុស្សមានតម្លៃនៅត្រង់បានធ្វើប្រយោជន៍ ទាំង ប្រយោជន៍ខ្លួនឯង ទាំងប្រយោជន៍អ្នកដទៃ ។ ប្រយោជន៍ខ្លួនឯងគឺ អប់រំចិត្តឲ្យមានចំណេះនិងគុណធម៌ ប្រយោជន៍អ្នកដទៃគឺភាពជា ស្រែបុណ្យ ភាពជាកល្យាណមិត្ត មានអាមិសទាន អភយទាន និង ធម្មទាន ។ ជីវិតមានតម្លៃល្អដូចដើមផ្កា បើគេដាក់ជីឲ្យ រឹតតែមាន ផ្កាល្អ មិនក្លាយទៅជាជី ទៅជាលាមក ទៅជាសំរាម តាមជីដែល គេដាក់នោះឡើយ យ៉ាងណាមិញ មនុស្សមានតម្លៃគឺថ្លៃទៅដោយ គុណធម៌របស់ខ្លួន ហើយក៏មិនថោកទៅតាមអ្វីដែលថោកនៅជុំវិញ ខ្លួននោះដែរ បែរទៅជាបានបទសិក្សា ការពារខ្លួន រក្សាខ្លួន យក

ឈ្នះកិលេសខ្លួនឯងវិញ ។

## ជីវិតយើងជាការពិតរបស់យើង

យើងមិនមានសិទ្ធិជ្រើសរើសកំណើត កើតជាកូនអ្នកមាន ប៉ុន្តែយើងមានសិទ្ធិជ្រើសរើសធ្វើជាមនុស្សល្អ ។ ជីវិតយើងមិនដូចគេ តែជីវិតយើងជាការពិតរបស់យើង មិនក្លែងក្លាយ យុត្តិធម៌ត្រឹមត្រូវតាមបរមត្ថ មានកាយ វេទនា ចិត្ត និងពួកធម៌ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ឲ្យដឹង ពោលគឺជីវិតរបស់យើងហ្នឹងឯង ដែលជាអារម្មណ៍នៃព្រះកម្មដ្ឋានសម្រាប់ខ្លួនឯងអប់រំចិត្ត ចម្រើនបញ្ញា ។ យើងសប្បាយចិត្ត ព្រោះបានរស់នៅជាមួយនឹងការពិតដោយបញ្ញា ។

## អង្គ ៤ សម្រេចបាននូវបញ្ញា

**សុស្សូសំ លភតេ បញ្ញំ** ស្តាប់ដោយល្អ គឺតាំងចិត្តស្តាប់ឲ្យយល់ បើមិនសូវយល់ ត្រូវសាកសួរឲ្យបានយល់ច្បាស់ នេះគ្រាន់តែជាអង្គ ១ ប៉ុណ្ណោះ ត្រូវប្រកបដោយអង្គ ៣ ទៀត ទើបសម្រេច

បាននូវបញ្ញា ។ អង្គ ៣ ទៀតគឺ អង្គទី ១ មានសទ្ធាជឿធម៌ព្រះអរហន្ត បានដល់ពោធិបក្ខិយធម៌ ថាជាធម៌ឲ្យបានសម្រេចដល់នូវព្រះនិព្វាន អង្គទី ២ គឺសេចក្ដីមិនប្រមាទ បានដល់មិនប្រាសចាកសតិក្នុងការស្ដាប់ធម៌ អង្គទី ៣ គឺពិចារណាអត្ថ បានដល់ការពិចារណាចាក់ធ្លុះអត្ថសេចក្ដីនៃព្រះធម៌ដែលកំពុងស្ដាប់ ឬព្រះធម៌ដែលបានទ្រទ្រង់ចាំទុកមកនោះ ។

## ឥស្សរភាពលើកិលេសខ្លួនឯង

រឹតតែហួងហែង រឹតតែកើតទុក្ខ ការព្រមលះបង់ ព្រមឲ្យអ្វីៗទៅតាមធម្មតាធម៌ នេះជាវិធីដោះទុក្ខដ៏ប្រសើរ ។ អ្វីៗក្នុងលោកសម្រាប់យល់ មិនមែនសម្រាប់ហួងហែងទេ សេចក្ដីទុក្ខក្នុងចិត្តរមែងថយចុះ ព្រោះបានដឹងថា ជីវិតនេះមិនមែនមានតែសេចក្ដីសុខនោះឡើយ ។ ព្យាយាមរស់នៅជាមួយនឹងសេចក្ដីល្អ ធ្វើល្អដល់អ្នកដទៃដោយមិនទាមទារផលតបស្នង នេះជាឥស្សរភាពនៃជីវិត ។ ភាពជាឥស្សរៈលើកិលេសរបស់ខ្លួន ទើបជាឥស្សរភាព ប្រព្រឹត្តទៅជាសុខពិតប្រាកដ ទាំងដែលជាឈ្មោះនៃព្រះនិព្វានទៀតផង ។

## រស់នៅជាមួយនឹងបញ្ញា បានសុខ

ជនទាំងឡាយ រមែងសោកសៅព្រោះហេតុហួងហែងរបស់មិនទៀង ថាជារបស់យើង ចំណែកអ្នកមានបញ្ញា រមែងបាននូវសេចក្តីសុខស្ងប់ជាមួយនឹងការមិនទៀងនោះឯង ព្រោះបានដឹងថានេះជាការពិតរបស់សង្ខារធម៌ ។ ជនទាំងឡាយ តែងសោកសៅទៅរកអ្នកដែលបែកឃ្លាត ព្រាត់ប្រាសទៅ ចំណែកអ្នកមានបញ្ញា រមែងមានសេចក្តីសុខជាមួយនឹងអ្នកដែលរស់នៅជុំវិញខ្លួន តាមរយៈនៃមេត្តាធម៌ និងគុណធម៌ផ្សេងៗទៀត ។ ជនទាំងឡាយ តែងសោកសៅទៅរករបស់ដែលបាត់បង់ ចំណែកអ្នកមានបញ្ញា រមែងរស់នៅជាសុខជាមួយនឹងរបស់ដែលនៅមាន ប្រើប្រាស់ឲ្យជាប្រយោជន៍ ។

## ចង់បានសុខពេកបែរនៅជាកើតទុក្ខ

មនុស្សយើងសព្វថ្ងៃអាយុតិច ទាំងខ្លីជាងអាយុក្ខ័យទៀតក៏មានច្រើន មិនមានពេលគ្រប់គ្រាន់ដើម្បីសេចក្តីស្រឡាញ់ ដើម្បី

សេចក្តីលោភលន់ ដើម្បីការខឹងក្រោធនោះឡើយ ដូច្នេះហើយ យើងកុំចេះតែរវល់ចង់បានអ្វីៗ ដែលយើងគិតថាល្អណាស់ ពិសេសណាស់ រហូតដល់ចំណង់នោះធ្វើឲ្យយើងរស់នៅមិនបានសុខក្នុងបច្ចុប្បន្ន មានតែទុក្ខក្តៅក្រហាយឡើយ ដូច្នេះយើងគួររស់នៅឲ្យបានសុខឲ្យហើយជាមួយនឹងរបស់ដែលយើងមាន រួចហើយយើងគប្បីកែខៃរៀបចំ អប់រំហេតុនៃសេចក្តីសុខ ប្រកបដោយការពេញចិត្ត មិនកើតទុក្ខអ្វីឡើយ ព្រោះបានដឹងជាពិសេសថា អ្វីៗជាបរមត្ថសុទ្ធតែត្រឹមត្រូវទៅតាមហេតុ ជាសច្ចធម៌ ។

## មើលឃើញសេចក្តីល្អខ្លួនឯង

មានរឿងមិនសប្បាយចិត្តត្រង់ដែលថា យើងធ្វើល្អប៉ុណ្ណឹងហើយ គេនៅតែមើលយើងមិនឃើញ ។ តាមពិត ឲ្យតែយើងមើលឃើញខ្លួនឯងទៅ ក្រែងតែយើងមើលមិនដឹងសេចក្តីល្អខ្លួនឯងតាមពិតនោះ ទើបយើងមិនសប្បាយចិត្តហ្នឹងឯង ព្រោះមិនមានអ្វីដែលគួរឲ្យរីករាយជាងការមើលឃើញសេចក្តីល្អក្នុងខ្លួនឯងឡើយ ។

# ៥.ភទ្ទាលិសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាព្រះមហា-វិហារជេតពន ក្នុងសម័យកាលនោះ ព្រះពុទ្ធអង្គទ្រង់បញ្ញត្តវិកាល-ភោជនសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទាននូវសិក្ខា ព្រះភទ្ទាលិដ៏-មានអាយុ ក៏ក្រាបទូលនូវសេចក្តីមិនអាចធ្វើតាមបាន ហើយគេច ខ្លួនមិនឲ្យជួបព្រះដ៏មានព្រះភាគ ពេញបីខែគត់ ។

អដ្ឋកថាថា ពីជាតិមុននោះ ព្រះភទ្ទាលិលោកកើតជាសត្វក្អែក ធម្មតាក្អែកទាំងឡាយជាសត្វឃ្លានរឿយៗ គឺឆាប់ឃ្លានហ្នឹងឯង ។ ឧបនិស្ស័យនៃការបរិភោគរឿយៗ នាំឲ្យជាប់ជំពាក់ក្នុងការបរិភោគ រហូតមក ។

បីខែកន្លងទៅ ព្រះដ៏មានព្រះភាគបម្រុងនឹងស្តេចយាងចេញ ទៅកាន់ទីចារិក ព្រះភទ្ទាលិបានពួកភិក្ខុសព្រហ្មចារីរំលឹកដាស់តឿន ក៏បានចូលទៅសូមខមាទោសចំពោះព្រះដ៏មានព្រះភាគ ។ ព្រះពុទ្ធ-អង្គទ្រង់រំលឹកដាស់តឿនដល់ព្រះភទ្ទាលិក្នុងបទជាដើមថា **សម-យោបិ ខោ តេ ភទ្ទាលិ** ម្នាលភទ្ទាលិ សូម្បីគ្រាន់តែហេតុមួយ

ដែលអ្នកគប្បីដឹង ក៏អ្នកមិនបានកំណត់ដឹងឡើយ ។ ហេតុមួយ ឬរឿងមួយនោះគឺ ព្រះដ៏មានព្រះភាគក្តី ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទាំងសមណព្រាហ្មណ៍ខាងក្រៅព្រះពុទ្ធសាសនាក្នុងក្រុង-សាវត្ថីនេះក្តី គង់ដឹងថាអាត្មាអញជាភទ្ទាលិភិក្ខុ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា រឿងមួយនេះឯងដែលគួរដឹង ប៉ុន្តែព្រះភទ្ទាលិបែរទៅជាមិនបានកំណត់ដឹង ។ ព្រះភទ្ទាលិ សូមខមាទោសព្រះដ៏មានព្រះភាគ ជាលើកទី ២ ព្រះពុទ្ធអង្គទ្រង់លើកអំពីព្រះអរិយបុគ្គល ៧ ពួក មានឧភតោភាគវិមុត្តបុគ្គលជាដើម ជាបុគ្គលប្រដៅបានដោយងាយ ទាំងជាបុគ្គលដែលដឹងក្នុងហេតុគួរ ឬមិនគួរទៀតផង មិនមែនចេះតែធ្វើតាមដោយមិនដឹងអ្វីនោះឡើយ ចំណែកអ្នកជាភិក្ខុភទ្ទាលិក្រៅអំពីព្រះអរិយបុគ្គល ៧ ពួកនោះ ហើយប្រដៅបានដោយក្រទៀតផង ។ ព្រះភទ្ទាលិ សូមខមាទោសព្រះដ៏មានព្រះភាគ ជាលើកទីបី ទើបព្រះអង្គទ្រង់ត្រាស់ទទួលនូវការសូមខមាទោសនោះ ហើយប្រកាសសម្តែងអំពីទោសនៃការមិនបានបំពេញក្នុងសិក្ខារបស់ព្រះសាស្តា គឺទោះបីជាទៅនៅក្នុងព្រៃភ្នំទីស្ងាត់យ៉ាងណា ក៏មិនអាចជាក់ច្បាស់នូវគុណវិសេសឡើយ មានតែការតិះដៀលអំពីព្រះសាស្តា អំពីពួកសព្រហ្មចារីដែលជាអ្នកចេះដឹង ទាំងទេវតាក៏តិះដៀល ទាំងខ្លួនឯងក៏តិះដៀលខ្លួនឯងទៀត ។

អដ្ឋកថាថា ទេវតាមិនត្រឹមតែតិះដៀលទេ ថែមទាំងសម្តែងអារម្មណ៍ ដែលគួរឲ្យខ្លាច ធ្វើឲ្យគេចចេញអំពីទីនោះៗទៀតផង ឯការដែល តិះដៀលខ្លួនឯងនោះ គឺកាលដែលភិក្ខុនឹកដល់សីល ហេតុដែល សៅហ្មងក៏បានប្រាកដឡើង ចិត្តក្តៅក្រហាយរាយមាយ មិនសម្រេច នូវកម្មដ្ឋាន ក៏គេចចេញអំពីទីនោះដោយខ្លួនឯង ។

ជាបន្ត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងអំពីប្រយោជន៍ នៃការដែលភិក្ខុធ្វើឲ្យបរិបូណ៌ក្នុងសិក្ខារបស់ព្រះសាស្តា គឺបាននូវ ព្រះកម្មដ្ឋាន សម្រេចឈានរហូតដល់បានសម្រេចនូវវិជ្ជាបី ដល់ថ្នាក់ អស់អាសវក្កិលេស ។

ព្រះភទ្ទាលិបានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគ អំពី ហេតុដែលនាំឲ្យភិក្ខុធ្វើការសង្កត់សង្កិននូវភិក្ខុពួកខ្លះក្នុងសាសនានេះ និងព្រោះហេតុអ្វី ដែលនាំឲ្យពួកភិក្ខុមិនធ្វើការសង្កត់សង្កិននូវភិក្ខុពួក ខ្លះក្នុងសាសនានេះ ។

បទថា **បវយ្ហ បវយ្ហ ការណំ ករោន្តិ** គឺភិក្ខុ ទាំងឡាយ សង្កត់សង្កិនហើយ ធ្វើឲ្យជាហេតុ បានដល់ធ្វើការសង្កត់ នូវទោសសូម្បីមានប្រមាណតិច ទាំងធ្វើញយៗ ។ ពាក្យថា សង្កត់សង្កិនក្នុងបទ **បវយ្ហ បវយ្ហ** នេះ គឺក្នុងអត្ថន័យឃុំ គ្រង មើលថៃ ណែនាំ អប់រំទូន្មាន ប្រៀនប្រដៅ ចំពោះបុគ្គល

ដែលអាចប្រដៅបាន ។ ចំពោះព្រះភទ្ទាលិខ្លួនលោកដោយផ្ទាល់ មិនបានទទួលនូវ **បចយ្ឃា បចយ្ឃា** នេះទេ កន្លងទៅបីខែ អំពីព្រះ-សាស្តាក្តី អំពីព្រះភិក្ខុសង្ឃក្តី ទើបបានជាព្រះភទ្ទាលិ ក្រាបទូលសួរនូវបញ្ហានេះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីពួកភិក្ខុដែលប្រដៅបានដោយក្រ និងពួកភិក្ខុដែលប្រដៅបានដោយងាយជាដើម ។ ព្រះ-អដ្ឋកថាថា ព្រះភទ្ទាលិនេះ ជាភិក្ខុដែលប្រដៅបានដោយក្រ ជាបន្ត ព្រះភទ្ទាលិបានក្រាបទូលសួរព្រះដ៏មានព្រះភាគអំពី ហេតុដូចម្តេចបានជាកាលពីដើម មានសិក្ខាបទតិចល្មម តែពួកភិក្ខុច្រើនអង្គបានតាំងនៅក្នុងព្រះអរហត្ត ប៉ុន្តែឥឡូវនេះ មានសិក្ខាបទច្រើនណាស់ត្រឡប់ទៅជាមានពួកភិក្ខុដែលសម្រេចព្រះអរហត្តតិចអង្គទៅវិញ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ដំណើរនោះយ៉ាងនេះឯង គឺកាលបើសត្វទាំងឡាយ សាបសូន្យ កាលបើព្រះ-សទ្ធម្មអន្តរធាន សិក្ខាបទទាំងឡាយរមែងមានច្រើន ឯពួកភិក្ខុដែលបានឋិតនៅក្នុងព្រះអរហត្តមានតិច ។ ម្នាលភទ្ទាលិ ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់កើតប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្តាក៏មិនទាន់បញ្ញត្តសិក្ខាបទដល់

សាវ័កទាំងឡាយត្រឹមនោះ ។ ម្នាលភទ្ទាលិ លុះតែធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ កើតប្រាកដចំពោះសង្ឃក្នុងសាសនានេះ ក្នុងកាលណា ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ក្នុងកាលនោះ ដើម្បីនឹងការពារនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃ អាសវៈនោះប៉ុណ្ណោះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែង ពួកធម៌ខ្លះដែលជា ទីតាំងឡើងនៃអាសវៈ មានប្រាកដដល់សង្ឃ ៥ យ៉ាងគឺ

១- **សង្ឃោ មហត្តំ បត្តោ ហោតិ** មានភិក្ខុសង្ឃចំនួន ច្រើន ( ទាក់ទងដល់សេនាសនៈ ) ។

២- **លាភគ្គំ បត្តោ ហោតិ** ដល់នូវលាភដ៏ប្រសើរ ។

៣- **យសគ្គំ បត្តោ ហោតិ** ដល់នូវយសដ៏ប្រសើរ ។

៤- **ពាហុសច្ចំ បត្តោ ហោតិ** ដល់នូវភាពជាពហុស្សូត ( សិក្សាមិនល្អ សម្តែងក្រៅធម៌វិន័យថាជាព្រះពុទ្ធដីកា ) ។

៥- **រត្តញ្ញុតំ បត្តោ ហោតិ** ដល់នូវភាពជាអ្នកស្គាល់ រាត្រី ( គឺបួសបានយូរ ចាស់វស្សា ) ។

នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ សម្តែងអំពីភិក្ខុដែលមាននូវអសេក្ខធម៌ប្រកបដោយអង្គ ១០ មាន

សម្មាទិដ្ឋិជាដើមក្នុងអរហត្តផល ប្រៀបទៅនឹងសេះអាជានេយ្យ ដែលគេបង្ហាត់បានល្អហើយ ។

សូមអនុមោទនា !

## មនុស្សខ្សោយគំនិត មាត់ពោលមិនល្អ

មនុស្សខ្សោយគំនិតមាត់ពោលមិនល្អ និយាយភូតភរររករឿងទទេ
អួតចេះខ្លួនឯងមិនក្រែងចេះគេ គេខុសឯងជេរគ្មានទេគុណធម៌ ។
មនុស្សល្ងង់មែនពិតចិត្តអកុសល និយាយចូលដល់រឿងគេមិនល្អ
លុះដល់បានស្ដាប់សារសព្វតបត ថាខ្លួនមិនល្អកររឿងជម្លោះ ។
វេលាជីវិតពិតមិនគ្រប់ក្រោធ ពោលពាក្យចាក់ដោតខឹងក្រោធជួបគ្រោះ
បាបកម្មក្រាស់ក្រៃលអស់ពេលនឹងរស់ អត់ប្រយោជន៍សោះឈ្លោះគ្នាធ្វើអ្វី ។
វេលាជីវិតពិតមិនច្រើនឡើយ ដកដេកចេញហើយសល់ពីរភាគបី
លោភៈទោសៈមោហៈណាណី តើឲ្យប្រុសស្រីបានអ្វីទីពឹង ។
បើចេះពិនិត្យចិត្តបាបខ្លួនឯង រមែងចេះក្រែងមិនចេះតែខឹង
គ្រប់គ្នារងគ្រោះប្រាប់គ្នាឲ្យដឹង ជួយប្រាប់ទីពឹងប្រឹងលះតណ្ហា ។
កើតមករងទុក្ខរកសុខរៀងខ្លួន មិនអាចគេចពួនពីក្ដីមរណា
តែបើខំប្រុងនៅក្នុងសាសនា រួចពីហិង្សាមេត្តាសង្គ្រោះ ។

មិនមែនខ្ពង់ខ្ពស់ត្រង់ឈ្លោះឈ្នះគេ មិនមែនចាញ់ទេត្រង់គេមិនឈ្លោះ
ឈ្នះមានតម្លៃទាំងថ្លៃទាំងខ្ពស់ គឺឈ្នះបាបគ្រោះរស់រួចវេរា ។
ថាខ្លាចមនុស្សខូចមិនខ្លាចខ្មោចលង ខ្លាចការទាក់ទងមិនទុកចិត្តគ្នា
តែមិនខ្លាចខ្លួនដែលខ្លៅពាលា ខំប្រឹងឈ្លោះគ្នាទាមទារអ្វីទៅ ។
មនុស្សដែលយើងស្អប់ទោះដប់ម្ភៃនាក់ ត្រូវគិតឲ្យជាក់អ្នកជាសត្រូវ
យើងអ្នកស្អប់គេដើរវេខុសផ្លូវ កំពូលសត្រូវនៅក្នុងខ្លួនសោះ ។
ភារៈធ្ងន់ពេកទូលរែកមិនដាក់ ព្រោះតែអាសវៈវដ្តៈជាខ្នោះ
កំណើតទុក្ខពិតក្នុងចិត្តទាំងអស់ បញ្ញារំដោះឲ្យអស់អាសវា ។
អាសវៈក្សិណក្ស័យភពបីរលត់ និព្វានប្រាកដតណ្ហាក្ខយា
ព្រហ្មយានកើតមានក្នុងខ្លួនអ្នកណា អ្នកនោះយាត្រាចូលមហានិព្វាន ៕

ដោយ **ម.ស.ទ.**

## យកទឹកពន្លត់ភ្លើង

មនុស្សឆ្លាត មិនមែននៅត្រង់បានឈ្លោះឈ្នះគេនោះទេ តែនៅត្រង់មិនបង្កជម្លោះ គឺធ្វើជាមនុស្សទឹកដែលអាចពន្លត់ភ្លើងបាន ។ បើយើងដឹងថាអ្នកដទៃមានសេចក្តីក្រោធហើយ យើងមានស្មារតីនៅដោយសេចក្តីអត់ធន់ ស្ងប់ស្ងៀម ដូច្នេះ យើងឈ្មោះថា បានធ្វើនូវ

ប្រយោជន៍ទាំងខ្លួនយើងផង ទាំងអ្នកដទៃផង ទាំងបានឈ្នះនូវសង្គ្រាម ដែលឈ្នះបានដោយក្រផង ។

## ចេះទទួលយល់ព្រម ទើបស្ងប់ចិត្ត

អ្វីដែលបញ្ញាទទួលយកបានគឺការពិត ធ្វើឲ្យយល់ព្រមថា វាត្រូវតែយ៉ាងហ្នឹង ។ មនុស្សយើងច្រើនតែរីករាយទទួលយកសេចក្ដីសុខ បដិសេធមិនទទួលយកសេចក្ដីទុក្ខឡើយ ប៉ុន្តែយើងកើតមកហើយ តើរត់ទៅណារួចពីទុក្ខ ពេលខ្លះត្រូវកើតទុក្ខព្រោះហេតុតែចង់បានសុខពេកហ្នឹងឯង ដូច្នេះត្រូវអប់រំបញ្ញាទទួលការពិត ត្រូវដឹងថាជីវិតនេះមិនមែនមានតែសុខនោះទេ បើយើងបដិសេធចំពោះសេចក្ដីទុក្ខ វារឹតតែគ្របសង្កត់ធ្វើឲ្យយើងកើតទុក្ខថែមទៀត ។

## មេត្តាចិត្តឲ្យសុខគ្នាមៗ

កាលបើយើងជួបនឹងបុគ្គលដែលមិនជាទីស្រឡាញ់ពេញចិត្ត យើងកើតទុក្ខ ព្រោះមកអំពីយើងធ្លាប់ជាប់ជំពាក់ចិត្តជាមួយនឹង

បុគ្គល ជាមួយនឹងអ្វីៗដែលជាទីស្រឡាញ់នោះៗ ទាំងមិនបានអប់រំសតិសម្បជញ្ញៈ ឲ្យបានយល់ច្បាស់អំពីសភាពការណ៍នៃជីវិត ដែលមិនចេះតែបានអ្វីៗតាមចិត្តចង់ទៅនោះទេ ប៉ុន្តែបើយើងហ្វឹកហាត់អប់រំនូវមេត្តាចិត្តរឿយៗ យើងក៏មិនចាំបាច់លំបាកកើតទុក្ខអ្វី នៅពេលជួបនឹងអ្នកណាៗនោះឡើយ ។

## ត្រូវចិត្តនិងត្រឹមត្រូវ

១- ត្រូវចិត្ត គឺត្រូវទៅតាមចំណង់ចំណូលចិត្ត ។

២- ត្រូវតាមសេចក្ដីពិត គឺត្រូវតាមហេតុ តាមបច្ច័យ ជាសច្ចធម៌នៃជីវិតក្នុងលោក និយាយឲ្យខ្លីមកគឺថា ត្រឹមត្រូវ ។ ពីរនេះតើយើងយកមួយណា បើយកត្រូវចិត្ត វាជាការកាន់យកដោយលោភៈ ហើយលោភៈនេះជាហេតុនាំឲ្យកើតទុក្ខពិតប្រាកដណាស់ ព្រោះក្នុងលោកនេះ វាមិនអាចមានអ្វីឲ្យយើងត្រូវចិត្តគ្រប់យ៉ាងទៅនោះទេ ទាំងលោភៈជាមូលនៃវដ្តទុក្ខទៀតផង តែបើយើងក្រេបយកសច្ចរសបាន ពោលគឺបញ្ញាកើតឡើង បានដឹងថាអ្វីៗជាសេចក្ដីពិតទទួលយកភាពត្រឹមត្រូវនៃសង្ខារលោក ក្នុងខ្លួនយើងក្ដី ក្នុងអ្នកដទៃ

ក្តី ក្នុងធម្មជាតិមេឃដីក្តី បានជ្រាបច្បាស់ឡើងៗ គឺអ្វីៗត្រឹមត្រូវតាមបច្ច័យមួយរយភាគរយ ដូច្នេះចិត្តរមែងសុខស្ងប់ មិនជាប់នៅក្នុងសង្ខារលោក មិនលិចចុះក្នុងទុក្ខឡើយ ។

## ចូរឆ្នាក់ខ្លួន កុំគេចពួនពីភារពិត

បុថុជ្ជន ធ្ងន់កិលេស មិនចេះដឹង
ចេះតែខឹង ប្រឹងតែស្អប់ ជាប់វេរា
ភ្នែកក្នុងខ្វាក់ មិនប្រចក្ស នូវធម្មា
ញុំាងវេទនា ជាបច្ច័យ នៃតណ្ហា ។
មិនដឹងទុក្ខ ពោលចាក់រុក សំបុកបាប
ក្លិនឆ្អេះឆ្អាប បាបអសោច ហោចកុសលា
ប្រកាន់ខ្លួន ពួនធ្វើខុស លុះកាមា
ផលក្តៅផ្សា ចិន្តាខ្លោច អសោចកេរ្តិ៍។
មិនសិក្សា ការមិនទៀង ល្មៀងឃ្លាតឃ្លា
តាមធម្មា ជាធម្មតា មិនបិតថេរ
ប្រឹងហួងហែង ប្រឹងស្វះស្វែង សូន្យទទេ

ស្លាប់ទៅគេ    កាយដីកប់    ចប់មួយជាតិ ។
ចូរភ្ញាក់ខ្លួន    កុំគេចពួន    ពីការពិត
កាយនិងចិត្ត    ទាំងគំនិត    គឺជាធាតុ
កុំវង្វេង    បោកខ្លួនឯង    ឲ្យឃ្លៀងឃ្លាត
កំណត់ធាតុ    បបួលញាតិ    សិក្សាធម៌ ៕

ដោយ **ម.ស.ទ.**

## មនុស្សមិនល្អ

មនុស្សមិនល្អ ចូលចិត្តនិយាយរឿងមិនល្អរបស់អ្នកដទៃ ទាំងដែលរឿងល្អរបស់គេមានដែរ តែមិននិយាយ នេះព្រោះចិត្តឥតមេត្តា តាំងទុកអ្នកដទៃនោះជាសត្រូវរបស់ខ្លួន មានគំនុំសងសឹក សង្កត់អ្នកដទៃដើម្បីលើកខ្លួនឯង ទាំងដែលមិនដឹងថាខ្លួនឯងកំពុងតែជាមនុស្សមិនល្អ ។

# ៦. លដុកិកោបមសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអាបណនិគម នាដែនឈ្មោះអង្គុត្តរាបៈ ស្ដេចទ្រង់បិណ្ឌបាត ហើយក្នុងវេលាក្រោយភត្ត ទ្រង់គង់សម្រាកក្រោមម្លប់ឈើមួយដើម ។ ក្នុងសម័យនោះ ព្រះឧទាយីក៏គង់សម្រាកក្បែរព្រះដ៏មានព្រះភាគដែរ លុះដល់ពេលចេញពីផលសមាបត្តិមក ក៏មានសេចក្ដីត្រិះរិះនឹករលឹកចំពោះព្រះគុណរបស់ព្រះដ៏មានព្រះភាគ ហើយក៏បានចូលគាល់ព្រះអង្គក្រាបទូលសេចក្ដីនៃពុទ្ធានុស្សតិ ទាំងបានលើកឡើងនូវទោសនៃការបរិភោគអាហារក្នុងវេលាវិកាល ក្រាបទូលដល់ព្រះដ៏មានព្រះភាគទៀតផង ។

ព្រះដ៏មានព្រះភាគ ទ្រង់លើកឡើងនូវឧបមាដូចជាសត្វប្រចៀច ( លដុកិកោបមា ) ដែលជាប់ដោយចំណងវល្លិផោម ។ ពិតមែន ថាវល្លិផោមវាមិនស្វិតមាំដូចជាវល្លិស្វិតមាំដទៃៗ ប៉ុន្ដែវាជាចំណងដែលចងសត្វប្រចៀចបានយ៉ាងជាប់លាប់មាំមួន ព្រោះមកអំពីសត្វប្រចៀចជាសត្វតូច មានកម្លាំងខ្សោយដោយពិត ។

គ្រឿងចងដែលមាំស្វិត វាស្ថិតនៅត្រង់សត្វតូចមានកម្លាំងខ្សោយ យ៉ាងណា បុគ្គលដែលទន់ខ្សោយទៅដោយសទ្ធានិងបញ្ញា ក៏យ៉ាងនោះដែរ គ្រាន់តែទោសត្រឹមវត្ថុនៃអាបត្តិទុក្កដ ក៏មិនអាចលះបង់បាន មានសភាពមាំស្វិតប្រាកដដូចវត្ថុនៃបារាជិកដូច្នោះឯង គឺថាការជាប់ជំពាក់នឹងរបស់បន្តិចបន្តួច ក៏មិនអាចលះកាត់បានដែរ កូនខ្ទមដែលរខេករខាកសោះ ប្រាកដដូចជាវិមានប្រាសាទ ប្រពន្ធមុខមាត់អាក្រក់ មារយាទថោកសោះ ប្រាកដដូចទេពធីតា ឬស្ត្រី-កែវដែលជាអគ្គមហេសីនៃស្តេចចក្រ ។ ចំណែកកុលបុត្រដែលមានសទ្ធានិងបញ្ញាច្រើន សូម្បីតែកាមគុណជាទិព្វក៏លះបង់បានដែរ ដូចជាព្រះសមិទ្ធិដែលមិនស្រឡាញ់ទេពធីតា ឬដូចព្រះរដ្ឋបាលត្ថេរ ព្រះអនុរុទ្ធ ព្រះភទ្ទិយកាឡិគោធាយបុត្ត និងព្រះមហាកប្បិនជាដើម ដែលសុទ្ធតែជាអង្គដែលបរិបូណ៌ដោយកម្លាំងសទ្ធានិងបញ្ញា ប្រាកដដូចជាដំរីដែលផ្តាច់នូវទន្លីងដូច្នោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងបន្តអំពីបុគ្គល ៤ ពួក គឺ ពួកទី ១ មិនបានលះនូវឧបធិ ពួកទី ២ បានលះនូវឧបធិ ពួកទី ៣ លះនូវឧបធិបានដោយឆាប់រហ័ស និងពួកទី ៤ លះបង់នូវកិលេសូបធិ ព្រោះដឹងច្បាស់ថាខន្ធូបធិជាមូលនៃទុក្ខ ។ បីពួកខាង

ដើមគឺបុថុជ្ជននិងព្រះអរិយបុគ្គល ( វៀរព្រះអរហន្ត ) ដែលថា មិនបានលះនូវឧបធិសូម្បីតែព្រះអនាគាមិបុគ្គល ក៏នៅញាប់ញ័រក្នុងសុខមានភវរាគៈ ទើបឈ្មោះថា នៅលះមិនទាន់បាន ។ ដែលថាលះបាននូវឧបធិ សូម្បីបុថុជ្ជនអ្នកចម្រើនវិបស្សនា ឈ្មោះថាលះបានគឺដោយព្យាយាមចម្រើនវិបស្សនា ដកនូវកិលេសដោយមគ្គ ។ ដែលថាលះនូវឧបធិបានដោយឆាប់រហ័ស ដូចសម្តែងក្នុងមហាហត្ថិបទោ-បមសូត្រ ឥន្ទ្រិយភាវនាសូត្រ និងក្នុងព្រះសូត្រនេះដោយពិត ។ ចំណែកបុគ្គលពួកទី ៤ គឺព្រះអរហន្តលះបង់កិលេសមិនមានសល់ ។ ព្រះតថាគត ទ្រង់ជ្រាបច្បាស់នូវឥន្ទ្រិយដែលផ្សេងគ្នាចំពោះបុគ្គលក្នុងលោក ព្រះអង្គទ្រង់សម្តែងបុគ្គល ៤ ពួក ដែលមានបុគ្គលមិនបានលះនូវឧបធិ និងបុគ្គលបានលះនូវឧបធិនោះក្នុងពេលក្រោយទៅតាមឥន្ទ្រិយចាស់ក្លា ឬទន់ខ្សោយ ។

ជាចុងក្រោយនៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់អំពីកាមគុណ ៥ និងកាមសុខ ថាជាសុខមិនស្អាត ជាសុខរបស់បុថុជ្ជន មិនមែនជាសុខរបស់ព្រះអរិយៈ ដែលគេមិនគួរធ្វើឲ្យថ្មើក មិនគួរចម្រើន មិនគួរធ្វើឲ្យរឿយៗឡើយ តថាគតពោលថា គួរខ្លាចសេចក្តីសុខនោះ ។ ផ្ទុយគ្នា ព្រះអង្គទ្រង់ត្រាស់អំពីនេក្ខម្មសុខ វិវេកសុខ ឧបសមសុខ

និងសម្ពោធិសុខ ដែលបុគ្គលគួរធ្វើឲ្យថ្មើក គួរចម្រើន គួរធ្វើឲ្យរឿយៗ តថាគតពោលថា បុគ្គលមិនគួរខ្លាចនូវសេចក្តីសុខនេះឡើយ ។

សូមអនុមោទនា !

## សេចក្តីសុខ ២ ផ្នែក

សេចក្តីសុខ គឺជាកំពូលនៃសេចក្តីប្រាថ្នារបស់មនុស្សយើងគ្រប់គ្នា ទោះជាប្រាថ្នាវត្ថុអ្វីៗ ផ្សេងៗគ្នាក៏ដោយ សរុបមកសុទ្ធតែបំណងឲ្យជីវិតបានសុខ ទាំងខ្លួនឯង ទាំងបុគ្គលដែលខ្លួនស្រឡាញ់ ព្រោះអាស្រ័យហេតុនេះ មនុស្សយើងមិនគួរបៀតបៀនគ្នាទេ ម្យ៉ាងទៀត កុំឃើញតែកាមសុខថាជាសុខ ត្រូវឃើញនូវនេក្ខម្មសុខជាដើមថាជាសុខពិតមិនគួរឲ្យខ្លាច ឯចំណែកកាមសុខត្រូវតែប្រយ័ត្នឲ្យណាស់ ដូចឃើញទុក្ខទោសក្នុងកាមភពនេះស្រាប់ហើយ ។

## គួរចម្រើនមរណស្សតិឲ្យបានរឿយៗ

បើយើងមានមរណស្សតិរឿយៗ យើងនឹងរកសេចក្តីសុខ

បានងាយៗ ព្រោះយើងបានឃើញតម្លៃនៃពេលវេលាដែលនៅសល់ គ្រាន់តែភ្ញាក់ឡើងបានឃើញថ្ងៃថ្មីប៉ុណ្ណឹង យើងក៏មានសេចក្តីសុខទៅហើយ ដែលមិនបានស្លាប់ពីយប់មិញ នៅមានថ្ងៃនេះសម្រាប់យើងធ្វើអ្វីដែលយើងចង់ធ្វើ ដែលជាអំពើមានប្រយោជន៍ និងនៅបានឃើញមុខមនុស្សគ្រប់គ្នាប្រកបដោយមេត្តាចិត្ត មិនមានស្អប់អ្នកណាៗឡើយ ព្រោះយើងមានសេចក្តីសុខដោយការបានត្រឹមតែជីវិតមិនទាន់ស្លាប់ប៉ុណ្ណោះគ្រប់គ្រាន់ហើយ អរគុណបុណ្យដែលបានឲ្យនៅមានជីវិត អរគុណជីវិតដែលបានឲ្យនៅរស់ធ្វើបុណ្យបន្តទៀត ។ ជាមួយគ្នានេះដែរយើងឃើញមនុស្សទាំងឡាយដ៏ច្រើន ត្រឡប់ទៅជារកសុខបានដោយលំបាកក្រៃលែង ចេះតែត្រូវការនេះ ត្រូវការនោះ បាននៅរស់ហើយមិនគ្រប់គ្រាន់ ដោយសារមិនមាននូវមរណស្សតិហ្នឹងឯង ។

## បាននៅរស់ហើយ កុំភ្លេចខ្លួន

មនុស្សយើងប្លែកណាស់ ដើម្បីរក្សាជីវិត ព្រមលះបង់ទ្រព្យសម្បត្តិប៉ុនណាៗក៏ដោយ ឲ្យតែបាននៅរស់ ប៉ុន្តែឥឡូវបាននៅរស់

ហើយ បែរទៅជាកើតទុក្ខ ព្រោះត្រូវការទ្រព្យសម្បត្តិដោយប្រការផ្សេងៗទៅវិញ នេះហៅថាភ្លេចខ្លួន បាននៅរស់ហើយ ទៅជាខ្ជះខ្ជាយជីវិតឲ្យអស់ទៅឥតប្រយោជន៍ ។

## កុំខ្ជះខ្ជាយជីវិតដ៏មានតម្លៃនេះ

មនុស្សយើងខ្លះ ចេះសន្សំសំចៃក្នុងការចាយវាយទ្រព្យសម្បត្តិ ប៉ុន្តែបែរជាខ្ជះខ្ជាយជីវិតទៅវិញ ព្រោះមកអំពីភ្លេចគិតពីតម្លៃនៃជីវិត ។ មានសេដ្ឋីម្នាក់ដែលគាត់ភ័យចំពោះសេចក្តីស្លាប់ព្រោះមានរោគក្នុងក្បាល គាត់ត្រូវការជីវិតខ្លាំងណាស់ សូមឲ្យលោកគ្រូពេទ្យ ( ពេទ្យជីវកកោមារភច្ច ) ព្យាបាល ដោយសន្យាថាបើរោគគាត់បានជាសះស្បើយ គាត់ជូនទ្រព្យគាត់ទាំងអស់ដល់លោកគ្រូពេទ្យ ហើយគាត់នឹងទៅបម្រើលោកគ្រូពេទ្យ ក្នុងជីវិតរស់នៅតទៅទៀតរបស់គាត់ ។

# ក្នុងលោកនេះមិនមានអ្វីរហូតទេ

អ្វីៗសុទ្ធតែមានអាយុ មានពេលវេលា មិនថាសុខឬទុក្ខ គឺមានការកើតពីខាងដើម ប្រែប្រួលកណ្ដាល រួចហើយក៏រលត់រលាយបាត់ទៅនៅទីបំផុត ។ ការដែលមនុស្សយើងបានមកជួបគ្នា ស្គាល់គ្នា គឺជាអ្នកមានឧបនិស្ស័យជាមួយនឹងគ្នាមក បានជួបគ្នាហើយគួរតែប្រើប្រាស់ពេលវេលាឲ្យបានល្អ ធ្វើល្អដល់គ្នាឲ្យហើយៗ ព្រោះអ្វីដែលថារហូតមិនមានទីបំផុតនោះ គឺមានតែព្រះនិព្វានប៉ុណ្ណោះ ចំណែកយើងឯណេះវិញក្រែងតែថានៅមិនទាន់ដល់ស្អែកផងទេ អ្វីៗដែលល្អៗត្រូវតែប្រញាប់ធ្វើទៅ តែដល់ពេលកំណត់ត្រូវតែព្រាត់ត្រូវតែបែក ប្រកែកមិនបានឡើយ ។

# ចំណេះដឹងក្នុងរឿងស្នេហាគឺការលះបង់

មនុស្សយើងច្រើនតែកើតទុក្ខសោកសៅ ព្រោះការហួងហែងនូវសេចក្ដីស្រឡាញ់ ចាប់ផ្ដើមស្រឡាញ់ ស្នេហាពេលណា ការហួងហែងក៏ចាប់ផ្ដើមដែរ ទាំងចាប់ផ្ដើមសង្ស័យ ហើយសាកសួរ

ដេញដោល បង្កឲ្យមានការច្រណែន ប្រចណ្ឌ ។ល។ បើមិនមានការហួងហែងទេ មានតែសេចក្ដីស្រឡាញ់ដោយមេត្តា ក៏មិនមានបញ្ហាតានតឹងក្នុងដើមទ្រូងដែរ ។ សេចក្ដីស្រឡាញ់ចូលមកដល់ជីវិតយើង ដើម្បីឲ្យយើងរៀនដឹង មិនមែនសម្រាប់ឲ្យយើងគ្រប់គ្រងរហូតទៅនោះទេ គេមានពេលវេលារបស់គេ យើងត្រូវតែយល់ឲ្យច្បាស់ ហើយចំណេះដឹងដែលយើងត្រូវអនុវត្តដើម្បីរក្សាខ្លួនយើងនោះ គឺការលះបង់ ។

## ចេតិយនៃជីវិត

ការមិនធ្វើបាបទាំងពួង គឺជាបុណ្យសំខាន់ផ្នែកចាក់គ្រឹះ រួចហើយទើបដល់ព្រមដោយការបំពេញនូវកុសល គឺជាតួកណ្ដាលនៃព្រះចេតិយ ជាទីបំផុតចិត្តយើងស្អាត គឺជាកំពូលនៃព្រះចេតិយដែលសម្រាប់តម្កល់ទុកនូវនិព្វានធាតុ គឺព្រះនិព្វានជាអារម្មណ៍នៃផលសមាបត្តិ នេះគឺចេតិយនៃជីវិត ។

# ៧.ចាតុមសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអាមលកីវ័ន ( ព្រៃកន្ទួតព្រៃ ) ក្នុងស្រុកចាតុមា ។ សម័យនោះឯង ពួកភិក្ខុប្រមាណ ៥០០ អង្គដែលទើបនឹងបួសថ្មីៗ ត្រូវបានព្រះអគ្គសាវ័កទាំងពីរអង្គនាំចូលគាល់ព្រះបរមសាស្តា ដោយគិតថា ពួកកុលបុត្រទាំងនេះ បួសហើយមិនធ្លាប់បានឃើញព្រះទសពលឡើយ យើងនឹងឲ្យភិក្ខុទាំងនេះបានគាល់ព្រះដ៏មានព្រះភាគ បានស្តាប់ព្រះធម៌ក្នុងសម្នាក់ព្រះអង្គហើយនឹងតាំងនៅតាមឧបនិស្ស័យរបស់ខ្លួន ។

ព្រះភិក្ខុទាំង ៥០០ អង្គនោះ ត្រូវព្រះដ៏មានព្រះភាគបណ្តេញចេញអំពីសម្នាក់ព្រះអង្គ ព្រោះមកអំពីមាត់ក មានសំឡេងគឹកកងខ្លាំងៗ នៅពេលដែលទើបតែនិមន្តចូលទៅដល់ ទាក់ទងនឹងរៀបចំទីកន្លែងគង់អាស្រ័យនៅ ដោយព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចេញទៅ តថាគតបណ្តេញអ្នកទាំងឡាយ គឺអ្នកទាំងឡាយមិនគួរនៅក្នុងសម្នាក់តថាគតឡើយ ។ ព្រះអដ្ឋកថាបញ្ជាក់សេចក្តីត្រង់ព្រះពុទ្ធដីកា **ន វោ មម សន្តិកេ វត្ថព្វំ**

ដែលប្រែថា អ្នកទាំងឡាយមិនគួរនៅក្នុងសម្នាក់តថាគតឡើយ គឺ ក្នុងសេចក្តីថា ពួកអ្នកមកដល់សម្នាក់នៃព្រះសម្មាសម្ពុទ្ធហើយ នៅ ធ្វើសំឡេងខ្លាំងៗដល់ថ្នាក់នេះ ទម្រាំដល់ពួកអ្នកនៅតាមកន្លែងរបស់ ខ្លួន នឹងធ្វើអំពើសមគួរបានយ៉ាងដូចម្តេចទៅ ដូចពួកអ្នកទាំងឡាយ នេះ មិនមានកិច្ចដែលនឹងនៅក្នុងសម្នាក់តថាគតឡើយ ។

បំណងភិក្ខុទាំងនោះថា យើងនឹងគាល់ព្រះសាស្តា នឹងស្តាប់ ព្រះធម៌ទេសនា នឹងនៅក្នុងសម្នាក់ព្រះពុទ្ធអង្គ ទើបបានមក ប៉ុន្តែ ពេលដែលមកដល់សម្នាក់ព្រះសាស្តាដែលជាព្រះពុទ្ធបរមគ្រូ បែរ ទៅជាធ្វើសំឡេងខ្លាំងៗ នេះគឺជាកំហុសរបស់ពួកយើង ទើបត្រូវ ព្រះសាស្តាទ្រង់បណ្តេញ ។ ពួកភិក្ខុមិនបាននៅក្នុងសម្នាក់ព្រះដ៏-មានព្រះភាគ មិនបានឃើញនូវព្រះសរីរៈដែលមានពណ៌ដូចមាស មិនបានដើម្បីនឹងស្តាប់ នូវព្រះធម៌ដោយព្រះសូរសៀងដ៏ពីរោះដូច្នេះ ពួកភិក្ខុទាំងនោះ ក៏ដល់នូវភាពទោមនស្សយ៉ាងខ្លាំង ទទួលស្តាប់ ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគ ថាព្រះករុណាព្រះអង្គ ហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយ រៀបចំទុកដាក់សេនាសនៈ បានកាន់យកបាត្រនិងចីវរចៀស ចេញទៅ ។

ក្នុងកាលនោះ បានសក្យៈទាំងឡាយអ្នកស្រុកចាតុមា និង

សហម្បតិព្រហ្ម ចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលសូមសេចក្តីអនុគ្រោះដល់ពួកភិក្ខុទាំង ៥០០ អង្គនោះ ដោយលើកឧបមាដូចពូជដែលនៅទន់ខ្ចី និងដូចកូនគោតូច ។ ពូជដែលនៅទន់ខ្ចី កាលមិនបានទឹកហើយ នឹងមានការស្វិតស្រពោន ឬនឹងមានដំណើរប្រែប្រួល ( វិបរិណាមោ ) គឺពួកភិក្ខុនឹងសឹកចាកសិក្ខាបទ ដូចពូជស្រូវត្រូវស្វិតក្រៀមដោយសារអត់ទឹកដូច្នោះដែរ ពុំនោះសោត ដូចកូនគោតូចកាលដែលមិនបានឃើញមេហើយ នឹងមានការស្គាំងស្គមដល់ស្លាប់ឈ្មោះថាការប្រែប្រួល ពោលគឺពួកភិក្ខុទាំងនោះនឹងលាចាកសិក្ខា ។

កាលដែលព្រះដ៏មានព្រះភាគ ទ្រង់អនុគ្រោះដល់ព្រះភិក្ខុទាំងនោះឲ្យចូលគាល់ជាថ្មីហើយ ទ្រង់ប្រទានសាធុការដល់ព្រះ-មហាមោគ្គល្លាន ក្នុងគំនិតដែលព្រះមហាមោគ្គល្លានគិតថា នឹងគ្រប់គ្រងភិក្ខុសង្ឃជាមួយនឹងព្រះសារីបុត្ត រួចហើយ ទើបព្រះអង្គទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា អំពីភ័យ ៤ យ៉ាង ។

## ភ័យ ៤ យ៉ាងគឺ

១- **ឧម្មិភយំ** ភ័យកើតពីរលក ជាឈ្មោះនៃសេចក្តីក្រោធនិងសេចក្តីចង្អៀតចង្អល់ចិត្ត ។

២- **កុម្ភីលភយំ** ភ័យនឹងក្រពើ ជាឈ្មោះនៃការគិតតែបរិភោគបំពេញផ្ទៃប៉ុណ្ណោះ ។

៣- **អាវដ្ដភយំ** ភ័យកើតពីអន្លង់ទឹក ជាឈ្មោះនៃកាមគុណ ៥ ។

៤- **សុសុកាភយំ** ភ័យកើតអំពីត្រីសាហាវ ជាឈ្មោះនៃមាតុគ្រាម ។

ម្នាលភិក្ខុទាំងឡាយ ភ័យទាំង ៤ នេះឯង ដែលកើតមានចំពោះបុគ្គលពួកមួយក្នុងសាសនានេះ ជាបព្វជិតដែលចេញចាកផ្ទះចូលកាន់ផ្នួសក្នុងធម្មវិន័យនេះ ។

សេចក្ដីពិស្ដារនៃភ័យ ៤ យ៉ាងនេះ មានក្នុងព្រះសូត្រស្រាប់ សូមពុទ្ធបរិស័ទរីករាយជ្រះថ្លាក្នុងការសិក្សា សូមអនុមោទនា ។

សូមអនុមោទនា !

## អប់រំហ្វឹកហាត់ចិត្ត

មនុស្សសព្វថ្ងៃពូកែណាស់ ខាងធ្វើអ្វីៗឲ្យមនុស្សផងគ្នាប្រើប្រាស់ ដូចជារថយន្ត យន្តហោះ ទូរទស្សន៍ ទូរស័ព្ទ ។ល។

ប៉ុន្តែបែរជាសាងចិត្តរបស់ខ្លួនឯងឲ្យស្ងប់មិនបាន ។ ចិត្តនេះត្រូវអប់រំហ្វឹកហាត់ក្នុងអារម្មណ៍នៃព្រះកម្មដ្ឋាន មានសីលសម្រាប់ទ្រទ្រង់ ។ ដួងចន្ទពេញបូណ៌មី គ្រាន់តែត្រជាក់ភ្នែកប៉ុណ្ណោះ ប៉ុន្តែសីលនាំឲ្យត្រជាក់ចិត្ត ។ យើងមិនអាចបង្គាប់បញ្ជាអ្វីៗឲ្យបានដូចចិត្តយើងចង់ទៅគ្រប់យ៉ាងនោះឡើយ ប៉ុន្តែយើងអាចអប់រំចិត្តឲ្យយល់ព្រមជាមួយនឹងអ្វីៗដែលកើតឡើងនោះ រស់នៅជាមួយបានដោយស្មារតីប្រគល់ឲ្យអ្វីៗទៅតាមធម្មតាធម៌ជាសភាវៈក្នុងលោក ការមិនចាប់ប្រកាន់គឺជាទីពឹងរបស់អ្នកប្រព្រឹត្តធម៌ ។

## សម្លឹងសន្តិ លះលោកាមិសៈ

បញ្ហាក្នុងជីវិតគ្រប់គ្នា គឺកិលេសក្នុងចិត្តរបស់ខ្លួន ដំណោះ-ស្រាយគឺសន្សំបុណ្យលះបាបហ្នឹងឯង ។ អ្វីៗដែលជាមហាកុសលមិនមែនអរិយមគ្គ មិនមែនសម្រាប់ដើម្បីលះកិលេសទេនោះ តើចេះតែខំត្រេកអរដើម្បីអ្វីទៅ ។ សូមឲ្យពុទ្ធបរិស័ទ ចេះសម្លឹងមើលសេចក្តីសុខនៅត្រង់ការអស់កិលេស អស់ទុក្ខ ដែលជាបរមសុខគឺព្រះនិព្វាន ។

## មួយណាជាសត្រូវពិតប្រាកដ

មួយអ្នកដទៃដែលយើងស្អប់ មួយទៀតគឺការស្អប់អ្នកដទៃនោះ តើមួយណាដែលគួរលះបង់ មួយណាដែលជាសត្រូវនឹងយើងពិតប្រាកដ ។

## ចេះសម្លឹងឃើញកិលេសខ្លួនឯង

មួយសម្លឹងទោសអ្នកដទៃ ដើម្បីចាប់កំហុស ប្រកាសទោស តិះដៀលដោយគំនុំគុំស្អប់ មួយទៀតសម្លឹងទោសខ្លួនឯង ដើម្បីកែខៃលះបង់នូវអ្វីដែលមិនល្អ អប់រំចម្រើននូវគុណធម៌ឲ្យបានពេញ-លេញ តើមួយណាដែលគួរកាន់យក ។ តាមពិត មនុស្សយើង ឲ្យតែចេះសម្លឹងឃើញកិលេសក្នុងចិត្តរបស់ខ្លួនពិតៗ ប្រាកដជាមិនកាចសាហាវដាក់អ្នកដទៃទេ ព្រោះបានយល់ថា មិនមានអ្នកណាសាងកិលេសឲ្យខ្លួនឯងឡើយ កិលេសហ្នឹងហើយដែលជាអកុសលមូល បើមិនមានអកុសលមូល គឺលោភៈ ទោសៈ និងមោហៈទេ ក៏មិនមានអ្នកណាធ្វើអ្វីខុសក្នុងអកុសលកម្មបថដែរ ។

# កម្មមាន តែអ្នកធ្វើកម្មមិនមាន

មនុស្សយើងចេះនិយាយថា ស្អប់អំពើអាក្រក់ ប៉ុន្តែតាមពិត គឺស្អប់មនុស្សដែលធ្វើអាក្រក់នោះៗឯង ។ ដោយបរមត្ថ កម្មមាន ប៉ុន្តែអ្នកធ្វើកម្មមិនមានទេ កម្មកើតអំពីអវិជ្ជា តណ្ហា ឧបាទាន កាលណា បានដឹងដូច្នេះដោយបញ្ញាដ៏ប្រពៃតាមពិត គឺរមែងមិនមាន ការស្អប់គ្នាឡើយ មានតែខ្មាសខ្ពើមបាប ខ្លាចបាបដោយហិរិនិង ឱត្តប្បៈ និងមានសតិរលឹកដឹងទោសនៃបាបអកុសលនោះៗ កាល បើមានបញ្ញត្តិជាអារម្មណ៍ ក៏ចេះជួយគ្នាឲ្យរួចពីបាប ដោយការ ប្រព្រឹត្តធម៌ ឃើញគ្រប់គ្នាសុទ្ធតែជាអ្នករងគ្រោះក្នុងវដ្តសង្សារ ។

# អំពើបាបជាអំពើរបស់បុគ្គលល្ងង់ទេតើ

គួរតែរលឹកដឹងថា អំពើដែលប្រព្រឹត្តទៅដោយរាគៈ គេមិន ចាំបាច់រៀនសូត្រព្រះធម៌ ប្រព្រឹត្តតាមព្រះធម៌ដប់ម្ភៃឆ្នាំទៅនោះឡើយ សូម្បីតែមនុស្សទ្រុស្តសីល មិច្ឆាទិដ្ឋិ ឬសូម្បីតែសត្វតិរច្ឆានក៏ចេះដែរ ការខឹងក្រោធក៏ដូចគ្នា ដូច្នេះវាមិនមែនជាសភាវៈដែលមានតម្លៃគួរ

កាន់យកនោះឡើយ តើយើងខំរៀនធម៌ ម្ភៃសាមសិបឆ្នាំ បានត្រឹមតែចេះខឹង ចេះខុសហ្នឹងឬ ?

## ទុក្ខប៉ុណ្ណឹងកុំរអ៊ូយអី

ព្រោះធ្លាប់សុខស្រណុកស្រួល ធ្លាប់គ្រាន់បើរឿងនេះ រឿងនោះ ក៏មិនអាចទទួលការណែនាំអំពីព្រះឧបជ្ឈាយាចារ្យ ដោយគិតថាលំបាកយ៉ាងនេះ លំបាកយ៉ាងនោះ ដូច្នេះហើយ ក៏មិនអាចប្រព្រឹត្តព្រហ្មចរិយធម៌ដើម្បីរួចផុតចាកទុក្ខបាន នេះព្រោះមិនឃើញភ័យក្នុងវដ្តៈហ្នឹងឯង ។

ព្រោះធ្លាប់ក្នុងរឿងបរិភោគតាមឆ្ងាញ់ និងគ្រប់ពេលវេលា ក៏មិនអាចប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យរួចផុតចាកទុក្ខបានដែរ ខ្លាចទុក្ខបន្តិចបន្តួច តែមិនខ្លាចទុក្ខធំក្នុងវដ្តៈ មិនខ្លាចទុក្ខក្នុងអបាយភូមិ ។

ព្រោះត្រេកអរក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីត្រេកអរ ជាទីប្រាថ្នា ជាអារម្មណ៍ដែលប្រកបដោយកាម ជាទីតាំងនៃតម្រេក ក៏មិនអាចប្រព្រឹត្តព្រហ្ម-ចរិយធម៌ឲ្យរួចផុតចាកទុក្ខ នេះមកអំពីចង់លះទុក្ខក្នុងបច្ចុប្បន្នដោយ

អវិជ្ជា ហើយសន្សំកពូននូវហេតុនៃសេចក្ដីទុក្ខដោយតណ្ហា ទាំងមិនឃើញភ័យក្នុងវដ្តសង្សារទ្បើយ ។

ព្រោះកាមរាគៈអាស្រ័យនឹងមាតុគ្រាម ក៏មិនអាចប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យរួចផុតចាកទុក្ខបាន ដែលមាតុគ្រាមនោះគឺមិនមែនជាអរិយមគ្គ ក៏មិនមែនជាមហាកុសលដែរ ។ ប្រភពនៃបញ្ហាគឺតណ្ហាក្នុងចិត្ត ដូច្នេះគប្បីស្វែងរកនូវកុសល ត្រេកអរក្នុងព្រហ្មចរិយធម៌ដើម្បីលះបង់ហេតុនៃសេចក្ដីទុក្ខ ។

តាមពិត បានកើតជាមនុស្សហើយ ទាំងបានប្រព្រឹត្តនូវព្រហ្មចរិយធម៌គឺធម៌ដ៏ប្រសើរទៀត ក៏ល្មមយល់ដឹងអំពីសេចក្ដីសុខដែលប្រាសចាកទោស ដោយមិនចាំបាច់ទាមទារអ្វីៗដែលនាំមកនូវភ័យទាំង ៤ យ៉ាងនោះៗទ្បើយ បានសុខប៉ុណ្ណឹងក៏ល្មមហើយ ទាំងបានឃើញភ័យក្នុងវដ្តសង្សារថែមទៀត ដូច្នេះគួរអប់រំសេចក្ដីសុខឲ្យបានស្ងប់ប្រណីត ចម្រើនវិបស្សនាកំណត់ដឹងទុក្ខ លះបង់តណ្ហាសម្រេចនូវមគ្គព្រហ្មចរិយៈដល់ទីបំផុត ។

# ៨-នឡកបានសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃចារ ( បលាសវ័ន ) ជិតស្រុកនឡកបានៈ ក្នុងដែនកោសល ។ ក្នុងសម័យនោះ កុលបុត្រទាំងឡាយជាច្រើនអង្គ ដែលចូលកាន់ផ្នួសដោយសទ្ធា ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគ មានព្រះអនុរុទ្ធ ព្រះភទ្ទិយៈ ព្រះកិម្ពិលៈ ព្រះភគ្គុ ព្រះកោណ្ឌញ្ញៈ ព្រះរេវតៈ និងព្រះអានន្ទ ជាដើម គង់នៅជាមួយនឹងព្រះដ៏មានព្រះភាគ ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់សួរអំពីការត្រេកអរក្នុងព្រហ្មចរិយធម៌ ។

ការដែលបួសដោយសទ្ធា គឺមិនមែនបួសព្រោះព្រះរាជាទ្រង់គុំគួន ចោរគុំគួន ជំពាក់បំណុលគេ ភ័យរឿងក្ដី ឬមានវិបត្តិក្នុងការចិញ្ចឹមជីវិតជាដើមឡើយ ប៉ុន្តែព្រោះមកអំពីគិតឃើញថា អាត្មាអញជាអ្នកត្រូវជាតិជរាមរណៈ សោកបរិទេវៈ ទុក្ខទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្តគ្របសង្កត់ ពោលគឺជាអ្នកមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ទើបចេញចាកផ្ទះដោយសទ្ធា ចូលកាន់ផ្នួសបួសជាបព្វជិត ដើម្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នោះ ឲ្យប្រាកដបាន ។

កិច្ចដែលកុលបុត្របួសដោយសទ្ធាគឺស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ បានសម្រេចនូវបឋមជ្ឈាន និងទុតិយជ្ឈាន ។ បើមិនទាន់បាននូវឈានថ្នាក់លើ ឬមិនទាន់សម្រេចនូវមគ្គ ៤ ទេ ក៏ត្រូវធម៌ជាអកុសល ៧ យ៉ាងគ្របសង្កត់ គឺនីវរណធម៌ ៥ និងអរតិ ដែលមិនត្រេកអរនឹងអធិកុសល ១ តន្ទ្រី សេចក្តីខ្ជិលច្រអូសទម្រន់យឺត-យូរ ១ លុះដល់បានសម្រេចនូវឈានថ្នាក់លើគឺតតិយជ្ឈាន និងចតុត្ថជ្ឈាន ( ឈានចតុក្កន័យ ) ឬបានសម្រេចនូវមគ្គ ៤ តាមដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ម្នាលពួកអនុរុទ្ធ បុគ្គលនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបីតិនិងសុខ ឬបានដល់នូវសេចក្តីសុខដទៃ ដែលស្ងប់ស្ងាត់ជាងបីតិនិងសុខនោះ ទើបអកុសលធម៌ទាំង ៧ យ៉ាងនោះ មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ( **ឞិវេគំ អនុរុទ្ធា ភាមេហិ ឞិវេគំ អកុសលេហិ ធម្មេហិ បីតិសុខំ អធិគច្ឆតិ អញ្ញំ ឞា តតោ សន្តតរំ** ) ។

អាសវៈទាំងឡាយណា នាំមកនូវសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិជរាមរណៈ អាសវៈអម្បាលនោះ ព្រះតថាគតទ្រង់លះបង់បានហើយ ព្រោះហេតុដូច្នោះបានជាព្រះតថាគត ៖

**សន្ទាយេកំ បដិសេវតិ** ទ្រង់ជ្រាបហើយ ទើបសេព របស់ខ្លះ គឺទ្រង់សេពនូវរបស់ដែលគួរសេព [១] ។

**សន្ទាយេកំ អធិវាសេតិ** ទ្រង់ជ្រាបហើយ ទើបអត់សង្កត់ក្នុងអារម្មណ៍ដែលគួរអត់សង្កត់ ។

**សន្ទាយេកំ បរិវជ្ជេតិ** ទ្រង់ជ្រាបហើយ ទើបវៀរនូវអ្វីដែលគួរវៀរ ។

**សន្ទាយេកំ វិនោទេតិ** ទ្រង់ជ្រាបហើយ ទើបបន្ទោបង់នូវអ្វីដែលគួរបន្ទោបង់ ។

ជាចុងក្រោយនៃព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងអំពីប្រយោជន៍ដែលព្រះអង្គទ្រង់ត្រាស់ព្យាករនូវភិក្ខុ ភិក្ខុនី ឧបាសក និង ឧបាសិកា ជាព្រះអរិយបុគ្គលដែលទទួលនូវមរណភាពទៅនោះៗ ។ ប្រយោជន៍គឺនៅត្រង់ដែលថា មានការរលឹកឃើញនូវសទ្ធា សីល សុតៈ ចាគៈ និងបញ្ញារបស់ព្រះអរិយបុគ្គលទាំងនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ នេះជា ផាសុវិហារធម៌ ។

**សូមអនុមោទនា !**

---

[១] សេពនូវបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម តាមសេចក្ដីក្នុងសព្វាសវសំវរសូត្រ ។

# ពូកែដែលអស្ចារ្យ អាសវក្ខយានិព្វានហោង

កុំពូកែតែគិត ត្រូវគិតសុចរិតមនោកម្មា
កុំពូកែតែថា ត្រូវពោលវាចាវចីសុចរិត ។
កុំពូកែតែធ្វើ ត្រូវធ្វើអំពើសុចរិតពិតៗ
កុំពូកែតែលិឍ ត្រូវតែប្រយ័ត្នកាំបិតទឹកឃ្មុំ ។
កុំពូកែតែរស់ ត្រូវរៀរជម្លោះរស់គ្មានគំនុំ
កុំពូកែតែខ្ញុំ ត្រូវមើលឲ្យជុំក្រែងខ្ញុំតណ្ហា ។
កុំពូកែតែហូប ត្រូវចេះស្រស់ស្រូបមត្តញ្ញុតា
កុំពូកែតែថា ត្រូវខំសិក្សាបដិបត្តិប្រពៃ ។
កុំពូកែតែចាយ ត្រូវគិតចំណាយចំណូលលកលៃ
កុំពូកែតែភ័យ ត្រូវមើលអ្វីៗតាមសេចក្ដីពិត ។
កុំពូកែតែអញ ត្រូវចេះស្រឡាញ់ធម្មញាតិធម្មមិត្ត
កុំពូកែតែស្និទ្ធ ត្រូវចេះពិនិត្យក្រែងមិត្តនាំគ្រោះ ។
កុំពូកែតែដេក ត្រូវក្រែងថាស្អែកមិនបាននៅរស់
កុំពូកែតែឈ្លោះ ត្រូវយកការរស់សង្គ្រោះមេត្តា ។
កុំពូកែតែដើរ ត្រូវគិតដំណើរចាកវដ្តសង្សារ

ពូកែដែលអស្ចារ្យ　　　អាសវក្ខយានិព្វានហោង ។

ដោយ **ម.ស.ខ.**

## គេនិយាយអត់គំនិត យើងយកមកគិតឲ្យស្មុកចិត្ត

អ្នកខ្លះនិយាយអត់គំនិត　　　យើងយកមកគិតធ្វើអ្វីទៅ
ពាក្យមានខ្លឹមសារវាចាត្រូវ　　　ស្តាប់ទៅគិតទៅសប្បាយចិត្ត ។
អ្នកខ្លះអួតខ្លួនខ្លាំងពូកែ　　　ក៏ព្រោះហេតុតែមិនបានគិត
កិលេសរួបរឹតសន្តានចិត្ត　　　បើខ្លាំងមែនពិតបរិសុទ្ធហោង ។
អ្នកខ្លះរំពៃតែទោសគេ　　　រិះគន់គ្នាន់គ្នេរថៃមថយផង
ក្នុងចិត្តខ្លួនឯងខ្មៅសៅហ្មង　　　ម្តេចមើលរំលងមិនអៀនមាត់ ។
អ្នកខ្លះហ៊ានវាយតម្លៃមនុស្ស　　　មិនបានចាក់ធ្លុះឲ្យហ្មត់ចត់
សម្តីមនុស្សថ្លៃពិតប្រាកដ　　　តែដល់ពោលភ្លាត់ទៅជាថោក ។
ព្រះពុទ្ធបរមគ្រូត្រាស់សម្តែង　　　ឲ្យមើលខ្លួនឯងក្រែងចាញ់បោក
ដឹងខុសកែខៃថ្លៃផុតលោក　　　ផុតចាកទុក្ខសោកនិព្វានហោង ។

ដោយ **ម.ស.ខ.**

## ទាល់តែមិនទាញ បានមិនតឹង

ទាល់តែមិនទាញបានវាមិនតឹង គឺលែងឲ្យវាទៅតាមធម្មតា-ធម៌ យើងរៀនរស់នៅជាមួយនឹងការមិនប្រកាន់ ទើបកាត់បន្ថយសេចក្តីទុក្ខផ្លូវចិត្តបាន ។

## មនុស្សល្អ ខ្មើមបាប

មនុស្សស្អាត ខ្មើមរអើមរបស់ស្មោកគ្រោក ចំណែកមនុស្សល្អវិញ ខ្មើមឆ្អើមអំពើបាបរបស់ខ្លួនឯង ។

## ប្រយោជន៍ធំ បរមសុខ

ត្រីធំមាននៅតែក្នុងសមុទ្រទឹកជ្រៅ បើយើងមានតែទូកតូចនៅតែក្បែរៗមាត់ច្រាំង នឹងចាប់ត្រីធំបានយ៉ាងដូចម្តេចទៅ យ៉ាង-ណាមិញ ប្រយោជន៍ដ៏ក្រៃលែងជាប្រយោជន៍ធំ គឺឋិតនៅក្នុងជម្រៅ

នៃធម៌បដិបត្តិ ។ បើមានត្រឹមតែសីល ៥ ប៉ុណ្ណោះ វានៅកៀកនៅក្បែរនឹងកាមគុណពេកណាស់ ដូច្នេះត្រូវសមាទានឧបោសថ មាននូវនេក្ខម្មៈដោយការអប់រំចិត្ត ចម្រើនបញ្ញា លះបង់រឿងរ៉ាវក្នុងលោកិយ ចូលកាន់ផ្លូវនៃជីវិតបរិសុទ្ធគឺអរិយមគ្គអង្គ ៨ មិនប្រាថ្នាភពផុតចាកពីតណ្ហា នេះទើបជាការបានសម្រេចនូវប្រយោជន៍ធំ បរមសុខសាន្ត ។

## ទ្រុងមាសទ្រុងប្រាក់

បក្សីនៅក្នុងទ្រុងមាសដែលមនុស្សសាងឡើង តាមពិតទ្រុងនោះធ្វើអំពីអ្វីក៏ដោយ គឺសុទ្ធតែជាទោសទាំងអស់ ព្រោះឃុំឃាំងហាមឃាត់សេរីភាព ។ មនុស្សដែលគិតថាខ្លួនឯងឆ្លាតជាងសត្វប៉ុន្តែបែរជាត្រេកអរនឹងទ្រុងសម្បត្តិ ទ្រុងមាស ទ្រុងប្រាក់ ដែលខ្លួនឯងសាងឡើង ប្រព្រឹត្តទៅជាពន្ធនាគារ ចងរួបរឹតខ្លួនឯង រហូតគ្រប់ពេលវេលា ។

# ប្រាជ្ញានាំមកនូវប្រយោជន៍

បើយើងចង់មើលរបស់ល្អ គប្បីមើលខ្លឹមសារនៃព្រះត្រៃបិដក ចំណែកអ្វីៗផ្សេងទៀត យើងមិនចាំបាច់ទាស់ចិត្តដោយគិតថា មិនល្អនោះទេ គឺខ្លួនយើងហ្នឹងឯង ដែលត្រូវរៀបចំឲ្យអ្វីៗបានល្អប្រសើរឡើងសម្រាប់យើងខ្លួនឯង ។ តាមពិត វាមិនមានអ្វីដែលអាក្រក់សម្រាប់យើងទេ បើយើងមិនគិតថាអាក្រក់ទេនោះ អ្វីៗក៏យើងអាចបំពេញឲ្យសម្រេចបានជាបារមីជាមួយនឹងអ្វីៗនោះដែរ កាលបើដូច្នេះ តើយើងចង់ឲ្យរបស់អ្វីៗ ទៅជាអ្វីទៅវិញទៀត ទោះជាអ្វីនោះល្អប្រសើរគាប់ចិត្តយ៉ាងណា ក៏វាមិនល្អពូកែស័ក្តិសិទ្ធិដូចជាបារមីដែរ ។ បុគ្គលដែលមានប្រាជ្ញារមែងរកប្រយោជន៍បាន អំពីអ្វីៗសព្វគ្រប់ សូម្បីពីបុគ្គលដែលមិនមានប្រយោជន៍ ។

# ៩. គោលិស្សានិសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង មាន ភិក្ខុមួយអង្គឈ្មោះគោលិស្សានិ ជាអ្នកសមាទាននូវអារញ្ញកធុតង្គ ជាអ្នកមានមារយាទមិនរៀបរយ អង្គុយក្នុងកណ្តាលជំនុំសង្ឃ ដោយ កិច្ចណាមួយ ។

លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ប្រារព្ធនូវគោលិស្សា-និភិក្ខុ ហើយទើបពោលនឹងភិក្ខុទាំងឡាយថា ម្នាលអ្នកដ៏មានអាយុ ទាំងឡាយ ភិក្ខុដែលសមាទាននូវអារញ្ញកធុតង្គ កាលនឹងទៅកាន់ទី ប្រជុំសង្ឃ ៖

១- នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែប្រកបដោយសេចក្តី គោរពកោតក្រែង ចំពោះពួកសព្រហ្មចារីទាំងឡាយ ។

២- នៅក្នុងកណ្តាលជំនុំសង្ឃ គួរជាអ្នកឈ្លាសក្នុងការអង្គុយ ថា អាត្មាអញនឹងមិនអង្គុយជ្រៀតជ្រៀតភិក្ខុទាំងឡាយជាថេរៈផង មិនហាមឃាត់ភិក្ខុថ្មីទាំងឡាយដោយអាសនៈផង ។

៣- នៅក្នុងកណ្ដាលជំនុំសង្ឃ មិនគួរចូលទៅកាន់ស្រុកឲ្យហួសវេលា មិនគួរត្រឡប់មកឲ្យទាល់តែថ្ងៃហួសនោះដែរ ។

៤- នៅក្នុងកណ្ដាលជំនុំសង្ឃ មិនគួរដល់នូវការត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្ត និងក្រោយភត្តឡើយ ។

៥- នៅក្នុងកណ្ដាលជំនុំសង្ឃ មិនគួរមានចិត្តរាយមាយឃ្លេងឃ្លោងឡើយ ។

៦- នៅក្នុងកណ្ដាលជំនុំសង្ឃ កុំជាអ្នកមានមាត់រឹង កុំជាអ្នកមានវាចាឡេះឡោះឡើយ ។

៧- នៅក្នុងកណ្ដាលជំនុំសង្ឃ គួរជាអ្នកប្រដៅងាយ មានកល្យាណមិត្ត ។

៨- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ។

៩- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកដឹងប្រមាណក្នុងភោជន ។

១០-ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកប្រកបរឿយៗនូវការភ្ញាក់រលឹក ។

១១- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកប្រារព្ធ

ព្យាយាម ។

១២- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកតាំងស្មារតីឲ្យមាំ ។

១៣- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកមានចិត្តខ្ជាប់ខ្ជួន ។

១៤- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គួរជាអ្នកមានប្រាជ្ញា ។

១៥- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គប្បីធ្វើសេចក្តីព្យាយាមក្នុងអភិធម្មនិងអភិវិន័យ ។

១៦- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គប្បីធ្វើសេចក្តីព្យាយាមក្នុងវិមោក្ខដ៏ល្អិត គឺអរូបសមាបត្តិដែលកន្លងនូវរូបសមាបត្តិ ។

១៧- ភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ គប្បីជាអ្នកធ្វើសេចក្តីព្យាយាម ក្នុងឧត្តរិមនុស្សធម្ម គឺលោកុត្តរធម៌ ។

កាលព្រះសារីបុត្តសម្តែងយ៉ាងនេះហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលពាក្យនេះនឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោសារីបុត្ត ចុះធម៌ទាំងនេះ សម្រាប់តែភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គទេឬ ទើបសមាទានប្រព្រឹត្តបាន ឬក៏ភិក្ខុ

ដែលនៅក្នុងស្រុកគួរសមាទានប្រព្រឹត្តបានដែរ ។ ព្រះសារីបុត្តតបថា ម្នាលមោគ្គល្លានដ៏មានអាយុ ធម៌ទាំងនេះ សូម្បីភិក្ខុអ្នកសមាទាននូវអារញ្ញកធុតង្គ ក៏គួរតែសមាទានប្រព្រឹត្តទៅហើយ នឹងចាំបាច់ពោលទៅថ្វីដល់ភិក្ខុដែលនៅក្នុងស្រុក ។

ព្រះសារីបុត្តបានញ៉ាំងគោលិស្សានិភិក្ខុ ឲ្យបានសម្រេចព្រះ-អរហត្តដោយលំដាប់ តាំងអំពីអភិសមាចារិកវត្ត ដោយអំណាចនៃបុគ្គលដែលគួរណែនាំបាន ។

សូមអនុមោទនា !

## បញ្ញានិងករុណានៃព្រះមហាបុរស

ខ្លួនឯងឆ្លងដោយបញ្ញា ញ៉ាំងអ្នកដទៃឲ្យឆ្លងដោយករុណា ។

កំណត់ដឹងទុក្ខរបស់អ្នកដទៃដោយបញ្ញា ប្រារព្ធជួយដោះទុក្ខអ្នកដទៃដោយករុណា ។

ធុញទ្រាន់ នឿយណាយចំពោះទុក្ខដោយបញ្ញា ទទួលទុក្ខដោយករុណា ។

ឆ្ពោះមុខទៅព្រះនិព្វានដោយបញ្ញា ដល់នូវវដ្តៈដោយ

ករុណា ។

នឿយណាយក្នុងទីទាំងពួងដោយបញ្ញា ប៉ុន្តែព្រោះប្រព្រឹត្តទៅដោយករុណា ទើបត្រូវអនុគ្រោះសត្វទាំងពួង ។

ភាពជាបុគ្គលមិនមានអហង្ការមមង្ការ ( សេចក្តីប្រកាន់ថា អញ របស់អញ ) ដោយបញ្ញា មិនមានការខ្ជិលច្រអូសដោយករុណា ។

ជាអ្នកមិនធ្វើខ្លួនឯងឲ្យក្តៅក្រហាយដោយបញ្ញា មិនធ្វើអ្នកដទៃឲ្យក្តៅក្រហាយដោយករុណា ។

ការសម្រេចប្រយោជន៍ខ្លួនឯងដោយបញ្ញា ញ៉ាំងប្រយោជន៍អ្នកដទៃឲ្យសម្រេចដោយករុណា ។

ភាពជាអ្នកមានធម៌ជាធំដោយបញ្ញា មានលោកជាធំដោយករុណា ។

ភាពជាអ្នកដឹងគុណដោយបញ្ញា ជាបុព្វការីដោយករុណា ។

ការប្រាសចាកមោហៈដោយបញ្ញា ប្រាសចាកតណ្ហាដោយករុណា ។

ការសម្រេចវិជ្ជាដោយបញ្ញា សម្រេចចរណៈដោយករុណា ។

ការសម្រេចនូវទសពលញ្ញាណដោយបញ្ញា សម្រេចនូវវេសារជ្ជញ្ញាណដោយករុណា ។

## ត្រូវប្រយ័ត្នរឿង ៤ មុខ

១- ក្រព្រោះបរិភោគ

២- ស្មោកគ្រោកព្រោះយស

៣- ខូចឈ្មោះព្រោះកាម

៤- រហេមរហាមព្រោះឈ្លោះគ្នា ។

## ៤ មុខល្អប្រសើរ

១- បរិភោគឲ្យរស់

២- ប្រើយសសង្គ្រោះជន

៣- កាមគុណត្រូវសង្រួម

៤- យល់ព្រមឈប់ឈ្លោះ ។

# ១០. កីដាគិរិសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកក្នុងកាសីជនបទ មួយអន្លើដោយភិក្ខុសង្ឃច្រើនអង្គ ។ សេចក្ដីផ្ដើមនៅក្នុងព្រះសូត្រនេះ គឺព្រះពុទ្ធអង្គទ្រង់ត្រាស់ឲ្យភិក្ខុទាំងឡាយ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ ចំណែកនៅក្នុងភទ្ទាលិសូត្រ ព្រះ-អង្គទ្រង់ឲ្យវៀរចាកការបរិភោគក្នុងវេលាវិកាលដែលជាពេលថ្ងៃ ។

ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកតាមលំដាប់ក្នុងកាសីជនបទ រហូតដល់និគមឈ្មោះកីដាគិរីនៅក្នុងកាសីជនបទនោះឯង នៅក្នុងនិគមនោះ មានភិក្ខុពីរអង្គគឺអស្សជិភិក្ខុ និងបុនព្វ-សុកភិក្ខុ ដែលជាភិក្ខុនៅក្នុងចំណោមឆព្វគ្គិយភិក្ខុ លោកមិនព្រមតាមព្រះដ៏មានព្រះភាគឡើយ គឺលោកនៅទាមទារឆាន់មួយថ្ងៃបីដងព្រឹកថ្ងៃល្ងាច ។

ក្នុងការសម្ដែងព្រះធម៌ទេសនា ព្រះបរមសាស្ដា ទ្រង់លើកយកវេទនាបីអាស្រ័យកាមគុណ ដែលនាំឲ្យអកុសលធម៌ចម្រើនឡើងកុសលធម៌សាបសូន្យទៅ ដោយព្រះអង្គត្រាស់ថា តថាគតធ្លាប់ដឹង

ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញា ទើបតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវវេទនាបែបនេះចេញ ។ ចំណែកវេទនាបីអាស្រ័យនេក្ខម្មៈ ដែលនាំឲ្យកុសលធម៌ចម្រើនឡើង អកុសលធម៌សាបសូន្យទៅ ព្រះអង្គទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរសម្រេចនៅដោយវេទនាបែបនេះចុះ ។

ជាបន្ត ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងអំពីព្រះអរិយបុគ្គល ៧ ពួក ដែលមានព្រះអរហន្តពីរពួក និងព្រះសេក្ខបុគ្គល ៥ ពួក ។ ព្រះអរហន្តពីរពួកគឺឧភតោភាគវិមុត្តបុគ្គល និងបញ្ញាវិមុត្តបុគ្គល មិនបាច់ធ្វើកិច្ចដោយសេចក្តីមិនប្រមាទឡើយ ព្រោះភិក្ខុទាំងឡាយនោះបានធ្វើកិច្ចរួចហើយដោយសេចក្តីមិនប្រមាទ ពួកភិក្ខុជាព្រះអរហន្តនោះ មិនគួរប្រមាទទៀតឡើយ ។ ចំណែកព្រះសេក្ខបុគ្គល ៥ ពួកគឺកាយសក្ខីបុគ្គល ១ ទិដ្ឋិប្បត្តបុគ្គល ១ សទ្ធាវិមុត្តបុគ្គល ១ ធម្មានុ-សារីបុគ្គល ១ និងសទ្ធានុសារីបុគ្គល ១ ត្រូវធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ប្រព្រឹត្តទៅដើម្បីសម្រេចបានជាព្រះអរហន្ត ។

**នាហំ ភិក្ខវេ អាទិកេនេវ** ដោយសេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថាការតាំងនៅក្នុងអរហត្តផល ជាធម៌មុនដំបូងនោះទេ គឺត្រូវមានការសិក្សាដោយលំដាប់ មានការធ្វើដោយលំដាប់ មានការប្រតិបត្តិដោយលំដាប់ គឺ

**សទ្ធាជាតោ** មានសទ្ធាដែលជាទីតាំងនៃសេចក្តីសម្រេចកើតឡើងហើយ ។

**ឧបសង្កមតិ** រមែងចូលទៅរកគ្រូ ។

**បយិរុបាសតិ** រមែងអង្គុយក្នុងសម្នាក់គ្រូ ។

**សោតំ ឱទហតិ** ផ្ទៀងត្រចៀក ។

**ធម្មំ សុណាតិ** ស្តាប់ធម៌ ។

**ធម្មំ ធារេតិ** ទ្រទ្រង់ចាំទុកនូវធម៌ ។

**ធម្មានំ អត្ថំ ឧបបរិក្ខតោ** រមែងពិចារណាសេចក្តីនៃធម៌ដែលទ្រទ្រង់ចាំទុកនោះ ។

**ធម្មា និជ្ឈានំ ខមន្តិ** ធម៌ទាំងឡាយគួរដល់កិរិយាសម្លឹងពិនិត្យលៃលក ។

**ឆន្ទោ ជាយតិ** បំណងនឹងធ្វើក៏បានកើតឡើង ។

**ឧស្សហតិ** ឧស្សាហ៍ព្យាយាម ។

**តុលេតិ** ស្ទាបស្ទង់ថ្លឹងថ្លែងក្នុងត្រៃលក្ខណ៍ ។

**បទហតិ** តម្កល់នូវសេចក្តីព្យាយាមក្នុងមគ្គ ។

**បហិតត្តោ** មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។

**កាយេន ចេវ បរមំ សច្ចំ សច្ឆិករោតិ** ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចគឺព្រះនិព្វានដោយនាមកាយ ។

**បញ្ញាយ ច នំ អតិវិជ្ឈ បស្សតិ** ទាំងបាន ចាក់ធ្លុះឃើញច្បាស់នូវបរមសច្ចនោះ ដោយបញ្ញា គឺមគ្គប្បញ្ញា ដែលសម្បយុត្តដោយនាមកាយ ។

ព្រោះហេតុតែភិក្ខុនោះៗបានដំណឹងថា ព្រះបរមសាស្តាស្តេចយាងមក ក៏មិនធ្វើសូម្បីតែការទទួលព្រះសាស្តាដូច្នេះហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលនូវការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើសទ្ធានោះមិនមានហើយ ការចូលទៅរកក៏មិនមាន ។ល។ ឆន្ទៈបំណងនឹងធ្វើក៏មិនមាន ឧស្សាហ៍ក៏មិនមាន ការស្វាបស្ទង់ថ្លឹងថ្លែងក៏មិនមាន ការតម្កល់នូវបធានក្នុងមគ្គក៏មិនមាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមុខតែនឹងដល់នូវវិបត្តិ មុខតែនឹងប្រតិបត្តិខុសពុំខាន ម្នាលភិក្ខុទាំងឡាយ មោឃបុរសអម្បាលនេះ នឹងឃ្លាតចាកនូវធម្មវិន័យនេះឆ្ងាយប៉ុនណាទៅ ។

ជាចុងបញ្ចប់នៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសាវ័កជាអ្នកមានសទ្ធា កាន់តាមហើយប្រព្រឹត្តនៅក្នុងព្រះសាសនានៃព្រះសាស្តាដែលមិនជាប់ជំពាក់ដោយអាមិសៈទាំងឡាយ គឺថា ព្រះ-ដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវអានិសង្សក្នុងការបរិភោគតែម្តង ចំណែកអាត្មាអញពុំបានជ្រាបឡើយ ។ កាលដែលសាវ័កមាននូវ

សទ្ធាប្រព្រឹត្តតាមដូច្នេះ សាសនារបស់ព្រះសាស្តានឹងដុះដាល មានឱជារសឆ្ងាញ់ទៅបាន ទាំងដែលសាវ័កអ្នកមានសទ្ធានោះប្រារព្ធសេចក្តីព្យាយាមប្រកបដោយអង្គ ៤ នឹងបានសម្រេចជាព្រះអរហន្តឬព្រះអនាគាមិបុគ្គលពុំខានឡើយ ។

លុះព្រះដ៏មានព្រះភាគ បានត្រាស់សម្តែងនូវព្រះសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្តត្រេកអរ ចំពោះភាសិតនៃព្រះដ៏មានព្រះភាគ ។

សូមអនុមោទនា !

## សេចក្តីសុខធំទូលាយ

សុខធំ មិនមែនព្រោះមានអ្វីធំៗ ដោយលាភ ដោយយស ឬដោយរបស់អ្វីក្នុងលោកនោះទេ គឺដោយសារមានទុក្ខតិចទេតើ ទុក្ខតិចព្រោះរាគៈ ទោសៈ និងមោហៈតិច។ កាលដែលមានសេចក្តីប្រាថ្នាតិច សូម្បីតែមានរបស់តិចហើយ ក៏ប្រាកដដូចជាមានច្រើនដូច្នេះ សេចក្តីសុខមិនមែននៅត្រង់មានអ្វីៗច្រើននោះទេ គឺនៅត្រង់

មានសេចក្តីត្រូវការតិចហ្នឹងឯង ទាំងដែលមានការមិនប្រកាន់ជាទីពឹង ។

## រកសុខក្នុងចិត្ត

បើយើងធ្វើរបស់ឲ្យបាត់នៅនឹងផ្ទះ ស្រាប់តែយើងទៅស្វែងរកនៅក្រៅផ្ទះ ប្រាកដជារកមិនឃើញឡើយ រឹតតែទៅឆ្ងាយប៉ុនណា រឹតតែមិនឃើញ ប៉ុន្តែបើយើងគិតឲ្យបានត្រឹមត្រូវថា យើងធ្វើឲ្យបាត់នៅនឹងផ្ទះ ដូច្នេះយើងត្រឡប់មករកក្នុងផ្ទះ យើងនឹងមានឱកាសបានឃើញ សេចក្តីនេះយ៉ាងណា សេចក្តីសុខក៏យ៉ាងនោះដែរ យើងធ្វើឲ្យបាត់អំពីចិត្តរបស់យើង សេចក្តីសុខនោះមិនមែនចេះនៅក្រៅចិត្តឡើយ ព្រោះជាចេតសិក ដូច្នេះបើយើងស្ទុះស្ទារកសុខនៅខាងក្រៅអំពីការអប់រំចិត្ត នឹងធ្វើឲ្យយើងជួបតែរឿងដែលនាំឲ្យកើតទុក្ខក្នុងចិត្តច្រើនឡើងថែមទៀត ទោះជាមានរឿងឲ្យរីករាយចិត្តខ្លះក៏គ្រាន់តែជាសុខបួម សុខក្លែងក្លាយ សុខគួរឲ្យខ្លាចតែប៉ុណ្ណោះ មិនមែនជាសេចក្តីសុខពិត សុខដែលប្រាសចាកទោសនោះឡើយ ។

សុខក្នុងការអប់រំចម្រើននូវកុសលចិត្ត ជានេក្ខម្មសុខ វិវេកសុខ ឧបសមសុខ និងជាសម្ពោធិសុខ ។

## សួស្តីសិរីភទ្រ

ធ្វើអ្វីពោលអ្វីឲ្យមានតម្លៃ គិតការយប់ថ្ងៃឲ្យមានច្រកទៅ
អត់ធន់ទ្រាំឃ្លានឲ្យមានទិសដៅ ជីវិតរស់នៅឲ្យមានសួស្តី ។

ដោយ **ម.ស.វ.**

## ស្រវឹងបាត់ស្មារតី

ស្រវឹងជីវិតភ្លេចមរណា ស្រវឹងកាយាភ្លេចជរា
ស្រវឹងបញ្ញត្តិភ្លេចធម្មា ស្រវឹងភរិយាភ្លេចម៉ែឪ ។

ដោយ **ម.ស.វ.**

# ព្រមរៀនប្រព្រឹត្តធម៌វិន័យ

ផ្ទះតូចក៏សុខដែរ គឺឲ្យតែចិត្តព្រមសុខ
បើចិត្តមិនស្រណុក ពិតជាទុក្ខទោះភូមិគ្រឹះ ។
រស់នៅរៀនសិក្សា ឲ្យជ្រាបថាការពិតនោះ
មិនដែលបោកយើងសោះ តែនេះព្រោះហេតុមិនព្រម ។
មិនព្រមដឹងការពិត តាមតែចិត្តមិនចេះល្មម
អារាមធាត់វត្តស្គម បើចេះល្មមពិតព្រមព្រៀង ។
ព្រមព្រៀងប្រព្រឹត្តធម៌ ចិត្តស្ងប់ល្អឃើញមិនទៀង
ដូចយប់អុជចង្កៀង មគ្គព្រមព្រៀងអង្គប្រាំបី ។
ប្រឹងប្រែងអប់រំចិត្ត ព្រោះជីវិតពិតជាខ្លី
លាភយសពេញផែនដី ធម៌វិន័យទើបបានក្រ ។
ក្របានកើតជាមនុស្ស ក្របានបួសក្រត្រេកអរ
ក្របានដឹងព្រះធម៌ ក្រសែនក្រក្រត្រាស់ដឹង ។
រំលឹកសាជាថ្មី ធម៌វិន័យត្រូវខំប្រឹង
ព្រះពុទ្ធក្រត្រាស់ដឹង ត្រូវខំប្រឹងផ្លូវតែមួយ ។
ឯកាយនមគ្គ ស្ងប់ត្រជាក់ផុតទុក្ខព្រួយ

បរមសុខចំណែកមួយ  គ្មានទុក្ខព្រួយលាយឡើយហោង ។

ដោយ **ប.ស.ទ.**

## មង្គល ៣៨ ប្រការ

១- **ការមិនគប់ជនពាល** ស្លឹកឈើខ្ចប់ត្រីស្អុយ វារមែងជាប់ស្អុយ ទៅតាមដែលស្លឹកឈើនោះប្រឡាក់ជាមួយនឹងត្រីស្អុយយ៉ាងណាមិញ ការសេពគប់ជនពាល នាំឲ្យកាន់យកធម៌ពាលមកដាក់ខ្លួន ហើយប្រព្រឹត្តបាបកម្មផ្សេងៗ មានរហូតដល់ថ្នាក់សម្លាប់មាតា សម្លាប់បិតាទៀតផង ក៏យ៉ាងនោះឯង ព្រោះហេតុដូច្នេះ ការមិនសេពគប់ជនពាល ទើបជាមង្គលដ៏ឧត្តម ។

២- **ការសេពគប់បណ្ឌិត** ស្លឹកឈូកខ្ចប់ផ្កាម្លិះ ផ្កាចេកទុំ ឬសំពត់ដែលខ្ចប់គ្រឿងក្រអូបផ្សេងៗ រមែងជាប់ក្រអូបតាមមកយ៉ាងណា ការសេពគប់បណ្ឌិត រមែងបានទទួលនូវចំណេះដឹង រហូតបានសម្រេចនូវលោកុត្តរកុសលដល់នូវព្រះនិព្វានទៀតផង យ៉ាងនោះឯង ។

៣- **កិរិយាបូជាដល់បុគ្គលដែលគួរបូជា** ដាំកូនឈើតូច ត្រូវមើលថែឲ្យបានសព្វគ្រប់ ដើម្បីឲ្យបានធំយ៉ាងណា បុគ្គលដែលប្រាថ្នាសេចក្ដីចម្រើន គប្បីបូជាដល់បុគ្គលដែលគួរបូជា ដើម្បីទុកជាតួយ៉ាងក្នុងដំណើរជីវិត សិក្សាបដិបត្តិកម្ចាត់ទោស ចម្រើនគុណ រីករាយក្នុងបុណ្យកុសល មានបុគ្គលដែលគួរបូជានោះជាទីរលឹក រហូតដល់សម្រេចបាននូវទីពឹង ដូច្នោះឯង ។

៤- **កិរិយានៅក្នុងប្រទេសដ៏សមគួរ** ព្រះពោធិព្រឹក្សកាលបើប្រតិស្ឋាននៅនឹងថើង មិនអាចធំបានប៉ុន្មានទៅឡើយ តែបើប្រតិស្ឋានក្នុងទីដែលល្អ មានផ្ទៃដីទូលំទូលាយ ព្រះពោធិព្រឹក្សប្រាកដជាធំ មានមែកត្រសុំត្រសាយ យ៉ាងណា មនុស្សយើងក៏ដូច្នោះដែរ គប្បីនៅក្នុងប្រទេសដែលមានសប្បុរស ជាទីដែលនាំឲ្យកុសលធម៌ចម្រើនឡើង អកុសលធម៌សាបសូន្យទៅ រហូតដល់បានសម្រេចនូវពោធិបក្ខិយធម៌ជាលោកុត្តរ ។

៥-**ភាពនៃបុគ្គលមានបុណ្យបានធ្វើទុកហើយ** ពូជនៃដំណាំល្អ វានាំឲ្យមានផលល្អ ដូចជាផ្លែច្រើន ផ្លែធំៗ និងមានឱជារសល្អជាដើម យ៉ាងណា មនុស្សយើងជាអ្នកមានបុណ្យបានធ្វើទុក

ហើយ ក៏ដូច្នោះដែរ គឺជាអ្នកដល់ព្រមដោយលោកិយសម្បត្តិ និង លោកុត្តរសម្បត្តិ ទៅតាមបុណ្យដែលបានធ្វើហើយជាកម្មប្បច្ច័យ និង ឧបនិស្សយប្បច្ច័យ ។

៦- **កិរិយាតម្កល់ខ្លួនដោយប្រពៃ** ស្រូវដែលនៅក្នុង ស្រែល្អ មានទឹកមានដីត្រឹមត្រូវ រមែងមានផលល្អ យ៉ាងណា មនុស្ស យើងដែលបានជួបប្រសព្វនូវសេចក្ដីសម្រេចក្នុងជីវិតទៅបាន ព្រោះ មកអំពីបានតម្កល់ខ្លួនដោយប្រពៃនៅក្នុងសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា យ៉ាងនោះឯង ។

៧- **ការចេះដឹងច្រើនជាពហុស្សូត** ពន្លឺរស្មីនៃព្រះ-អាទិត្យធ្វើឲ្យរុក្ខជាតិបានរស់ និងមានពណ៌ល្អស្រស់តាមធម្មជាតិ យ៉ាងណា ការចេះដឹងច្រើន ក៏ដូចជាពន្លឺរស្មីនៃព្រះអាទិត្យដូច្នោះ ដែរ ធ្វើឲ្យមនុស្សមានការអភិវឌ្ឍទៅតាមការចេះដឹងនោះឯង ។

៨- **សិល្បៈ** បានដល់កិច្ចការងារហត្ថកម្មដែលប្រាសចាក ទោស ធ្វើទៅដោយការវៃឆ្លាត ទាក់ទងនឹងការចេះដឹងដែលបាន សិក្សារៀនសូត្រមក ។ ការសិក្សារៀនសូត្របានចេះដឹង ប្រៀបដូច

ជាការដាំស្វាយ ចំណែកសិល្បៈប្រកបកិច្ចការមានធ្វើជាងជាដើម ដូចជាការបានផ្លែស្វាយបរិភោគ ។

៩- **មានវិន័យ** ចម្ការដំណាំត្រូវធ្វើរបងការពារសត្វគោក្របីជាដើម យ៉ាងណា ចំណេះដឹងនិងសមត្ថភាពក្នុងការងារ បើមិនមានវិន័យគ្រប់គ្រងទេ ប្រាកដជាត្រូវបរាជ័យដូច្នេះឯង ទើបត្រូវមានវិន័យ ។

១០- **វាចាសុភាសិត** សត្វខ្លះយំមានសំឡេងកោកកាកមិនពីរោះ ប៉ុន្តែសត្វតាវៅនៅលើចុងឈើខ្ពស់ យំពីរោះ ដែលអ្នកផងទាំងពួងតែងសរសើរ សេចក្ដីនេះគឺដូចពាក្យសម្ដីរបស់មនុស្សដូច្នោះដែរ អ្នកខ្លះនិយាយទុព្ភាសិត អ្នកខ្លះទៀតនិយាយសុភាសិត សម្ដីផ្កា សម្ដីទឹកឃ្មុំ វៀរចាកវចីទុច្ចរិត ៤ យ៉ាង ។

១១- **កិរិយាបម្រើមាតាបិតា** (២) ដើមដូង ដើមស្វាយជាដើម កាលណាគេដាំ គេមើលថៃ រហូតបានផ្លែជាផលតបស្នង

---

(២) **មាតាបិតុឧបដ្ឋានំ** អដ្ឋកថាថាចែកជាពីរក៏បាន រួមតែមួយក៏បាន ប៉ុន្តែដើម្បីឲ្យបាន ៤ មង្គល ត្រូវចែកជាពីរ ។

យ៉ាងណា កូនប្រុសស្រីមិនត្រូវឲ្យចាញ់ដើមឈើមានផ្លែទាំងនោះឡើយ ។

១២- **សង្គ្រោះបុត្ត** [៣] ឈើអណ្តែតទឹក គេស្រង់យកមកហាលថ្ងៃ គេច្នៃធ្វើអ្វីក៏បាន យ៉ាងហោចណាស់ក៏អុសដុតដែរ យ៉ាងណា ការសង្គ្រោះចិញ្ចឹមបីបាច់មើលថែបុត្រធីតាឲ្យបានល្អប្រកបដោយធម៌ ប្រាកដជាមិនចាញ់ការស្រង់ឈើអណ្តែតទឹកនោះឡើយ លើកលែងតែកូនអកតញ្ញូដែលអន់ជាងឈើអណ្តែតទឹកនោះឯង ។

១៣- **សង្គ្រោះភរិយា** ដើមឈើបានជាម្លប់ដល់អ្នកជ្រកដូច្នេះម្ចាស់ដើមឈើគប្បីថែរក្សាដើមឈើនោះ យ៉ាងណាការសង្គ្រោះគ្នារវាងភរិយាស្វាមីក៏យ៉ាងនោះដែរ ។

១៤- **ការងារមិនច្របូកច្របល់** ដើមឈើមានដើមស្វាយជាដើម តែកាលណាមានបញ្ញើក្អែក វារមែងអន់ដើម យ៉ាងណា ការងារបើធ្វើឲ្យច្របូកច្របល់ដោយសេចក្តីខ្ជិល នឹងត្រូវធ្លាក់

---

(៣) **បុត្តទារស្ស សង្គហោ** អដ្ឋកថាថាចែកជាពីរក៏បាន ។ ក្នុងគាថានេះមានមង្គលបី ឬបួន ឬក៏ប្រាំ ប៉ុន្តែផ្លូវការរាប់យក ៤ ។

ចុះ ក៏យ៉ាងនោះដែរ ។ ខ្លាចលំបាកហើយខ្ជិលមិនព្យាយាម មិនរួច អំពីសេចក្ដីលំបាកឡើយ ។ ខ្វះខន្ដីសេចក្ដីអត់ធន់ ការងារមិនបាន ល្អ ។ ខ្វះការតស៊ូ ការងារមិនសម្រេច ។ រវល់តែរឿងស្នេហា កាន់ ការងារធំមិនបាន ។ ព្រោះសេចក្ដីធ្វេសប្រហែស ការងារដែលចេះ ស្ទាត់ហើយនោះ ត្រឡប់ទៅជាបរាជ័យដូចបុគ្គលល្ងង់ខ្លៅ ដូច្នេះត្រូវ តែហ្មត់ចត់ក្នុងការងារ ។

១៥- **ការបំពេញទាន** ដើមឈើមានផ្កាក្រអូប មានផ្លែ ល្អ ឬបានជាម្លប់ល្អ រមែងជាទីត្រេកអរនៃមនុស្សសត្វទាំងឡាយ យ៉ាងណា អ្នកឲ្យទាន អាមិសទានក្ដី ធម្មទានក្ដី ក៏មានឈ្មោះថា ជា មនុស្សមានប្រយោជន៍ រមែងបានទទួលការលើកតម្កើង ការសរសើរ និងការជួយទំនុកបម្រុងអំពីមនុស្សទាំងឡាយ ក៏យ៉ាងនោះឯង ។

១៦- **ការប្រព្រឹត្តធម៌** គឺប្រព្រឹត្តនៅក្នុងកុសលកម្មបថ ១០ ធ្វើល្អបី សម្ដីល្អបួន និងមនោកម្មបី ។ ខ្លឹមចន្ទន៍ទោះបីស្ងួតក៏ មិនលះបង់ក្លិនក្រអូបយ៉ាងណា បណ្ឌិតទោះបីមានសេចក្ដីលំបាក ម្ដេចម្ដា ក៏មិនលះបង់ការប្រព្រឹត្តធម៌ឡើយ ។

១៧- **សង្គ្រោះញាតិ** ព្រៃឈើ មានដើមឈើដុះច្រើន ជាប់ៗគ្នា រមែងជួយទប់គ្នានៅគ្រាដែលមានខ្យល់ព្យុះ យ៉ាងណា ការសង្គ្រោះញាតិ ក៏យ៉ាងនោះដែរ ។ ការរាប់អានជិតដិតស្និទ្ធស្នាល មានទឹកចិត្តជួយគ្នាប្រកបដោយធម៌ ចេះឲ្យសេចក្តីសំខាន់ដល់គ្នា នេះគឺជាញាតិដ៏ក្រៃលែង ។

១៨- **ការងារប្រាសចាកទោស** បើយើងដាំទឹកឲ្យពុះ ហើយយកទៅចាក់ស្រោចគល់កូនឈើទាំងក្តៅក្នុងបំណងឲ្យកូនឈើ បានល្អ កុំឲ្យកណ្តៀរស៊ីគល់ ប្រាកដជាកូនឈើនោះងាប់ជាមិនខាន សេចក្តីនេះយ៉ាងណា ក្នុងការបណ្តុះបណ្តាលនូវគុណភាពនៃជីវិត ដែលប្រៀបដូចជាការដាំកូនឈើ ត្រូវតែគេចឲ្យផុតអំពីការងារទុច្ចរិត ព្រោះការងារនេះជាសត្រូវនឹងខ្លួនឯង ដូចចាក់ស្រោចទឹកក្តៅកំពុងពុះ ទៅនឹងគល់នៃកូនឈើដែលដាំដូច្នោះឯង ។ មនុស្សអត់ការងារជា មនុស្សអន់ មនុស្សទ្រមក់ ប៉ុន្តែបើមានការងារអាក្រក់ ទុច្ចរិតទៅវិញ នោះ ជាមនុស្សគម្រក់តែម្តង ដេកលក់វិញប្រសើរជាង ។ ការងារ បែងចែកមនុស្សឲ្យខ្ពង់ខ្ពស់ ឬថោកទាប ដូច្នេះមង្គលសិរីសួស្តី គឺនៅ ត្រង់ធ្វើការងារណាដែលបរិសុទ្ធប្រាសចាកទោស ត្រូវចេះស្រឡាញ់

ការងារនោះ ព្រោះមិនមានអ្នកណាម្នាក់គាំទ្រយើងឲ្យខ្ពង់ខ្ពស់ ក្រៅអំពីខ្លួនឯងដែលចេះគោរពការងាររបស់ខ្លួននោះឡើយ ។

១៩- **កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប** មនុស្សដែលស្រឡាញ់ការរស់នៅជាសុខ មិនគប្បីបរិភោគនូវផ្លែឈើពុលឡើយ យ៉ាងណា បុគ្គលគប្បីវៀរចាកបាបដើម្បីឲ្យរួចផុតចាកទុក្ខទោសក្នុងវដ្តសង្សារក៏ដូច្នោះដែរ ។

២០- **សង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង** អ្នកចម្ការរក្សាដំណាំក្នុងចម្ការយ៉ាងណា អ្នកស្រែថែស្រូវយ៉ាងណា មនុស្សល្អរមែងរក្សានូវស្មារតីរបស់ខ្លួនក៏យ៉ាងនោះឯង ។ ក្នុងការរក្សានូវស្មារតី ត្រូវវៀរចាកកិរិយាផឹកនូវទឹកស្រវឹងជាដើម ។

២១- **មិនប្រមាទក្នុងធម៌ទាំងឡាយ** គោខូចចុះស៊ីសន្ទូងក្នុងស្រែ ដោយសារអ្នកយាមធ្វេសប្រហែស លុះដល់គេយកចិត្តទុកដាក់យាមឲ្យបានល្អ គេចាប់គោវាយដោយដំបងរឿយៗ គោនោះក៏រាងចាល សន្ទូងក៏បានផល សេចក្តីនេះយ៉ាងណា គោខូចជាឈ្មោះនៃចិត្តខូច សន្ទូងក្នុងស្រែជាឈ្មោះនៃបញ្ចកាមគុណ អ្នកយាម

ធ្វេសប្រហែសជាឈ្មោះនៃសេចក្ដីប្រមាទ លុះដល់អ្នកយាមយកចិត្តទុកដាក់ នេះជាឈ្មោះនៃស្មារតីគឺសេចក្ដីមិនប្រមាទ ដំបងវាយគោជាឈ្មោះនៃឱវាទានុសាសនីរបស់ព្រះបរមសាស្ដា គោដល់នូវការរាងចាលជាឈ្មោះនៃការអប់រំចិត្តដោយព្រះកម្មដ្ឋាន សន្ទូងបានផលជាឈ្មោះនៃការបានសម្រេចមគ្គផល ។

២២- **សេចក្ដីគោរព** ភិក្ខុប្រមាណប្រាំរយអង្គ រៀនយកមេត្តាភាវនាអំពីព្រះដ៏មានព្រះភាគ ហើយបានផ្សព្វផ្សាយនូវមេត្តានោះដល់ពួកទេវតានៅតាមដើមឈើក្នុងព្រៃ ពួកទេវតាក៏បានទទួលនូវមេត្តានុភាព ហើយជួយទំនុកបម្រុងរក្សាដល់ព្រះភិក្ខុសង្ឃទាំងឡាយនោះ រហូតដល់លោកបានសម្រេចព្រះអរហត្តគ្រប់ទាំងប្រាំរយអង្គទៅ យ៉ាងណា ការដែលមនុស្សយើងនឹងបានទទួលផលប្រយោជន៍អំពីបុគ្គលណាៗ ក៏គប្បីជាអ្នកមានសេចក្ដីគោរពកោតក្រែងដល់បុគ្គលនោះៗ ក៏ដូច្នោះដែរ ។

២៣- **កិរិយាឱនលំទោន** គឺជាការដាក់ចុះនូវមានះរឹងត្អឹង ហើយឱនលំទោនដល់បុគ្គលដែលគួរឱនលំទោន ។ ឱនក្បាលឲ្យទាប លើកចិត្តឲ្យខ្ពស់ តម្កល់ខ្លួនឲ្យប្រពៃ ពាក្យខ្មែរថា

ងើយស្កុក ឱនដាក់គ្រាប់ ។ ដំណាំមានផ្លែដូចជាក្រូច មៀនជាដើម លុះដល់ផ្លែច្រើនធ្វើឲ្យមែកទន់ព្រោះធ្ងន់នឹងផ្លែ សភាពបែបនេះគឺល្អណាស់ ខុសអំពីមែកអត់ផ្លែឬងាប់ យ៉ាងណា សភាពទន់ភ្លន់ឱនលំទោនរបស់មនុស្សយើង ក៏យ៉ាងនោះដែរ ។

២៤- **សេចក្ដីសន្ដោស** ផ្លែឫស្សីសម្លាប់ដើម ផ្លែចេកក៏សម្លាប់ដើមដូចគ្នាដែរ យ៉ាងណា លាភសក្ការៈ មាសប្រាក់ទ្រព្យសម្បត្តិ ឋានៈបុណ្យស័ក្តិ រមែងសម្លាប់បុគ្គលល្ងង់ខ្លៅក៏យ៉ាងនោះ-ឯង ។ សម្លាប់ម្យ៉ាង គឺសម្លាប់កុសលធម៌ សម្លាប់ម្យ៉ាងទៀត គឺជាឈ្មោះនៃសេចក្ដីទុក្ខក្នុងវដ្តសង្សារ ។ សេចក្ដីសន្ដោសនេះ គឺជាសេចក្ដីសុខជាមួយនឹងរបស់ដែលមាន ប្រើប្រាស់របស់ដែលមានឲ្យជាប្រយោជន៍ក្នុងបុណ្យកុសល ប្រព្រឹត្តព្រហ្មចរិយធម៌បានសម្រេចជាមង្គលដ៏ឧត្តម ។

២៥- **ការដឹងគុណ** មានរឿងប្រៀបដូចជាថា ដើមឈើដែលមានផ្លែមានផ្កា សប្បាយចិត្តនឹងមនុស្សពោលសរសើរថាផ្កាល្អផ្លែឆ្ងាញ់ នាំឲ្យដើមឈើនោះចង់ហោះអណ្តែតទៅលើមេឃ ទាស់ចិត្តនឹងឫសគល់របស់ខ្លួន ។ ដើមឈើបានពឹងឲ្យខ្យល់ជួយផ្ដាច់ឫស

គល់ពីដី នឹងជួយឲ្យខ្លួនបានអណ្តែតទៅសប្បាយលេងក្នុងអាកាស ទីបំផុតដើមឈើត្រូវងាប់ដោយសារដាច់ឫសគល់ហ្នឹងឯង សេចក្តីនេះយ៉ាងណា បុណ្យដែលបានធ្វើទុកពីជាតិមុនក្តី បុព្វការីទាំងអស់ក្តី គឺសុទ្ធតែជាឫសគល់នៃការរស់នៅរបស់មនុស្សយើង អកតញ្ញូការមិនដឹងគុណគឺជាការផ្តាច់ឫសគល់របស់ខ្លួន ដែលនាំឲ្យខ្លួនដល់នូវសេចក្តីវិនាសយ៉ាងនោះឯង ដូច្នេះទើបការដឹងគុណជាមង្គលដ៏ឧត្តម ព្រោះនាំឲ្យបំពេញបារមី អប់រំគុណធម៌ជាឧបនិស្ស័យនៃអរិយមគ្គ ។ សម្រាប់អ្នកបួស ត្រូវប្រយ័ត្នចំពោះលាភសក្ការៈនិងលោកធម៌ផ្សេងៗទៀត ដែលប្រៀបដូចជាផ្កា ជាផ្លែ ជាខ្យល់ ជាអាកាស នាំឲ្យផ្តាច់ឫសគល់របស់ខ្លួនគឺវិន័យ ។

២៦- **ស្តាប់ធម៌តាមកាល** ព្រះមហាមោគ្គល្លានត្ថេរ បានអារាធនាគ្រាប់ពូជព្រះពោធិព្រឹក្ស ពីទីដែលព្រះសម្មាសម្ពុទ្ធត្រាស់ដឹងទៅប្រគេនព្រះអានន្ទត្ថេរនៅនាវត្តជេតពន លោកសេដ្ឋីអនាថបិណ្ឌិកជាអ្នកប្រតិស្ឋាននូវគ្រាប់ពូជព្រះពោធិព្រឹក្សនោះ សេចក្តីនេះយ៉ាង-ណា ការស្តាប់ ការសិក្សាព្រះធម៌ក្នុងព្រះពុទ្ធសាសនា គឺជាការប្រតិស្ឋាននូវគ្រាប់ពូជនៃការត្រាស់ដឹងអរិយសច្ចធម៌ គ្រាប់ពូជនោះគឺតថាគតពោធិសទ្ធាហ្នឹងឯង ។

២៧- **សេចក្តីអត់ធន់** ដើមឈើធន់នឹងកម្តៅថ្ងៃ ដើម្បីឲ្យមនុស្សសត្វបានជ្រកយ៉ាងណា មាតាបិតាទ្រាំទុក្ខលំបាក ដើម្បីជាជម្រករបស់កូនប្រុសស្រីយ៉ាងណា សេចក្តីអត់ធន់ក៏ជាជម្រកដ៏ត្រជាក់របស់ចិត្ត យ៉ាងនោះដែរ ។ អារម្មណ៍ដែលនាំឲ្យកើតរាគៈ ដូចជាភ្លៀង អារម្មណ៍ដែលនាំឲ្យកើតទោសៈ ដូចជាកម្តៅថ្ងៃ អារម្មណ៍ដែលនាំឲ្យកើតមោហៈ ដូចជាខ្យល់ព្យុះ អារម្មណ៍ដែលនាំឲ្យភ័យខ្លាចដូចជាសត្វសាហាវក្នុងព្រៃ ចំណែកខន្តីគឺសេចក្តីអត់ធន់ប្រៀបដូចជាប្រាសាទកែវ ចិត្តប្រៀបដូចជាស្តេចចក្រពត្តិ ដែលគង់ប្រថាប់ក្នុងប្រាសាទកែវនោះឯង ។

២៨- **បុគ្គលដែលគេប្រដៅបានដោយងាយ** សម័យពុទ្ធកាល ពេទ្យជីវកកោមារភច្ច បានវេរចម្ការស្វាយធ្វើវត្តនៅជិតភ្នំគិជ្ឈកូដ បាវារិកសេដ្ឋីក៏វេរចម្ការស្វាយធ្វើវត្តដែរ នៅស្រុកនាឡន្ទា ចំណែកនាងអម្ពបាលីក៏វេរចម្ការស្វាយដូចគ្នានៅវេសាលី រហូតមកដល់សព្វថ្ងៃក៏នៅតែសម្បូណ៌ចម្ការស្វាយ បានសេចក្តីថា ជាដើម-ឈើងាយដាំ មានផលគាប់ប្រសើរ យ៉ាងណា មនុស្សដែលគេងាយថា ងាយប្រដៅ គឺជាមនុស្សមានតែសេចក្តីចម្រើនដូចជាព្រះរាធៈ

ព្រះរាហុលជាដើម រមែងបានទទួលនូវឱវាទរឿយៗ អ្នកណាៗក៏ចូលចិត្តប្រាប់ រំលឹកដាស់តឿនដែរ ។

២៩- **ការបានឃើញសមណៈ** ព្រះបរមពោធិសត្វ បានយាងមកដល់ព្រះពោធិព្រឹក្សដែលដុះក្នុងថ្ងៃព្រះអង្គទ្រង់ប្រសូត ព្រះ-អង្គទ្រង់បានត្រាស់ដឹងក្រោមព្រះពោធិព្រឹក្សនោះ ទាំងបានប្រថាប់ឈរសម្លឹងព្រះពោធិព្រឹក្សក្នុងសប្តាហ៍ទីពីរ ដោយមិនប៉ប្រិចព្រះនេត្រ សេចក្តីនេះយ៉ាងណា ការបានឃើញនូវសមណៈអ្នកស្ងប់រម្ងាប់នូវបាបមានព្រះសម្មាសម្ពុទ្ធជាដើម នាំឲ្យបានសម្រេចនូវប្រយោជន៍តាមឧបនិស្ស័យ និងនាំឲ្យបានបំពេញនូវសេចក្តីល្អផ្សេងៗ ទាំងបានជាតួយ៉ាងអំពីសមណៈអង្គនោះៗ ដូច្នោះឯង ។

៣០- **សន្ទនាធម៌តាមកាល** យកឈើច្រើនដើមមកបញ្ឈរដាក់ចុងទល់គ្នា រមែងជួយទប់គ្នាទៅវិញទៅមកមិនឲ្យដួលយ៉ាងណា សាកច្ឆាគឺកិរិយាសន្ទនាគ្នាទៅវិញទៅមកនូវព្រះធម៌ រមែងជួយគ្នាឲ្យបានយល់ដឹង អស់ការសង្ស័យ ដែលជាផ្លូវនៃការរួចចាកទុក្ខ ។

៣១- **ការប្រព្រឹត្តតបៈ** គឺសង្រួមឥន្ទ្រិយដុតអភិជ្ឈានិងទោមនស្ស ប្រៀបដូចជាការកាប់ព្រៃដុតស្មៅដើម្បីធ្វើចម្ការដូច្នោះដែរ ។ មានពាក្យខ្មែរយើងមួយឃ្លាថា ចង់បានផ្លែផ្កា យកភ្លើងដុតគល់ គឺដុតគល់នៃវដ្តសង្សារបានដល់អវិជ្ជានិងតណ្ហាហ្នឹងឯង ឯពាក្យថាផ្លែផ្កាគឺជាឈ្មោះនៃការបានសម្រេចអរិយផល ឯចំណែកភ្លើងបានដល់ការបំពេញតបៈ សម្រេចវិបស្សនាញាណ និងមគ្គញ្ញាណ ។

៣២- **ការប្រព្រឹត្តព្រហ្មចរិយធម៌** បន្ទាប់ពីកាប់ព្រៃដុតស្មៅ ត្រូវប្រញាប់ដាំដំណាំ កុំទុកយូរនាំឲ្យដុះស្មៅ កើតព្រៃត្រឡប់មកវិញ យ៉ាងណា មនុស្សយើង កាលដែលប្រព្រឹត្តតបៈហើយ ត្រូវព្យាយាមបណ្តុះបណ្តាលនូវគុណធម៌ផ្សេងៗក្នុងចិត្តសន្តានជាការប្រព្រឹត្តនូវព្រហ្មចរិយធម៌ឲ្យបានធំខ្ពស់ឡើង កម្ចាត់បង់បាបដែលដូចជាស្មៅនិងកូនព្រៃឈើ កុំឲ្យត្រឡប់កើតឡើងវិញ ក៏ដូច្នោះឯង ។

៣៣- **ឃើញអរិយសច្ច** ភ្លៀងធ្លាក់រឿយៗ នាំឲ្យដំណាំដាំដុះក្នុងចម្ការ បានផលផ្លែផ្កា យ៉ាងណាការប្រព្រឹត្តព្រហ្មចរិយធម៌ប្រកបដោយសេចក្តីព្យាយាម ក៏បានសម្រេចនូវការចាក់ធ្លុះអរិយ-

សច្ចធម៌ ដោយវិបស្សនាញាណនិងមគ្គញ្ញាណ ក៏យ៉ាងនោះដែរ ។

៣៤- **ជាក់ច្បាស់នូវព្រះនិព្វាន** ម្ចាស់ចម្ការមានជីវភាពធូរធារ ចិញ្ចឹមជីវិតរស់នៅបានដោយសារផលដំណាំក្នុងចម្ការយ៉ាងណា អរិយមគ្គមានព្រះនិព្វានជាអារម្មណ៍ ធ្វើកិច្ចជាក់ច្បាស់ក្នុងព្រះនិព្វានដែលជាអមតៈ និងធ្វើកិច្ចបីទៀតក្នុងអរិយសច្ច ក៏ដូច្នោះឯង ។

៣៥- **ចិត្តដែលមិនញាប់ញ័រក្នុងលោកធម៌** សិលាគិរីមិនញាប់ញ័រនឹងកម្លាំងខ្យល់ យ៉ាងណា បុគ្គលដែលជាក់ច្បាស់ក្នុងព្រះនិព្វាន អស់រាគៈ ទោសៈ និងមោហៈហើយ រមែងមានចិត្តមាំទាំមិនញាប់ញ័រក្នុងលោកធម៌ទាំងឡាយ យ៉ាងនោះដែរ ។

៣៦- **ការមិនសោកសៅ** ជនទាំងឡាយ តែងសោកសៅព្រោះធ្លាក់ចុះក្នុងរណ្តៅនៃការហួងហែង ដូចជាមនុស្សអត់ផ្ទះសំបែងរស់នៅហាលភ្លៀងហាលខ្យល់។ បុគ្គលកាប់ឈើយកមកធ្វើផ្ទះ អស់កង្វល់នឹងហាលភ្លៀងហាលខ្យល់ យ៉ាងណា បុគ្គលបាននូវអនិច្ចសញ្ញាជាកម្លាំងអស់ការហួងហែង ក៏លែងមានសេចក្តីសោកសៅ

តទៅទៀតដែរ ។

៣៧- **ចិត្តប្រាសចាកធូលី** ផ្កាឈូកដុះផុតអំពីភក់ អំពីទឹក ភក់ក្តី ទឹកក្តី មិនបានប្រឡាក់សើមផ្កាឈូកនោះ យ៉ាងណា ព្រះហឫទ័យនៃព្រះខីណាស្រពផុតចាកលោកហើយ លោកទាំងបីក៏មិនបានប្រឡាក់ព្រះហឫទ័យនៃព្រះខីណាស្រពនោះ ដោយរាគៈជាដើមឡើយ ដូច្នោះដែរ ។

៣៨- **ចិត្តក្សេមក្សាន្ត** បុគ្គលកាលវង្វេងនៅក្នុងព្រៃ រមែងមានភ័យ លុះផុតចាកព្រៃបានឃើញផ្លូវសំដៅមករកភូមិស្រុកហើយ ក៏សប្បាយចិត្តលែងមានការភ័យភិតតទៅទៀត យ៉ាងណា ព្រះ-អរហន្តទាំងឡាយ បានរួចផុតចាកវដ្តសង្សារ មានកិលេសវដ្តៈជាដើមហើយ ក៏រមែងមានព្រះហឫទ័យក្សេមក្សាន្ត មិនមានភ័យអ្វីទៀតឡើយ ក៏យ៉ាងនោះឯង ។

សូមអនុមោទនា !

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ

# ក្នុងការខារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក អ៊ឹម វ៉ៃយ៉ា |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូផា | ២០. ឧបាសិកា ហាយច័ន្ទធរី |
| ២១. ឧបាសក គឹម សោភ័ណ | ២២. ឧបាសក ហង់ វណ្ណៈ |

## សព្វទានំ ធម្មទានំ ជិនាតិ

ធម្មទានឈ្នះអស់ទានទាំងពួង ។

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

| | | |
|---|---|---|
| ១- | លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហគ្គា +បុត្រ ..... | ស.រ.អ. |
| ២- | ឧ.សិ.កេតុ ថូរ + ឧ.សិ.ស្វាយ សិត + កូនចៅ ...................... | ស.រ.អ. |
| ៣- | ឧ.ស.កែម សុគន្ធ និង ឧ.សិ.ជា សុភាព ............................ | ស.រ.អ. |
| ៤- | ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៥- | ឧ.សិ.គុជ ឡាំងអេង និង អ្នកស្រី សេង យុវផា + កូនចៅ .. | ស.រ.អ. |
| ៦- | ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ....................... | ស.រ.អ. |
| ៧- | ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ ............................ | ស.រ.អ. |
| ៨- | ឧ.ស.ចាន់ ម៉ល់ និង ឧ.សិ.ជា សុផា ................................. | ស.រ.អ. |
| ៩- | ឧ.សិ.ឆាន់ ហៃគឹង ព្រមទាំងបុត្រ និង ចៅ .................... | ស.រ.អ. |
| ១០- | ភិក្ខុ ឆុំសារឿន+ភិក្ខុឈួមសម្បូរ+ពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | ស.រ.អ. |
| ១១- | ឧ.ស.ជា គុំ ................................................................ | ស.រ.អ. |
| ១២- | ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ព្រមទាំងបុត្រ .. | ស.រ.អ. |
| ១៣- | ឧ.ស.ជឹម អេងស្រ៊ន និង ឧ.សិ.វ៉ា សុខគីន ព្រមទាំងបុត្រ +ចៅ | ស.រ.អ. |
| ១៤- | ឧ.សិ.ជុំ ឆដា ( ហៅ លាភ )........................................ | ស.រ.អ. |
| ១៥- | ឧ.ស.ឈួន ផារិន និង ឧ.សិ.ព្រំ ប្រណិត ...................... | ស.រ.អ. |
| ១៦- | ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. | ស.រ.អ. |
| ១៧- | ឧ.ស.តាប ឈន និង ឧ.សិ.ព្រាប មិច ........................... | ស.រ.អ. |
| ១៨- | លោក តាំង គឹមស៊ាង និង លោកស្រី ជា ស៊ីវអេង ................ | ស.រ.អ. |
| ១៩- | ឧ.សិ.តាំង លេខគៀវ ( ហៅ តាំងហ៊ាង ) ព្រមទាំងកូនចៅ . | ស.រ.អ. |

២០- ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ ស.រ.អ.

២១- ឧ.ស.តាំង អាង និង ឧ.សិ.កួយ ឡាំហួង ព្រមទាំងបុត្រ ........ ស.រ.អ.

២២- ឧ.សិ.ប៉ាន សារិទ្ធ ហៅង៉ា ព្រមទាំងកូនចៅ ................... ស.រ.អ.

២៣- ឧ.សិ.ប៊ិត ថងខាំ និង ឧ.សិ.សាន ផល្លីនព្រមទាំងបុត្រ+ចៅ. ស.រ.អ.

២៤- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹងវិទ្ធារី ព្រមទាំងបុត្រ ...... ស.រ.អ.

២៥- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................ ស.រ.អ.

២៦- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ...... ស.រ.អ.

២៧- ឧ.ស.ម៉ៃ គួលអេង និង ឧ.សិ.រស់ កល្យាណ ................... ស.រ.អ.

២៨- ឧ.សិ.រស់ លីណា ព្រមទាំងកូនចៅ .... ស.រ.អ.

២៩- ឧ.ស.លី ឌីន និង ឧ.សិ.ថាច់ លីហ៊ាន ................................ ស.រ.អ.

៣០- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ............................................. ស.រ.អ.

៣១- ឧ.សិ.លី សូវង្ស .......................................................... ស.រ.អ.

៣២- ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ . ស.រ.អ.

៣៣- ឧ.សិ.ស៊ីវ យក់លុយ ព្រមទាំងបុត្រ និងចៅ .................. ស.រ.អ.

៣៤- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... ស.រ.អ.

៣៥- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... ស.រ.អ.

៣៦- ឧ.សិ.ស្រង់ អៃ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៣៧- ឧ.ស.ស្រេង វិសុទ្ធ និង អ្នកស្រី គឹម ស្រ៊ុនកណិកា + បុត្រ ..... ស.រ.អ.

៣៨- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ ស.រ.អ.

៣៩- ឧ.សិ.ហេង លាភ ព្រមទាំងបុត្រ និង ចៅ ....................... ស.រ.អ.

៤០- ឧ.ស.ហោ លាន និង ឧ.សិ.ឆឹង អួន ............................... ស.រ.អ.

៤១- ឧ.សិ.ឡុង អ៊ុម ព្រមទាំងបុត្រ និងចៅ ........................ ស.រ.អ.

| | | |
|---|---|---|
| ៤២- | ឧ.ស.ឡេង កុយ និង ឧ.សិ.ឈឹម សេន ........................ | ស.រ.អ. |
| ៤៣- | ឧ.សិ.ឡាំង គឹមឆេង ព្រមទាំងបុត្រ ............................ | ស.រ.អ. |
| ៤៤- | ឧ.សិ.អួន ញ៉ ........................................................... | ស.រ.អ. |
| ៤៥- | លោកគ្រូធម្មបណ្ឌិត អឿ សៅ .................................. | ស.រ.អ. |
| ៤៦- | ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . | ស.រ.អ. |
| ៤៧- | ឧ.សិ.កែវ សុខលាភ ព្រមទាំងបុត្រ .............................. | អូស្ត្រាលី |
| ៤៨- | កញ្ញា ខុម គាដារ៉ា ( ហៅ ស្រីណេ ) .............................. | អូស្ត្រាលី |
| ៤៩- | យុវជន ខុម ច័ន្ទឱណា .................................................. | អូស្ត្រាលី |
| ៥០- | ឧ.ស.ខុម ពុធដានី និង ឧ.សិ.គាប ពុទ្ធារី .................... | អូស្ត្រាលី |
| ៥១- | ឧ.ស.ង៉ូវ ឈើវ និង ឧ.សិ.ហេង ពាស៊ីម ព្រមទាំងបុត្រ+ចៅ | អូស្ត្រាលី |
| ៥២- | ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ........................ | អូស្ត្រាលី |
| ៥៣- | ឧ.សិ.ជូ រ៉េន ....................................................... | អូស្ត្រាលី |
| ៥៤- | ឧ.សិ.ឈ គឹមស៊ីន និង ក្រុមគ្រួសារកូនចៅ .................. | អូស្ត្រាលី |
| ៥៥- | ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... | អូស្ត្រាលី |
| ៥៦- | លោក ញ៉ាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ | អូស្ត្រាលី |
| ៥៧- | ឧ.ស.ឌុច ផ្លែក និង ឧ.សិ.ហ៊ុន ណូក ............................ | អូស្ត្រាលី |
| ៥៨- | ឧ.សិ.តាំង ស៊ីយន ..................................................... | អូស្ត្រាលី |
| ៥៩- | ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. | អូស្ត្រាលី |
| ៦០- | ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ .......... | អូស្ត្រាលី |
| ៦១- | ឧ.ស.ប៉ុច រឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. | អូស្ត្រាលី |
| ៦២- | លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ | អូស្ត្រាលី |
| ៦៣- | ឧ.សិ.ពុធ សុខង៉ោ+ឧ.សិ.លី វណ្ណា និង ឧ.ស.ខួយ ចេង ... | អូស្ត្រាលី |

| | | |
|---|---|---|
| ៦៤- | ឧ.សិ.ម៉េង ប៊ុន្នារី ( ហៅស្រីពៅ ) និងស្វាមី ព្រមទាំងបុត្រ. | អូស្ត្រាលី |
| ៦៥- | ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. | អូស្ត្រាលី |
| ៦៦- | ឧ.សិ.យិន មួយឡាង និង ស្វាមី ព្រមទាំងបុត្រ .............. | អូស្ត្រាលី |
| ៦៧- | លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ........ | អូស្ត្រាលី |
| ៦៨- | ឧ.ស.រស់ ធារុន និង ឧ.សិ.ហេង សុមានធា ........................ | អូស្ត្រាលី |
| ៦៩- | ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . | អូស្ត្រាលី |
| ៧០- | ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់ រិទ្ធ ព្រមទាំងបុត្រ ........... | អូស្ត្រាលី |
| ៧១- | ឧ.សិ.លឹម ស៊ូឆេង ព្រមទាំងកូនចៅ .......................... | អូស្ត្រាលី |
| ៧២- | ឧ.ស.លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី ព្រមទាំងបុត្រ... | អូស្ត្រាលី |
| ៧៣- | ឧ.ស.សរ ប៊ុនធឿង ព្រមទាំងបុត្រ និងចៅ.................. | អូស្ត្រាលី |
| ៧៤- | ឧ.ស.ស៊ីវ មាស និង ឧ.សិ.លាង ណាំសួរ ព្រមទាំងកូនចៅ.. | អូស្ត្រាលី |
| ៧៥- | ឧ.សិ.សុខ ណារី និង ស្វាមី ព្រមទាំងបុត្រ .................... | អូស្ត្រាលី |
| ៧៦- | កញ្ញា ស៊ុយ ដាណែត ............................................ | អូស្ត្រាលី |
| ៧៧- | ឧ.ស.ស៊ូ យឹម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ+ចៅ.. | អូស្ត្រាលី |
| ៧៨- | ឧ.សិ.សៀង វ៉ូច ព្រមទាំងកូនចៅ .............................. | អូស្ត្រាលី |
| ៧៩- | ឧ.សិ.សេង សៀងឈុន ព្រមទាំងបុត្រ និងចៅ ............. | អូស្ត្រាលី |
| ៨០- | ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... | អូស្ត្រាលី |
| ៨១- | កុង ហេង ឡេងថៃ និង ម៉ា អ៊ា គីមទាង+ចៅថៃ យីអ៊ុយ | អូស្ត្រាលី |
| ៨២- | ឧ.សិ.ហេង ពាអ៊ី និង ឧ.ស.អេង តាយ+កូនអេង ឡាយហួរ | អូស្ត្រាលី |
| ៨៣- | លោកម្ចាស់ សីលឋាវរោ ឡូញ ផល្លី ........................... | អូស្ត្រាលី |
| ៨៤- | ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ........ | អូស្ត្រាលី |
| ៨៥- | ឧ.សិ.អ៊ន ម៉ា ព្រមទាំងកូនចៅ .................................... | អូស្ត្រាលី |

៨៦- ឧ.សិ.អ៊ុច សុផល្លី ព្រមទាំងកូនចៅ ............................... អូស្ត្រាលី

៨៧- HENG Srey Chea+HENG Srey Chan+H.Srey Neang. ... អូស្ត្រាលី

៨៨- ឧ.សិ.គី អ៊ីភីង ........................................................... បារាំង

៨៩- ឧ.សិ.គីម ហួយ ព្រមទាំងបុត្រ និងចៅ ..................... បារាំង

៩០- ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ ព្រមទាំងបុត្រ... បារាំង

៩១- ឧ.សិ.ចាន់ សុស (ហៅសាម៉េត) និង ឧ.ស.ឆាយ អូន+កូនចៅ បារាំង

៩២- ឧ.ស.ជីន ជុង និងភរិយា.......................................... បារាំង

៩៣- ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ ............... បារាំង

៩៤- ឧ.សិ.ទាវ គឹមហ៊ួន និង កូនចៅ ...................................... បារាំង

៩៥- ឧ.សិ.ប្រាក់ គា និង គ្រួសារ ព្រមទាំងកូនចៅ ..................... បារាំង

៩៦- ឧ.សិ.យិន មួយហួរ .................................................... បារាំង

៩៧- ឧ.សិ.យុគ ជា និង បុត្រ ................................................ បារាំង

៩៨- ឧ.ស.លាភ ឆាយ និង ឧ.សិ.ហែម ពៅ ព្រមទាំងបុត្រ ....... បារាំង

៩៩- ឧ.ស.ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ........... បារាំង

១០០- ឧ.ស.ឡោ សេងជ្រុន និង ឧ.សិ.ផាំង លី កូនចៅ .......... បារាំង

១០១- DARRIET DAMIEN ជាម រ៉ានី (ហៅស្រីនាង) ......... បារាំង

១០២- ឧ.សិ.ចំណាន ព្រមទាំងក្រុមគ្រួសារ ......................... កាណាដា

១០៣- ឧ.សិ.ឆាយ ស៊ន ព្រមទាំងបុត្រ និងចៅ+ចៅទួត......... កាណាដា

១០៤- ឧ.ស.ពុធ ប៉ោលាង និង ឧ.សិ.ហ៊ុន ស៊ីវអៀង+កូនចៅ . កាណាដា

១០៥- Chhem Sokreth.Puth Kunthea+Rothmony+Bunnawat. កាណាដា

១០៦- Su Sokunora et Inn Visal+Narita et Raksa ..... កាណាដា

១០៧- ឧ.សិ. លី វន ព្រមទាំងក្រុមគ្រួសារ ......................... កាណាដា

| | | |
|---|---|---|
| ១០៨- | ឧ.ស.ឡៅ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន+បុត្រ .. | កាណាដា |
| ១០៩- | ឧ.សិ.អ៊ា នៅ និង ឧ.សិ.អ៊ា គីមយូ ព្រមទាំងកូនចៅ ....... | កាណាដា |
| ១១០- | ឧ.សិ.ត្រា វ៉ាន្នី ឧ.ស.ត្រា គីមពិសារនិង ឧ.សិ.ត្រា សារឿន. | ស្វីស |
| ១១១- | ឧ.ស.កាន់ គង់ និង ឧ.សិ.ជីវ យួម ព្រមទាំងកូនចៅ ............ | ប.ប. |
| ១១២- | ឯ.ឧ.កាន់ រ៉ាត់ និង ឧ.សិ.កែវ កល្យាណ+ក.កាន់សុថារត្ន័ | ភ.ព. |
| ១១៣- | ឯ.ឧ.កែវ ស៊ីវន និង លោកជំទាវ លួង ណារ៉េត+បុត្រធីតា .... | ភ.ព. |
| ១១៤- | ឧ.សិ.កៅ គីមជ្រី និង កូនចៅ ..................................... | ភ.ព. |
| ១១៥- | ឧ.ស.កាំង ប៉េងជីវ និង ឧ.សិ.លឹម អ៊ីហ៊ាម + កូនចៅ ..... | ភ.ព. |
| ១១៦- | ឧ.សិ.ខឹម តាន់ និង កូនចៅ ........................................ | ភ.ព. |
| ១១៧- | ឧ.សិ.ខៀវ វុត្ថា (ហៅមុំ).................................... | ភ.ព. |
| ១១៨- | ឧ.ស.ខៀវ ជៀប និង ឧ.សិ.ប៉ោ គីមស្រ៊ាង ព្រមទាំងកូនចៅ | ភ.ព. |
| ១១៩- | ឧ.សិ.គង់ ម៉ៃ ព្រមទាំងបុត្រ និងចៅ ........................ | ភ.ព. |
| ១២០- | ឧ.ស.គង់ សៀងហៃ និង ឧ.សិ.ប៉ក់ សូត្រតារាភិឱន+បុត្រ | ភ.ព. |
| ១២១- | ឧ.ស.គង់ ហេង និង ឧ.សិ.ធាវ ស៊ីប ព្រមទាំងកូនចៅ .. | ភ.ព. |
| ១២២- | ឧ.ស.គិន កូ និង ឧ.សិ.ម៉ៅ ថេង ព្រមទាំងបុត្រធីតា ......... | ភ.ព. |
| ១២៣- | ឧ.ស.គីម ឡុង និង ឧ.សិ.កាំង ដានី ព្រមទាំងបុត្រ ............ | ភ.ព. |
| ១២៤- | លោកយាយ គីម គាល +កូនចៅ + ចៅទួត ...................... | ភ.ព. |
| ១២៥- | ឧ.សិ.គីម សុខុន ព្រមទាំងបុត្រ និងចៅ .................... | ភ.ព. |
| ១២៦- | ឧ.ស.គុជ ជ និង ឧ.សិ.សុខ អេង ព្រមទាំងកូនចៅ ............ | ប.ប. |
| ១២៧- | ឧ.ស.គួច ឡៃស្រេង និង ឧ.សិ.ជិន ហួរ ........................ | ភ.ព. |
| ១២៨- | ឧ.សិ.គ្រី ណៃប៊ួយ ព្រមទាំងបុត្រ ............................ | ភ.ព. |
| ១២៩- | លោក ឃួន តុលា និង អ្នកស្រី លឹម សុខហួរ + បុត្រ ........... | ភ.ព. |

១៣០- ឧ.ស.ឃ្លោក យិត និងពុទ្ធបរិស័ទខេត្តព្រះសីហនុ ........ ក.ព.ស.

១៣១- ឧ.ស.ងឹម ញាណ និង ឧ.សិ.កាំង ប៉ូលីន ព្រមទាំងបុត្រ . ភ.ព.

១៣២- ឧ.ស.ង៉ូវ គា និង ឧ.សិ.ឈុន គីមអេង ព្រមទាំងបុត្រ ... ប.ប.

១៣៣- ឧ.សិ.ង៉ូវ មុយអ៊ី ព្រមទាំងកូនចៅ ................................ ប.ប.

១៣៤- ឧ.ស.ង៉ែត ផេង និង ឧ.សិ.ហៅ ហេង+បុត្រ ផេង បូរ៉ា . ភ.ព.

១៣៥- ឧ.សិ.ច័ន្ទ ណារឿន+ឪពុក ច័ន្ទ ឆឹង និងម្តាយ មួង ភី ..... ភ.ព.

១៣៦- ឧ.សិ.ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា ..................... ភ.ព.

១៣៧- ឧ.ស.ច័ន្ទ សុខុម និង ឧ.សិ.គីម ចន្ថា ព្រមទាំងកូនចៅ ... ភ.ព.

១៣៨- ឧ.សិ.ចុង ថូ និង កូនចៅ .......................................... ភ.ព.

១៣៩- ឯ.ឧ.ចែម វីឌ្យ៉ា និង លោកជំទាវ សុខា ស៊ូលីវណ្ណ+បុត្រ. ភ.ព.

១៤០- ឧ.សិ.ច្រឹង គីមស្រ៊ី ព្រមទាំងបុត្រ .......................... ភ.ព.

១៤១- ឧ.សិ.ឆាយ សែង ព្រមទាំងកូនចៅ .............................. ប.ប.

១៤២- ឧ.ស.ឆេង ស្រ៊ា និង ឧ.សិ.ផាន គីមហ៊ី ព្រមទាំងកូនចៅ ...... ភ.ព.

១៤៣- ឧ.ស.ជ័យ ភា (តាន់គុណសេរី) អ្នកស្រី ឆេង សុវណ្ណារី+បុត្រ ភ.ព.

១៤៤- ឧ.សិ.ជា នាង និងកូនចៅ +ឧ.សិ.ឈីវ គីមសាន និងកូនចៅ . ប.ប.

១៤៥- ឧ.ស.ជា រ៉ានី និង ឧ.សិ.លឹម សុភ័ណ ព្រមទាំងបុត្រធីតា .. ភ.ព.

១៤៦- ឧ.សិ.ជា សុណារី និងក្មួយស្រី ជា សុមេធាធីតា .......... ភ.ព.

១៤៧- ឧ.ស.ជា សុខុម និង ឧ.សិ.អ៊ុន ពូន ព្រមទាំងបុត្រ ....... ភ.ព.

១៤៨- ឧ.ស.ជាន យ៉ែត និង ឧ.សិ.សុក ចេង ព្រមទាំងបុត្រ ..... ភ.ព.

១៤៩- លោកស្រី ជីវ គីមឆេង និង ឧ.សិ.ជីវ យ៉ា +ឧ.សិ.ភូ នាវ .... ប.ប.

១៥០- ឧ.សិ.ជីវ វួចម៉េង ព្រមទាំងកូនចៅ ............................. ប.ប.

១៥១- ឧ.សិ.ជឹង គីមស្រ៊ី +ឧ.សិ.វង្ស ឈៀកនាង និងស្វាមី+បុត្រ ភ.ព.

១៥២- ក្រុមឧ.សិ.ជុន ស៊ូគី និង ក្រុមឧ.សិ.អ៊ុឹង យុនធួន ................ ភ.ព.

១៥៣- ឧ.សិ.ជូ ឆេងហោ .............................................. ក.ព.ឆ.

១៥៤- ឧ.សិ.ជួង ខេន ព្រមទាំងកូនចៅ .................................. ភ.ព.

១៥៥- ឧ.សិ.ជួន ស្រី ............................................................ ភ.ព.

១៥៦- ឧ.ស.ជ្រា បេង និង ឧ.សិ.គ្រឹត គីម .............................. ភ.ព.

១៥៧- ឧ.សិ.ជ្រុន ស៊ីដេត និងប្អូន +ក្មួយ និងចៅ .................. ភ.ព.

១៥៨- ឧ.សិ.ឈឹម ផលវិទ្យា និងក្មួយ វរុណ ភក្តី .................. ភ.ព.

១៥៩- ឧ.សិ.ឈុន ណារី និងកូនចៅ+ឧ.សិ.តោ ឡោ និងកូនចៅ ភ.ព.

១៦០- ឧ.សិ.ឈួន គឹមនី និងបងប្អូន កូនក្មួយ ...................... ភ.ព.

១៦១- ឧ.សិ.ឌួង គុយអេង និង កូនចៅ .................................... ភ.ព.

១៦២- ឧ.ស.តាក គីអ៊ាង ឧ.សិ.ឱម លាងគ្រី+កូនតាកវិរវណ្ណ+ចៅ . ភ.ព.

១៦៣- លោក តាន់ គុណសេរី និង អ្នកស្រី ឆេង សុវណ្ណារី + បុត្រ ...... ភ.ព.

១៦៤- ឧ.សិ.តាន់ ជាលី ........................................................ ស.រ.

១៦៥- ឧ.សិ.តូច វន្ថា ( នាមដើម តូច ណាំយ៉េន និង ស្វាមី+កូនចៅ .. ស.រ.

១៦៦- ឧ.ស.តែ គឹមហ៊ុន និង ឧ.សិ..តាំង សុខអ៊ឹម+ ភ.ព.

១៦៧- ឧ.សិ.តាំង លីគាង និង ស្វាមី ព្រមទាំងបុត្រ +ចៅ ...... ភ.ព.

១៦៨- ឧ.ស.តាំង សុផល និង ឧ.សិ.ឡុង កេង ព្រមទាំងបុត្រ ...... ប.ប.

១៦៩- កុមារី តាំង សុមាវតី ................................................ ប.ប.

១៧០- ឧ.សិ.តាំង ប៉ោជឹង ( ទន់) និង ឧ.ស.អ៊ឹង ហ្គិចឡេង+ កូនចៅ .. ប.ប.

១៧១- ឧ.ស.ទា ឈីវម៉ូវ និង ឧ.សិ.តាំង មុយលី + បុត្រធីតា ........ ភ.ព.

១៧២- ឧ.សិ.ទី សុធី និង កូន ហែម តុលា +ឡាយ មុយឡេង .......... ភ.ព.

១៧៣- ទូចផាន់ណាស៊ី សុខច័ន្ទណារិទ្ធ+ឧ.ស.ខៀវរិន ឧ.សិ.គឹមផន ... ភ.ព.

| | | |
|---|---|---|
| ១៧៤- | ព្រះបាឡាត់គណ ទេព ធីន+ភិក្ខុ សូចាន់ស៊ីម+ភិក្ខុ ប៉ែនសេដ្ឋា | ក.ព.ឆ. |
| ១៧៥- | ឯ.ឧ.ធ្នាំ (ធម្ម) ប៊ុនស្រុន លោកជំទាវ យ៉ែម សួស្តី+បុត្រ. | ភ.ព. |
| ១៧៦- | ឧ.ស.នាក់ ឌីឡែន និង ឧ.សិ.ខៀវ បុណ្យថា ព្រមទាំងបុត្រ .. | ភ.ព. |
| ១៧៧- | ឧ.សិ.នឹម វណ្ណី +ឯ.ឧ គីន ឡាយ លោកជំទាវ អ៊ុង គីមរី +បុត្រ | ភ.ព. |
| ១៧៨- | ឧ.ស.នុត វន្ថា និង ឧ.សិ.ម៉ៅ សុភា ព្រមទាំងបុត្រ ...... | ភ.ព. |
| ១៧៩- | ឧ.ស.នុត សារិន និង ឧ.សិ.ម៉ី ដារ៉េ + កូនចៅ .................... | ភ.ព. |
| ១៨០- | ឧ.សិ.នួន សូនី និង បុត្រ ................................................ | ប.ប. |
| ១៨១- | ឧ.ស.នួន ឡុន និង ឧ.សិ.ឡុង មុនីបញ្ញា + បុត្រី ................ | ភ.ព. |
| ១៨២- | ឧ.សិ.ប៉ក់ សុភាព ព្រមទាំងបុត្រ និងចៅ .................. | ភ.ព. |
| ១៨៣- | ឧ.ស.ប៉ក់ សូត្រ និង ឧ.សិ.លឹម ណៃហៀង+បុត្រធីតា+ចៅ | ភ.ព. |
| ១៨៤- | ឧ.ស.ប៉ុល នាង និង ឧ.សិ.គ្រៀល ស៊ីយ៉ា +បុត្រ+ចៅ . | ភ.ព. |
| ១៨៥- | ឧ.សិ.ប៊ូ សៀកលីវ+ឧ.ស.ឈុនចន្ថា និងឧ.សិ.ភត់សុធន្នី+បុត្រ | ប.ប. |
| ១៨៦- | ឧ.សិ.ប៊ូអាន ស៊ីវុត្ថា ........................................... | ភ.ព. |
| ១៨៧- | ឧ.សិ.ប៊ូ ផាវ៉ាណេ ................................................ | ភ.ព. |
| ១៨៨- | ឧ.សិ.ព ធារី និងក្រុមគ្រួសារ កូនចៅ ព្រមទាំងម្តាយ ........... | ភ.ព. |
| ១៨៩- | ឧ.ស.ព្រុំ សុន+ឧ.សិ.ស៊ុនយុត និង ស្រេងគង់+ផៃស៊ីវឡាយ | ភ.ព. |
| ១៩០- | ឧ.ស.ភាវ សាន និង ឧ.សិ.ប៉ក់ សុបុណ្យ+បុត្រ........... | ភ.ព. |
| ១៩១- | លោកតា ម៉ក់ មេង និង ម៉ា សៀក ព្រមទាំងកូនចៅ ....... | ភ.ព. |
| ១៩២- | ឧ.ស.មាស ខេង និង ឧ.សិ.មួរ វួច + កូនចៅ ...................... | ភ.ព. |
| ១៩៣- | ឧ.ស.ម៉ួង យឿនវណ្ណៈ និង ឧ.សិ.ប៉ក់ សូត្រសុន្នី+បុត្រ.. | ភ.ព. |
| ១៩៤- | លោក ម៉េង ប៊ុនណា និង ភរិយា ព្រមទាំងបុត្រ ............. | ភ.ព. |
| ១៩៥- | ឧ.ស.ម៉ែន សឿន ឧ.សិ.អៀង ណារី +កូន សយ វណ្ណា+កូនចៅ | ភ.ព. |

| | | |
|---|---|---|
| ១៩៦- | ឧ.សិ.ម៉ៅ ថេង និង ស្វាមី ព្រមទាំងបុត្រ ......................... | ភ.ព. |
| ១៩៧- | ឧ.សិ.ម៉ៅ សុផល ព្រមទាំងបុត្រ ....................................... | ភ.ព. |
| ១៩៨- | ឧ.ស.ម៉ៅ ផុន និងមាតា យស សម្បត្តិ .................... | ភ.ព. |
| ១៩៩- | ឧ.ស.ម៉ៅ ម៉ន និង ឧ.សិ.ទួន យ៉ាន ព្រមទាំងកូនចៅ ...... | ប.ប. |
| ២០០- | ឧ.ស.ម៉ៅ វ៉ាន និង ឧ.សិ.ធន់ សំបូរ ព្រមទាំងកូនចៅ ........ | ភ.ព. |
| ២០១- | ឧ.ស.ម៉ៅ សយ និង ឧ.សិ.គង់ ចំរើន +បុត្រ+ចៅ ....... | ភ.ព. |
| ២០២- | ឧ.ស.ម៉ៅ សុគន្ធ និង ឧ.សិ.អ៊ឹង យ៉េកហួយ និងបុត្រ .. | ភ.ព. |
| ២០៣- | ឧ.ស.ម៉ៅ ស្រ៊ិន និង ឧ.សិ.ទូច ស៊ីនហ៊ន+បុត្រ+ចៅ..... | ភ.ព. |
| ២០៤- | ឧ.សិ.ម៉ៅ សុន្ថា ................................................ | ភ.ព. |
| ២០៥- | ឧ.ស.យ៉ត មី និង ឧ.សិ.ស៊ូ គៀង ព្រមទាំងបុត្រ ................ | ភ.ព. |
| ២០៦- | ឧ.ស.យន្ត សួន និង ឧ.សិ.តាំង ឈុងប៊ួយ +កូនចៅ ...... | ភ.ព. |
| ២០៧- | ឯកឧត្តម យិន សារ៉ាន់ លោកជំទាវ អ៊ាន អេឡែន និងបុត្រ | ភ.ព. |
| ២០៨- | ឧ.ស.យឹម ស៊ីមុន្នី និង ឧ.សិ.យូ ប៉ូលីន និងបុត្រ+ចៅ ... | ភ.ព. |
| ២០៩- | ឧ.សិ.យុន គីមជី និង ឧ.សិ.ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ. | ភ.ព. |
| ២១០- | ឧ.ស.យូ ម៉េង និង ឧ.សិ.ឆេង ហ៊ាងស្រីពុំ ...................... | ក.ព.ស. |
| ២១១- | ឧ.ស.យ៉ាំ ស្រេន និង ឧ.សិ.អ៊ុល សេងលាង +បុត្រ....... | ភ.ព. |
| ២១២- | ឧ.ស.រស់ សំណាង និង ឧ.សិ.ឈង ម៉ាក់នី ព្រមទាំងកូនចៅ. | ភ.ព. |
| ២១៣- | លោក រឿង សេដ្ឋា និង អ្នកស្រី នាង ជួនអេង +បុត្រ .. | ភ.ព. |
| ២១៤- | ឧ.សិ.រៀល យ៉ូន ព្រមទាំងបុត្រ ............................ | ភ.ព. |
| ២១៥- | ឧ.សិ.លាង ស៊ីវប៊ួយ និង ឧ.សិ.ហ៊ឺ ហ៊ន + កូនចៅ ............ | ភ.ព. |
| ២១៦- | ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ និងចៅ ...................... | ភ.ព. |
| ២១៧- | ឧ.សិ.លី ឡៃហ៊ាង និង កូនចៅ ..................................... | ភ.ព. |

| | | |
|---|---|---|
| ២១៨- | ឧ.សិ.លី គុយហ៊ួរ និង ឧ.សិ.លី ហ្គេចឡាង+ស្វាមី+បុត្រ | ភ.ព. |
| ២១៩- | ឧ.សិ.លឹម អេង ព្រមទាំងបុត្រ .............................. | ភ.ព. |
